មិថុនា ២០១៨



# ការស្វែងយល់អំពីការប្រើប្រាស់គ្រាប់ពូជ និងផលប៉ះពាល់មកលើសន្តិសុខស្បៀង សុវត្ថិភាពស្បៀង និងភាពជាម្ចាស់លើគ្រាប់ពូជ និងស្បៀងរបស់កសិករខ្នាតតូច និងមធ្យមនៅកម្ពុជា


សិក្សាស្រាវជ្រាវ និងរបាយការណ៍ដោយ

| សកម្មភាពសង្គមដើម្បីសហគមន៍ និង ការអភិវឌ្ឍ | បណ្ដាញពហុវិស័យ | ក្រុមស្រាវជ្រាវសកម្ម(អង្គការផ្ដោតទៅលើលោកខាងត្បូង) |

របាយការណ៍ស្រាវជ្រាវ

# "ការស្វែងយល់អំពីការប្រើប្រាស់គ្រាប់ពូជ និងផលប៉ះពាល់មកលើសន្តិសុខស្បៀង សុវត្ថិភាពស្បៀង និង ភាពជាម្ចាស់លើគ្រាប់ពូជនិងស្បៀង របស់កសិករខ្នាតតូច និងមធ្យមនៅកម្ពុជា"

សិក្សាស្រាវជ្រាវ និងរបាយការណ៍ដោយ៖

អង្គការសកម្មភាពសង្គមដើម្បីសហគមន៍និងការអភិវឌ្ឍ (SACD)

បណ្តាញពហុវិស័យ (CGCN)

ក្រុមស្រាវជ្រាវសកម្ម នៃអង្គការផ្តោតទៅលើលោកខាងត្បូង (ART-Focus on The Global South)

ខែ មិថុនា ឆ្នាំ២០១៨

**មាតិកា**


១. សេចក្តីផ្តើម

២. សេចក្តីសង្ខេបអំពីរបកគំហើញសំខាន់ៗ

៣. សេចក្តីសង្ខេបអំពីស្ថានភាពកសិកម្មដំណាំស្រូវនៅកម្ពុជា

៤. ទំនើបភាវូបនីយកម្មនៃវិស័យកសិកម្មដំណាំស្រូវនៅកម្ពុជា

៥. គោលបំណង និង វិធីសាស្រ្តនៃការសិក្សា

៦. របកគំហើញសំខាន់ៗនៃការសិក្សាស្រាវជ្រាវ

 ៦.១. បទពិសោធន៍ធ្វើស្រែរបស់កសិករ

 ៦.២. ហានិភ័យមកលើសន្តិសុខស្បៀង សុវត្ថិភាពស្បៀង និងអធិបតេយ្យស្បៀង របស់កសិករ

 ៦.៣. ការស្វែងយល់អំពីជម្រើសថ្មីក្នុងការធ្វើស្រែ

៧. សេចក្តីសរុប

៨. អនុសាសន៍របស់កសិករ និង ពីក្រុមស្រាវជ្រាវ

## ១. សេចក្តីផ្តើម

សកម្មភាពសង្គមដើម្បីសហគមន៍និងការអភិវឌ្ឍ សហការជាមួយនឹងកសិករនៃបណ្តាញពហុវិស័យ និងក្រុមស្រាវជ្រាវសកម្ម បានធ្វើការសិក្សាស្រាវជ្រាវរួមគ្នាមួយស្តីពី **«ការស្វែងយល់អំពីការប្រើប្រាស់គ្រាប់ពូជ និងផលប៉ះពាល់មកលើ សន្តិសុខស្បៀង សុវត្ថិភាពស្បៀង និង អធិបតេយ្យស្បៀង របស់កសិករខ្នាតតូច និងមធ្យមនៅកម្ពុជា»**។ ការសិក្សាស្រាវជ្រាវនេះត្រូវបានធ្វើឡើង ដោយសារតែមានការសង្កេតឃើញថា មានបញ្ហាមួយចំនួនបានកើតឡើងនិងមានឥទ្ធិពលមកលើជីវភាពរបស់កសិករខ្នាតតូច និង មធ្យម និង វិស័យកសិកម្មនៅកម្ពុជា។ បញ្ហាប្រឈមចម្បងៗខាងក្រោមនេះ ត្រូវបានលើកឡើងដោយកសិករសមាជិកបណ្តាញពហុវិស័យ ក្នុងនោះមានកសិករដែលបានចូលរួមក្នុងសិក្ខាសាលាមូលដ្ឋានចំនួន៧៧សិក្ខាសាលាក្នុងអំឡុងពេលពីខែសីហា ដល់ខែតុលា ឆ្នាំ២០១៦ (អំឡុងពេលដែលបណ្តាញពហុវិស័យបានចុះផ្សព្វផ្សាយ ពង្រឹងការយល់ដឹង និងវិភាគអំពីសេចក្តីព្រៀងច្បាប់ដឹកសិកម្ម[1]នៅក្នុងខេត្តចំនួន១៥នៃប្រទេសកម្ពុជា ដោយមានអ្នកចូលរួមសរុបប្រមាណជា១៧០០នាក់) និងនៅក្នុងវេទិកាកសិករស្តីពីសេចក្តីព្រៀងច្បាប់ដឹកសិកម្ម ដោយមានកសិករចូលរួមចំនួន៤៧៨នាក់ ព្រមទាំងនៅក្នុងសមាជប្រជាជនកម្ពុជាឆ្នាំ២០១៥ ដែលមានអ្នកចូលរួមប្រមាណជា១៣០០នាក់។

(១) ខ្វះខាតអង្ករសម្រាប់បរិភោគ ឬប្រើប្រាស់សម្រាប់ចិញ្ចឹមជីវិត៖ កសិករដែលមានដីតូចទទួលបានកសិផលតិចតួច មិនគ្រប់គ្រាន់សម្រាប់បរិភោគ និងយកទៅប្រើប្រាស់សម្រាប់ចិញ្ចឹមជីវិតឡើយ។

(២) តម្លៃស្រូវ៖ កសិករដែលផលិតស្រូវសម្រាប់លក់ជាលក្ខណៈអាជីវកម្ម និង ផលិតស្រូវសម្រាប់បរិភោគ និងលក់ខ្លះដើម្បីដោះស្រាយជីវភាពគ្រួសារ លក់កសិផលរបស់ខ្លួននៅក្នុងតម្លៃទាប។ តម្លៃគឺកំណត់ដោយឈ្មួញកណ្តាល។

(៣) កើនបំណុល៖ កសិករខ្ចីកម្ចីច្រើនជាងមុន ដើម្បីមកធ្វើជាទុនសម្រាប់ចំណាយលើការធ្វើកសិកម្ម និងចំណាយលើតម្រូវការចាំបាច់ផ្សេងៗ សម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃ។

[1] សេចក្តីព្រៀងច្បាប់ដឹកសិកម្មនេះរៀបចំតាក់តែងដោយអគ្គនាយកដ្ឋានកសិកម្ម ក្រោមការគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដែលនឹងត្រូវបានរៀបចំឡើងក្នុងគោលបំណងគ្រប់គ្រងដឹកសិកម្ម និងគាំទ្រដល់គោលនយោបាយ និងផែនការក្នុងការជំរុញផលិតកម្មស្រូវ និងការនាំអង្ករចេញ។ សេចក្តីព្រៀងច្បាប់ដឹកសិកម្មលើកទី៦ បានរៀបចំឡើងនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៦។

(៤) ការពឹងផ្អែកលើប្រភេទពូជស្រូវថ្មីឬទំនើបថ្មីៗ (ពូជបង្កាត់ ឬពូជចិញ្ចឹម ជាភាសាដែលកសិករប្រើប្រាស់)៖ កសិករត្រូវចំណាយទិញពូជស្រូវទំនើបថ្មីសម្រាប់ធ្វើស្រែជារៀងរាល់ឆ្នាំ ឬរាល់២ទៅ៣ឆ្នាំម្តងដោយសារតែជាទូទៅពូជទាំងនោះអោយផលខ្ពស់នៅឆ្នាំដំបូង ឬឆ្នាំទី១ ហើយបន្តធ្លាក់ទិន្នផលជាបន្តបន្ទាប់ ឬមិនដុះ និងពិបាកទុកពូជ ។ ការទុកពូជ សម្រាប់ដាំដុះប្រមូលផលគឺបានត្រឹមតែចន្លោះពីពីរទៅបីឆ្នាំប៉ុណ្ណោះ។ ពូជទំនើបថ្មីៗទាំងនោះ មិនអាចរក្សាទុកសម្រាប់ដាំដុះបានយូរអង្វែង តជំនាន់ ឬរហូតនោះទេ ហើយឆាប់ក្លាយ និង មានជម្ងឺច្រើន ទាក់ទាញសត្វល្អិត និង មិនធន់នឹងអាកាសធាតុ។

(៥) កំណើននៃការប្រើប្រាស់ជីគីមី និងថ្នាំពុលសម្លាប់សត្វល្អិត៖ ការដាំដុះពូជថ្មី និងដើម្បីបង្កើនបរិមាណទិន្នផលស្រូវនិងពន្លឿនអោយស្រូវឆាប់ផ្តល់ទិន្នផល អោយឆ្លើយតបទៅនឹងតម្រូវការទីផ្សារ និងគុណភាពដែលកំណត់ដោយឈ្មួញកណ្តាលនោះ កសិករបានប្រើប្រាស់នូវជីគីមី និងថ្នាំពុលសម្លាប់សត្វល្អិត ក្នុងការថែទាំដំណាំស្រូវរបស់ពួកគាត់។ ការប្រើប្រាស់នេះមានសន្ទុះកើនឡើងដ៏គួរឲ្យកត់សម្គាល់ ដែលនេះធ្វើឲ្យមានការប៉ះពាល់យ៉ាងខ្លាំងដល់ជីវជាតិដី ប្រព័ន្ធជីវៈចម្រុះ និងសុខភាព។ ទន្ទឹមនឹងនោះ ការប្រើប្រាស់ពូជទំនើបថ្មី គឺតម្រូវអោយកសិករប្រើប្រាស់ជីគីមីផងដែរ។

ហេតុដូចនេះហើយ ការស្រាវជ្រាវធ្វើឡើងដើម្បីសិក្សាមើល ថាតើបញ្ហាដែលបានលើកឡើងខាងលើដោយកសិករ ពិតជាកើតមានពិតជាក់ស្តែងមែនដែរឬទេ ចំពោះកសិករខ្នាតតូច និងមធ្យម? ជាពិសេសមើលទៅលើបញ្ហាដែលមានមកលើអធិបតេយ្យស្បៀង សន្តិសុខស្បៀង សុវត្ថិភាពស្បៀងនិងសេដ្ឋកិច្ចរបស់កសិករ។

ចំពោះពាក្យគន្លឹះសំខាន់ៗ ដែលបានប្រើប្រាស់នៅក្នុងការសិក្សានេះវិញ មានដូចជាកសិករខ្នាតតូចនិងមធ្យម ប្រព័ន្ធផលិតកម្មបែបប្រពៃណី ប្រព័ន្ធផលិតកម្មបែបទំនើប ពូជស្រូវបុរាណឬប្រពៃណី ពូជស្រូវទំនើបថ្មី អធិបតេយ្យស្បៀង សន្តិសុខស្បៀង និងសុវត្ថិភាពស្បៀង។ អត្ថន័យនៃពាក្យគន្លឹះនីមួយៗ ដែលកំណត់យកសម្រាប់ឯកសារនេះ មានដូចតទៅ៖

- កសិករខ្នាតតូច និងមធ្យម៖
    - តាមការកំណត់និយមន័យដោយកសិករដែលជាសមាជិកនៅក្នុងក្រុមសិក្សាស្រាវជ្រាវនេះ កសិករខ្នាតតូចគឺសំដៅលើគ្រួសារកសិករ ដែលកំពុងតែប្រកបមុខរបរធ្វើស្រែបែបគ្រួសារ និងមានទំហំដីស្រែប្រចាំគ្រួសារក្រោម២ហិកតា។

ដោយឡែក ការកំណត់និយមន័យនៃកសិករខ្នាតតូចដែលបានដកស្រង់ចេញពី យុទ្ធសាស្ត្រថ្មីសម្រាប់ការអភិវឌ្ឍជនបទ ស្តីពី ការពង្រីកទៅកាន់ប្រជាជនក្រីក្រនៅជនបទ (ឆ្នាំ ២០០៣) ដោយធនាគារពិភពលោក កសិករខ្នាតតូច គឺសំដៅទៅលើកសិករដែលមានធនធានតិចតួច ធ្វើស្រែ ឬកសិកម្មនៅលើដីតូចជាងឬស្មើនឹង ២ហិកតា។

- កសិករខ្នាតមធ្យម គឺសំដៅទៅលើកសិករដែលកំពុងប្រកបរបរធ្វើស្រែទាំងសម្រាប់ផ្គត់ផ្គង់គ្រួសារ និង សម្រាប់លក់ ហើយមានទំហំដីចន្លោះពី២ទៅ៥ហិកតា។ និយមន័យនេះ ក៏ត្រូវបានកំណត់ឡើងដោយកសិករដែលចូលរួមក្នុងការសិក្សាផងដែរ ដោយយោងទៅតាមបទពិសោធន៍របស់កសិករ ទៅលើជីវភាពជាក់ស្តែងរបស់កសិករ។ ក្រុមស្រាវជ្រាវ មិនអាចរកបាននូវការកំណត់ជាក់លាក់ជាផ្លូវការដោយរដ្ឋាភិបាលឬស្ថាប័នពាក់ពន្ធ័ណាមួយទៅលើនិយមន័យនេះនៅឡើយ។

- ប្រព័ន្ធផលិតកម្មបែបប្រពៃណី៖ គឺសំដៅទៅលើវិធីសាស្ត្រ និងបច្ចេកទេសធ្វើស្រែ និងការប្រើប្រាស់ធាតុចូល និងសម្ភារៈរួមមានការប្រើប្រាស់នូវឧបករណ៍បុរាណៗដូចជារនាស់ នង្គ័ល កណ្តៀវ និងប្រើកំលាំងសត្វពាហនៈសម្រាប់អូសទាញដូចជា គោ និងក្របីជាដើម ដោយមិនបានប្រើប្រាស់នូវគ្រឿងម៉ាស៊ីន ឬគ្រឿងចក្រ។ មានការពឹងផ្អែកទៅលើធម្មជាតិដូចជាទឹកភ្លៀង និងប្រព័ន្ធស្រោចស្រព ឬធារាសាស្ត្រដែលបានរៀបចំឡើងដូចជាប្រឡាយទឹក ព្រែកជីក ស្រះ បឹងបួ ស្ទឹង ទន្លេជាដើម និង ពិសេសនោះ គឺមានការប្រើប្រាស់នូវពូជប្រពៃណី ធាតុចូលធម្មជាតិឬសរីរាង្គ ដូចជាជីធម្មជាតិជាដើម។
- ប្រព័ន្ធផលិតកម្មបែបទំនើប៖ គឺសំដៅទៅលើវិធីសាស្ត្រ បច្ចេកទេសធ្វើស្រែ និងការប្រើប្រាស់ធាតុចូល និងសម្ភារៈកសិកម្មដូចជាការប្រើប្រាស់គ្រឿងចក្រ ឬម៉ាស៊ីនជំនួសអោយសត្វគោ ក្របី និងប្រើប្រាស់នូវពូជទំនើបថ្មី និង ធាតុចូលរួមមានសារធាតុគីមីដូចជាជីគីមី និងថ្នាំពុលគីមីជាដើម។
- ពូជស្រូវបុរាណ ឬពូជស្រូវប្រពៃណី៖ គឺជាប្រភេទពូជស្រូវទាំងឡាយណាដែលអាចរក្សាទុកសម្រាប់ដាំដុះបានតជំនាន់ ពីមួយជំនាន់ទៅមួយជំនាន់ដោយកសិករខ្មែរ និងបន្សល់ទុកពីដើមមកដោយកសិករខ្លួនឯង។
- ពូជស្រូវទំនើបថ្មី (ពូជបង្កាត់ ឬពូជចិញ្ចឹម ភាសាដែលកសិករប្រើប្រាស់)៖ គឺជាប្រភេទពូជស្រូវទាំងឡាយណាដែលត្រូវបានអភិវឌ្ឍថ្មីដោយឆ្លងកាត់ការបង្កាត់ពូជចេញពីស្រូវពីរ ឬ

ច្រើនប្រភេទផ្សេងៗគ្នា។ ពូជស្រូវទំនើបថ្មីមិនមែនជាពូជស្រូវប្រពៃណីឡើយ។ ពូជស្រូវទំនើបថ្មី គឺជាប្រភេទពូជថ្មីនៃដំណាំផងដែរ។ នៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ ពូជថ្មីនៃដំណាំសំដៅទៅលើពូជដំណាំទាំងឡាយ ដែលទើបនិងរកឃើញ និង អភិវឌ្ឍន៍ថ្មីៗ ដោយរុក្ខជម្រើសវិទូ ឬអ្នកបង្កាត់ពូជដំណាំ និងកាន់កាប់ផ្តាច់មុខយ៉ាងទូលំទូលាយក្នុងរយៈពេលមួយជាក់លាក់។

- ស្បៀង៖ តាមវចនានុក្រមខ្មែរ ដែលចងក្រងដោយសម្តេចសង្ឃ ជួន ណាត ស្បៀងគឺជាគ្រឿងបរិភោគចិញ្ចឹមជីវិត។
- អធិបតេយ្យស្បៀង៖ មានពីរនិយមន័យដែលយើងអាចសិក្សាបាននៅទីនេះ៖

១. បើយោងទៅតាម ចលនាកសិករ ឡាវៀខេមផេស៊ីណា (Lavia Campesina)[2] អធិបតេយ្យស្បៀងគឺជា គឺជាសិទ្ធិរបស់ប្រជាជន ប្រទេស ឬ រដ្ឋ ក្នុងការកំណត់គោលនយោបាយកសិកម្មនិងស្បៀងរបស់ពួកគេ ដោយមិនមានការបន្ថោកតម្លៃទៅវិញទៅមកទៅលើប្រទេសទីពឡើយ។ អធិបតេយ្យស្បៀងរួមមាន៖

- កំណត់អាទិភាពចំពោះការផលិតផលិតផលកសិកម្មក្នុងស្រុក សម្រាប់ចិញ្ចឹមផ្គត់ផ្គង់ប្រជាជន ហើយកសិករ និង ប្រជាជនដែលគ្មានដីទទួលបានដីធ្លី ទឹក គ្រាប់ពូជ និងឥណទាន។ ដូចនេះ វាត្រូវការអោយមាននូវកំណែទម្រង់ដីធ្លី ការទទួលបានគ្រាប់ពូជដោយមិនបង់ប្រាក់ ការថែទាំការពារធនធានទឹកជាសម្បត្តិសាធារណៈដើម្បីចែកចាយធនធានទឹកដោយនិរន្តរភាព និង ការប្រឆាំងទៅនឹងសរីរាង្គបំលែងសេនេទិច (GMOs)។
- សិទ្ធិរបស់កសិករ ក្នុងការផលិតស្បៀង និង សិទ្ធិរបស់អ្នកប្រើប្រាស់ក្នុងការសម្រេចចិត្តទៅលើអ្វីដែលគេត្រូវទិញនិងប្រើប្រាស់ ហើយគេអាចសម្រេចចិត្តបានថា តើរបស់នោះគួរត្រូវបានផលិតឡើងដោយរបៀបណា និង ដោយនរណា។
- សិទ្ធិរបស់ប្រទេសក្នុងការការពារខ្លួនពី ផលិតផលកសិកម្មនិងទំនិញកសិកម្មដែលនាំចូល ដែលមានតម្លៃថោក។ តម្លៃផលិតផលកសិកម្ម គឺផ្សារភ្ជាប់ទៅនឹងថ្លៃដើម ហើយការគ្រប់គ្រងតម្លៃអាចធ្វើទៅបានប្រសិនបើរដ្ឋមានសិទ្ធិក្នុងការកំណត់ពន្ធទៅលើទំនិញនាំចូលដែលមានតម្លៃថោកខ្លាំង ហើយនឹងនៅពេលដែលរដ្ឋប្តេជ្ញាចិត្តក្នុងការគាំទ្រទៅ

2 ឡាវៀ ខេមផេស៊ីណា (Lavia Campesina), ទាញចេញពីគេហទំព័រ៖ https://viacampesina.org/en/food-sovereignty/

ដល់ផលិតកម្មកសិកម្មប្រកបដោយនិរន្តរភាព និង នៅពេលដែលរដ្ឋគ្រប់គ្រងការផលិតនៅក្នុងទីផ្សារក្នុងប្រទេស ដើម្បីជៀសវាងការផលិតលើស។

- ប្រជាជនចូលរួមក្នុងការជ្រើសរើសគោលនយោបាយកសិកម្ម។
- ការទទួលស្គាល់នូវសិទ្ធិរបស់កសិករស្ត្រី ដែលមានតួនាទីចូលរួមចំណែកដ៏សំខាន់ក្នុងការផលិតស្បៀង និង ផលិតកម្មកសិកម្ម។

២. បើតាមការកំណត់ដោយកសិករសមាជិកបណ្ដាញពហុវិស័យ និង សមាជិកកសិករចូលរួមក្នុងដំណើរការសិក្សាស្រាវជ្រាវនេះ៖ អធិបតេយ្យស្បៀង គឺជាសិទ្ធិរបស់កសិករ ក្នុងការកំណត់គោលនយោបាយកសិកម្មរបស់ខ្លួន ការពារនិងគ្រប់គ្រងផលិតកម្មកសិកម្មក្នុងស្រុក (រួមមានដីគ្រាប់ពូជ ធាតុចូលកសិកម្ម បច្ចេកទេស...) និងទីផ្សារ និង តម្លៃកសិផលក្នុងស្រុក ដើម្បីសម្រេចបាននូវការអភិវឌ្ឍន៍ប្រកបដោយនិរន្តភាព។

- សន្តិសុខស្បៀង៖ គឺសំដៅទៅលើការផ្គត់ផ្គង់ស្បៀងគ្រប់គ្រាន់ និងថ្លៃស្បៀងដែលស្ថិតនៅក្នុងកម្រិតដែលប្រជាជនមានលទ្ធភាពទិញបាន[3]។ បើយោងតាមសៀវភៅយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ឆ្នាំ២០១៤-២០១៨ (ទំព័រ១១) ពាក្យថាសន្តិសុខស្បៀងចែកចេញជាបីកម្រិតគឺ៖
    - សន្តិសុខស្បៀងកម្រិតថ្នាក់ជាតិ៖ គឺសំដៅទៅលើស្ថានភាពមួយដែលស្បៀងនៅកម្រិតថ្នាក់ជាតិ មានចំនួនគ្រប់គ្រាន់សម្រាប់តម្រូវការរបស់ប្រជាពលរដ្ឋនៅក្នុងពេលណាមួយ។ វាអាចមានប្រភពមកពីការផលិតស្បៀងអាហារដោយខ្លួនឯង ការនាំចូល ឬក៏ទាំងពីរនេះ)
    - សន្តិសុខស្បៀងកម្រិតគ្រួសារ៖ គឺនៅពេលណាដែលគ្រួសារមួយ មានលទ្ធភាពទទួលបានស្បៀងអាហារគ្រប់គ្រាន់ ដែលចាំបាច់សម្រាប់សមាជិកគ្រួសារទាំងអស់ ដើម្បីរស់បានប្រកបដោយសុខភាពល្អ។
    - សន្តិសុខស្បៀងកម្រិតបុគ្គល៖ គឺសំដៅទៅលើការបែងចែកស្បៀងអាហារសមស្របនៅក្នុងគ្រួសារ និងការដែលអាចស្រូបយក និងប្រើប្រាស់ស្បៀងអាហារឲ្យបានត្រឹមត្រូវ និងប្រកប ដោយអាហារូបត្ថម្ភ ទៅតាមតម្រូវការរាងកាយ និងលក្ខខ័ណ្ឌសុខភាពរបស់បុគ្គលម្នាក់ៗ។

[3] «សេដ្ឋកិច្ចកម្ពុជា៖ មាគ៌ាឆ្ពោះទៅរកអនាគតដ៏ភ្លឺស្វាង៖ វឌ្ឍនភាព បញ្ហាប្រឈម និង ទស្សនវិស័យទៅអនាគត» បោះពុម្ពផ្សាយនៅភ្នំពេញ ឆ្នាំ២០១៥ ដោយបណ្ឌិត ហាង់ ជួន ណារ៉ុន។ ជំពូក ៧៖ វិស័យកសិកម្ម ទំព័រ១៨៥។

ជាបន្ថែមនោះ សន្តិសុខស្បៀង កើតឡើងនៅពេលដែលប្រជាជនទាំងអស់ ទទួលបាននូវអាហារគ្រប់គ្រាន់ អាហារដែលមានអាហារូបត្ថម្ភ និង មានសុវត្ថិភាព ដែលបំពេញនូវតម្រូវការរបបអាហារ និង ចំណង់ចំណូលចិត្តអាហារសម្រាប់ជីវិតដ៏មានសុខភាព និង ប្រកបដោយភាពរស់រវើកនៅគ្រប់ពេលវេលា គ្រប់កាលៈទេសៈ״ (ដកស្រង់ចេញពី កិច្ចប្រជុំកំពូល ស្តីពីស្បៀងអាហារពិភពលោក ឆ្នាំ១៩៩៦ និង ឯកសារសង្ខេបគោលនយោបាយដោយ អង្គការស្បៀង និង កសិកម្មនៃអង្គការសហប្រជាជាតិ-FAO, ការចេញផ្សាយលេខ២ ខែមិថុនា ឆ្នាំ២០០៦)

- សុវត្ថិភាពៈ សំដៅទៅដល់ស្ថានភាពដែលគ្មានគ្រោះថ្នាក់ ឬដែលអាចបញ្ចៀសបាននូវគ្រោះថ្នាក់ចំពោះមនុស្ស សត្វ និងបរិស្ថាន ដោយផ្ទាល់ ឬដោយប្រយោល រយៈពេលខ្លី ឬយូរអង្វែងដែលបង្កឡើងដោយថ្នាំកសិកម្ម ឬជីកសិកម្មនៅក្នុងគ្រប់សកម្មភាពដែលពាក់ពន្ធ័ក្នុងវដ្តនៃផលិតផលនេះ ដែលត្រូវគ្រប់គ្រងដោយវិធានសុវត្ថិភាពដូចមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម។

## ២. សេចក្តីសង្ខេបរបកគំហើញសំខាន់ៗ

ការសិក្សាស្រាវជ្រាវនេះ ត្រូវបានធ្វើឡើងនៅក្នុងខេត្តចំនួនប្រាំនៃប្រទេសកម្ពុជា គឺខេត្តព្រៃវែង តាកែវ កំពង់ឆ្នាំង កំពង់ធំ និងបាត់ដំបង និងធ្វើការសាកល្បងកម្រងសំណួរនៅខេត្តកំពត។ ក្រុមស្រាវជ្រាវបានចុះប្រមូលព័ត៌មានតាមរយៈការសម្ភាសនៅក្នុងស្រុកចំនួន ៩ ឃុំចំនួន១០ និងភូមិចំនួន១៥ ដោយសម្ភាសន៍កសិករមកពី១០១គ្រួសារផ្សេងៗគ្នា ក្នុងនោះមានស្រីចំនួន៥៥នាក់ ព្រមទាំងមានការពិភាក្សាក្រុមចំនួន៣ក្រុមផងដែរ (កសិករវ័យកណ្តាល អាយុចាប់ពី២៥ទៅ៤៥ឆ្នាំចំនួន១ក្រុម ក្រុមកសិករវ័យចំណាស់ អាយុចាប់ពី៤៥ទៅ៩០ឆ្នាំចំនួនពីរក្រុម) និង សម្ភាសន៍កសិករដែលជាអ្នកផលិតពូជទំនើបថ្មីសម្រាប់ចែកចាយចំនួន៨នាក់។ ខាងក្រោម នេះគឺជារបកគំហើញសំខាន់ៗដែលទទួលបានពីការសិក្សាស្រាវជ្រាវនេះ។

ក្នុងកំឡុងពេលជាងពីរទសវត្សចុងក្រោយនេះ របៀបនៃការធ្វើកសិកម្មដំណាំស្រូវរបស់កសិករមានការប្រែប្រួលយ៉ាងខ្លាំង ដោយផ្លាស់ប្តូរពីបច្ចេកទេសក្នុងការដាំស្រូវបែបប្រពៃណីមកបែបទំនើបនិងមានលក្ខណៈពាណិជ្ជកម្ម។ កសិករស្ទើរតែទាំងអស់ (៩៥%) នៃអ្នកផ្តល់បទសម្ភាសន៍កំពុងផ្លាស់ប្តូរ និងងាកមកប្រើប្រាស់នូវពូជស្រូវទំនើបឬពូជស្រូវថ្មី (ដែលអត្រានៃការប្រើប្រាស់ពូជថ្មីនេះមានការកើនឡើង៨២%ប្រសិនបើធៀបទៅនឹងចំនួនកសិករដែលប្រើប្រាស់ពូជថ្មីកាលពី១៥ទៅ២០ឆ្នាំមុន)។ កសិករបន្ថែមរដូវ ឬវដ្តដាំដុះពី១ដងទៅដល់៣ដងក្នុងមួយឆ្នាំ ដែលនេះតម្រូវអោយមានការកើនឡើងនូវតម្រូវការនៃការប្រើប្រាស់ទឹក ធនធាន និងធាតុចូលកសិកម្មជាច្រើនរូ

មមានទាំងជី និងថ្នាំកសិកម្មទៀតផងដែរ។ កសិករពឹងផ្អែកកាន់តែខ្លាំងទៅលើគ្រឿងចក្រសម្រាប់ជាប្រភពកំលាំងដ៏សំខាន់សម្រាប់ផលិតកម្មស្រូវនិងការប្រមូលទិន្នផល។ កសិករពឹងផ្អែកកាន់តែខ្លាំងបន្ថែមទៀតទៅលើជីគីមី និងថ្នាំពុលកសិកម្ម។ ការប្រែប្រួលនៃការអនុវត្តរបៀបធ្វើកសិកម្មនេះ ធ្វើអោយកសិករបង្កើនចំណាយកាន់តែខ្លាំង។ តាមកាសិក្សាស្រាវជ្រាវនេះ ៥០%នៃកសិករដែលចូលរួមផ្តល់សម្ភាសន៍ចំនួន៥២នាក់ គឺបានប្រើប្រាស់កម្ចីពីស្ថាប័នមីក្រូហិរញ្ញវត្ថុ និងក្រុមសន្សំសហគមន៍ជាមួយនឹងអត្រាការប្រាក់ខ្ពស់ចាប់ពី១.២ ទៅ ៤% ក្នុងមួយខែ ដើម្បីចំណាយទៅលើការផលិតស្រូវរបស់ពួកគាត់។ កត្តាចំបងៗក្នុងចំណោមកត្តាផ្សេងៗដែលបណ្តាលអោយមានការប្រែប្រួលទៅលើរបៀបនៃការធ្វើកសិកម្មស្រូវរបស់កសិករនេះ រួមមានដូចខាងក្រោម៖

- រដ្ឋាភិបាល តាមរយៈក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្ម បានស្រាវជ្រាវ និងអភិវឌ្ឍន៍នូវពូជដំណាំថ្មីរួមមានទាំងស្រូវស្រាលសម្រាប់ដាំដុះក្នុងរយៈពេលខ្លី និងស្រូវធ្ងន់សម្រាប់រយៈពេលវែង។ ភាគច្រើននៃពូជស្រូវថ្មីទាំងអស់នេះ ត្រូវបានផ្សព្វផ្សាយ និងលើកកំពស់ក្នុងការដាំដុះដោយរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលទាំងក្នុងស្រុក និងអន្តរជាតិមួយចំនួន រួមជាមួយនឹងការបង្ហាត់បង្រៀនបច្ចេកទេសដាំដុះទៅដល់កសិករ (ពិសេសសហគមន៍កសិកម្មនិងសមាជិក) សម្រាប់បង្កើនផលិតកម្មស្រូវ និងគាំទ្រដល់គោលបំណងក្នុងការនាំអង្ករចេញទៅទីផ្សារអន្តរជាតិ។ គោលបំណង និងការជម្រុញនេះ មានចែងច្បាស់នៅក្នុងផែនការសកម្មភាពសម្រាប់ការអនុវត្តគោលនយោបាយជម្រុញផលិតកម្មស្រូវ និងអង្ករសម្រាប់នាំចេញ។ បន្ថែមទៅលើការផ្សព្វផ្សាយដោយរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ពូជថ្មីមួយចំនួនត្រូវបានធ្វើពាណិជ្ជកម្ម ចរាចរលក់នៅលើទីផ្សារក្នុងស្រុកយ៉ាងទូលំទូលាយដោយឈ្មួញឯកជន។ នេះបង្កអោយកសិករទទួលរងការទាក់ទាញអោយប្រើប្រាស់ពូជថ្មីបានយ៉ាងងាយដោយអ្នកផ្សព្វផ្សាយលក់ពូជឯកជន និងងាយស្រួលដល់កសិករក្នុងការទិញពូជទាំងនេះដើម្បីសាកល្បងដាំដុះ និងប្រើប្រាស់ផងដែរ។
- ដោយសារតែពូជថ្មីមានគុណសម្បត្តិមួយចំនួនដូចជា ផ្តល់ផលលឿន (៣ទៅ៤ខែ) និងមានតម្រូវការទីផ្សារអន្តរជាតិ កសិករចាប់ផ្តើម និងផ្តោតកាន់តែខ្លាំងឡើងក្នុងការប្រើប្រាស់ពូជថ្មីទាំងនេះ ជំនួសអោយពូជប្រពៃណីដែលពួកគាត់ធ្លាប់ដាំដុះកន្លងមក។

ពូជទំនើបថ្មីផ្តល់ផលពិបាកដល់កសិករ និងធ្វើអោយប៉ះពាល់ដល់អធិបតេយ្យរបស់កសិករទៅលើស្បៀងអាហារពិសេសគឺអធិបតេយ្យទៅលើគ្រាប់ពូជ ហើយនៅក្នុងរយៈពេលវែងទៅថ្ងៃមុខនិងមានផលប៉ះពាល់ខ្លាំងមកលើសន្តិសុខស្បៀងរបស់កសិករ។ កសិករបាត់បង់នូវភាពជាម្ចាស់និងអំណាចក្នុងការគ្រប់គ្រងពូជស្រូវរបស់ពួកគាត់ ហើយពឹងផ្អែកកាន់តែខ្លាំងឡើងទៅលើពូជថ្មីដែលគ្រប់គ្រងដោយអ្នកអភិវឌ្ឍន៍ពូជ ឬ អ្នកផលិតពូជស្រូវសម្រាប់លក់។ នេះដោយសារតែ ទី១ នោះ គឺ គ្រាប់ពូជស្រូវថ្មីមិនអាចទុកពូជបានយូរឬច្រើនជំនាន់ឡើយ។ កសិករត្រូវទិញ ឬប្តូរពូជថ្មីជារៀងរាល់ឆ្នាំ ឬពីពីរទៅបីឆ្នាំម្តង។ ទីពីរ គឺ ទោះបីជាពូជថ្មីផ្តល់ផលបានខ្ពស់រហូតដល់៥តោនក្នុងមួយហិកតា វាផ្តល់ផលខ្ពស់បែបនេះបានត្រឹមតែឆ្នាំដំបូងប៉ុណ្ណោះ។ ពូជថ្មីនេះនឹងបន្តធ្លាក់ទិន្នផលនៅឆ្នាំទី២ ឬទី៣ ហើយវាក្លាយ បាត់បង់គុណភាព និងបន្តធ្លាក់ផលរហូតដល់សូន្យ។ ក្នុងករណីជាច្រើន គឺវាមិនដុះតែម្តងបន្ទាប់ពីឆ្នាំទី១។ ពូជថ្មី មានជំងឺច្រើន និងទាក់ទាញសត្វល្អិតចង្រៃ ហើយនេះបង្កផលពិបាកដល់កសិករក្នុងការថែទាំស្រូវ និងត្រូវចំណាយថវិការច្រើនទៅលើជីគីមី និង ថ្នាំពុលគីមី។

ចំនួននៃពូជប្រពៃណីបានបាត់បង់ច្រើន។ តាមការសិក្សាស្រាវជ្រាវនៅក្នុងខេត្តទាំងប្រាំ បានបង្ហាញថា មានពូជប្រពៃណីចំនួនរហូតដល់៣០ទៅ៥០មុខនៅក្នុងខេត្តនីមួយៗដែលកសិករបានប្រើប្រាស់កន្លងមក (រួមមានពូជស្រូវស្រាលសម្រាប់ការដាំដុះរយៈពេលខ្លី ស្រូវកណ្តាល និង ស្រូវធ្ងន់) ប៉ុន្តែពូជមួយចំនួនធំបានបាត់បង់ហើយ ដែលបច្ចុប្បន្ននេះ មានប្រហែលជា១០ទៅ១៥មុខប៉ុណ្ណោះនៅក្នុងខេត្តនីមួយៗដែលកសិករនៅប្រើប្រាស់។ ពូជប្រពៃណីទាំងនេះនឹងបន្តបាត់បង់នៅពេលអនាគត ប្រសិនបើកសិករឈប់ប្រើប្រាស់វា ហើយនៅតែបន្តពឹងផ្អែកខ្លាំងមកលើពូជថ្មី។ ខុសពីពូជទំនើបថ្មី ពូជប្រពៃណីមានអត្ថប្រយោជន៍ជាច្រើនដូចជា អាចរក្សាទុកបានយូរដោយកសិករខ្លួនឯង និងមិនមានជំងឺ ឬមានជំងឺតិចតួច។ លើសពីនេះទៅទៀតនោះ ពូជប្រពៃណី មិនចាំបាច់ ឬតម្រូវអោយប្រើប្រាស់ជីគីមីឡើយ នេះបើយោងទៅតាមបទពិសោធន៍របស់កសិករដែលចូលរួមផ្តល់បទសម្ភាសន៍ ពិសេស គឺក្រុមកសិករវ័យចំណាស់ ដែលមានបទពិសោធប្រើប្រាស់ពូជប្រពៃណី និង ការធ្វើស្រែបែបធម្មជាតិពីមុនមក។ កសិករក៏មិនចាំបាច់ត្រូវចំណាយថវិការដើម្បីទិញពូជឬប្តូរពូជជារៀងរាល់ឆ្នាំឡើយ។

ដីស្រែគឺជាជីវិតរបស់កសិករ។ នៅពេលដែលដីខ្សោះជីជាតិ និងសឹករិចរិល ដីនោះនឹងមិនអាចមានសមត្ថភាពក្នុងការផលិតស្បៀងបានទៀតឡើយ ហើយនេះនឹងបង្កផលប៉ះពាល់ខ្លាំងមកលើសន្តិសុខស្បៀងរបស់កសិករ។ ការប្រើប្រាស់ជីគីមី បង្កអោយកសិករចំណាយថវិកាច្រើន និងផ្តល់បញ្ហាជាច្រើនផងដែរ។ តាមបទពិសោធជាក់ស្តែងរបស់កសិករ ជីគីមីបណ្តាលអោយដីស្រែរឹង ខ្សោះជីជាតិ មិនអាចអោយស្រូវដុះលូតលាស់ល្អ។ ជីគីមី ក៏ផ្តល់ផលប៉ះពាល់មកលើជីវិតជីវៈចម្រុះ និង ប្រព័ន្ធអេកូឡូស៊ីដែលនៅជុំវិញដីស្រែទាំងនោះផងដែរ។ ជាពិសេសនោះ គឺការប្រើប្រាស់ថ្នាំពុលគីមីតែម្តង ដែលវាប៉ះពាល់យ៉ាងខ្លាំងមកលើសុខភាពរបស់កសិករ និងអ្នកបរិភោគ។ នៅកំឡុងពេល១០ឆ្នាំចុងក្រោយនេះ កសិករសង្កេតឃើញថា មានការបាត់បង់ខ្លាំងនូវកូនរុក្ខជាតិមានប្រយោជន៍ដែលដុះក្នុងស្រែ និងពពួកសត្វ និងជីវិតតូចៗនៅក្នុងស្រែដូចជាកូនត្រីជាដើម។ នេះបណ្តាលមកពីជីគីមី និងថ្នាំពុលគីមី។

ស្ទើរតែទាំងអស់នៃកសិករដែលចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះ ចង់ត្រឡប់ទៅអនុវត្តការធ្វើកសិកម្មបែបប្រពៃណីវិញ ប៉ុន្តែវាហាក់បីដូចជានៅមានឧបសគ្គច្រើនសម្រាប់ពួកគាត់ ដោយសារតែ ទី១ គឺពួកគាត់ត្រូវដាំដើម្បីតម្រូវទៅតាមទីផ្សារ ដូចនេះ ពួកគាត់ត្រូវបន្តដាំពូជថ្មី។ លើសពីនេះទៅទៀតនោះគឺ ពូជប្រពៃណីមួយចំនួនត្រូវបានបាត់បង់ទៅហើយ ដូចនេះវាពិបាកបន្តិចសម្រាប់ពួកគាត់ក្នុងការទៅរកពូជទាំងនោះមកវិញ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ កសិករមួយចំនួនគឺនៅប្រើប្រាស់ពូជប្រពៃណី ហើយពួកគេនឹងបន្តប្រើប្រាស់ពូជទាំងនេះ។ ទី២ ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារ កសិករត្រូវផលិតស្រូវអោយបានឆាប់រហ័ស ដូចនេះពួកគេត្រូវតែពឹងផ្អែកទៅលើគ្រឿងចក្រ។ តែមានកសិករមួយចំនួនបានពិចារណាក្នុងការកាត់បន្ថយការប្រើប្រាស់គ្រឿងចក្រផងដែរដើម្បីកាត់បន្ថយការចំណាយ។ ទី៣ គឺដោយសារតែកសិករបច្ចុប្បន្ន ប្រើប្រាស់គ្រឿងចក្រច្រើន និងបន្ថយការចិញ្ចឹមសត្វគោ ក្របីនៅតាមគ្រួសារ នោះបណ្តាលអោយកសិករខ្វះលាមកគោ ក្របីសម្រាប់ប្រើប្រាស់ជាជីធម្មជាតិ។

## ៣. សេចក្តីសង្ខេបអំពីស្ថានភាពកសិកម្មដំណាំស្រូវនៅកម្ពុជា

កម្ពុជាគឺជាប្រទេសកសិកម្មមួយនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលមានប្រជាជន ៨៥% រស់នៅក្នុងតំបន់ជនបទ ហើយ ៦០% នៃប្រជាជនទាំងនេះប្រកបរបរកសិកម្មដើម្បីចិញ្ចឹមជីវិត ក្នុងនោះមេគ្រួសារនៃគ្រួសារក្រីក្រជាកសិករមានរហូតដល់ទៅ ៧៥%[4] ។

វិស័យកសិកម្ម ជាពិសេសផលិតកម្មស្រូវ និងការចិញ្ចឹមសត្វ បានរួមចំណែកយ៉ាងសំខាន់នៅក្នុងកំណើននៃផលិតផលក្នុងស្រុកសរុប ឬអក្សរកាត់ជាភាសាអង់គ្លេស(GDP) ដែលមានចំនួនរហូតដល់ ២៦%[5] ក្នុងឆ្នាំ២០១៦។ នេះគឺជាការរួមចំណែកដ៏សំខាន់មួយទៅលើកំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាទាំងមូល ដែលបានកើនឡើងជាបន្តបន្ទាប់ជាប់ៗគ្នា នៅក្នុងអំឡុងពេលជាងមួយទសវត្សរកន្លងទៅនេះ។ រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកវិស័យកសិកម្ម ជាយុទ្ធសាស្ត្រមួយក្នុងការកាត់បន្ថយភាពក្រីក្រនៅក្នុងសហគមន៍ជនបទ ធានាឲ្យបាននូវសន្តិសុខស្បៀង និងទ្រទ្រង់កំណើនសេដ្ឋកិច្ច។

ស្របពេលគ្នានេះដែរ ប្រព័ន្ធបច្ចេកវិទ្យាទំនើបៗសម្រាប់ការធ្វើកសិកម្ម ក៏បាននាំចូលមកដល់ប្រទេសកម្ពុជា ក្នុងនោះមានដូចជា គោយន្ត ម៉ាស៊ីនបោកស្រូវ ម៉ាស៊ីនច្រូតស្រូវ ម៉ាស៊ីនកិនស្រូវ និងម៉ាស៊ីនរែងអង្កាមជាដើម ដើម្បីជាជំនួយដល់ការធ្វើស្រែរបស់ពួកគាត់។ នេះជាកត្តាជំរុញមួយដល់កសិករ ឲ្យជ្រើសរើសនូវជម្រើសនេះ ដើម្បីបំពេញនូវតម្រូវការខ្វះខាតខាងកម្លាំងពលកម្មរបស់ពួកគាត់ ក៏ដូចជាដើម្បីបំពេញនូវតម្រូវការរបស់ទីផ្សារផងដែរ ជាពិសេសដើម្បីឆ្លើយតបទៅប្រព័ន្ធធ្វើស្រែតាមកិច្ចសន្យា។

ជាងនេះទៅទៀត ក្រៅពីមានការផ្លាស់ប្តូរលើបច្ចេកទេសធ្វើស្រែ កសិករក៏ផ្លាស់ប្តូរពូជស្រូវសម្រាប់ដាំដុះដែរ ដើម្បីបង្កើនទិន្នផលស្រូវប្រចាំឆ្នាំ។ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CARDI) បានបង្កើតពូជស្រូវថ្មី និងធ្វើការផ្សព្វផ្សាយពីបច្ចេកទេសដាំដុះថ្មី ដល់ប្រជាកសិករ ដើម្បីបង្កើនទិន្នផលស្រូវ។ ពូជស្រូវថ្មីបានក្លាយទៅជាចំណាប់អារម្មណ៍របស់ប្រជាកសិករ

---

[4] «សេដ្ឋកិច្ចកម្ពុជា៖ មាគ៌ាឆ្ពោះទៅរកអនាគតដ៏ភ្លឺស្វាង៖ វឌ្ឍនភាព បញ្ហាប្រឈម និង ទស្សនវិស័យទៅអនាគត» បោះពុម្ពផ្សាយនៅភ្នំពេញ ឆ្នាំ ២០១៥ ដោយបណ្ឌិត ហង់ ជួន ណារ៉ុន។ ជំពូក ៧៖ វិស័យកសិកម្ម ទំព័រ១៧៧។

[5] អត្រានៃកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំនៅកម្ពុជា (ដោយធនាគារពិភពលោក)http://www.tradingeconomics.com/cambodia/gdp-growth-annual

ពីព្រោះវាអាចប្រមូលផលបានក្នុងរយៈពេលខ្លី អាចផ្តល់ទិន្នផលបានខ្ពស់ មានក្លិនក្រអូប បាយទន់ និងឆ្លើយតបតម្រូវការទីផ្សារជាតិ និងអន្តរជាតិ។ ពូជស្រូវបង្កាត់ថ្មីដ៏ពេញនិយមចំនួន១០មុខមានដូចជាពូជស្រូវស្រាលមានពូជសែនពីដោ អ៊ីអ៊ែរ៦៦ ជលសា ពូស្រូវកណ្តាលមានពូជផ្ការំដួល ផ្ការំដេង ផ្ការមៀត ផ្កាចាន់សែនសរ និងពូជស្រូវធ្ងន់មានពូជរាំងជ័យ ខា៤ និង ខា៦។ ពូជទាំងនេះសុទ្ធសឹងតែជាពូជស្រូវក្រអូបដែលត្រូវបានណែនាំ និងលើកទឹកចិត្តអោយដាំដុះដោយរាជរដ្ឋាភិបាល[6]។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ កសិករត្រូវទិញពូជស្រូវថ្មីទាំងនេះជាប្រចាំ ពីព្រោះពូជថ្មីទាំងនេះមិនអាចរក្សាទុកបានយូរឡើយ ហើយវាផ្តល់ផលខ្ពស់បានត្រឹមតែឆ្នាំដំបូងប៉ុណ្ណោះ តែមិនអាចផ្តល់ផលបានច្រើនសម្រាប់ឆ្នាំបន្តបន្ទាប់ឡើយ[7]។ ពូជស្រូវបុរាណ ឬប្រពៃណី ក៏ត្រូវបានបោះបង់ចោលជាបន្តបន្ទាប់ ហើយក៏បានបាត់បង់អស់ជាច្រើនប្រភេទផងដែរ ពីព្រោះប្រភេទស្រូវទាំងនោះមិនមែនជាតម្រូវការរបស់ទីផ្សារ និងមិនឆ្លើយតបទៅតាមស្តង់ដារទីផ្សារអន្តរជាតិឡើយ។ នេះធ្វើអោយកសិករបន្តពឹងផ្អែកកាន់តែខ្លាំងទៅលើពូជថ្មី ហើយពូជប្រពៃណីនឹងបាត់បង់។

## ៤. ទំនើបភាវូបនីកម្មវិស័យកសិកម្មស្រូវនៅកម្ពុជា

ក្រោយទសវត្សឆ្នាំ១៩៩០ មកដល់ពេលបច្ចុប្បន្ននេះ ប្រទេសកម្ពុជាកំពុងតែស្ថិតនៅលើមាគាឆ្ពោះទៅរកការអភិវឌ្ឍមួយដ៏លឿន។ រដ្ឋាភិបាលកម្ពុជាផ្តោតកាន់តែខ្លាំងក្នុងការពង្រឹងនិងអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ខ្លួន។ ក្នុងកំឡុងទស្សវត្សចុងក្រោយនេះ ឃើញថាប្រទេសកម្ពុជាមានកំណើនសេដ្ឋកិច្ចកើនឡើងជាលំដាប់ ដោយមានអត្រាកំណើនសេដ្ឋកិច្ចជាមធ្យម ៧.៦៣%ក្នុងមួយឆ្នាំ[8] ចាប់តាំងពីឆ្នាំ១៩៩៤ ដល់ ឆ្នាំ២០១៦។

ក្រោមជំនួយ និងការណែនាំរបស់ធនាគារពិភពលោក និងស្ថាប័នរូបិយវត្ថុអន្តរជាតិ ជាពិសេសក្នុងកំឡុងឆ្នាំ១៩៩៩-២០០២ រាជរដ្ឋាភិបាលប្រទេសកម្ពុជាបានធ្វើកំណែទម្រង់រចនាសម្ព័ន្ធសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយរៀបចំយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រដោយផ្តោតខ្លាំងទៅលើការអភិវឌ្ឍសេដ្ឋកិច្ច។ រាជរដ្ឋាភិបាលកម្ពុជាផ្តោតជាពិសេសទៅលើការវិនិយោគ រួមមានការវិនិយោគផ្ទាល់ពីបរទេស ការលើកកំពស់នូវភាពជាដៃគូរជាមួយស្ថាប័នឯកជន និងបើកអោយមាន

---

[6] ផលិតកម្មពូជស្រូវស្រាលសំខាន់ៗសម្រាប់ជម្រុញការនាំចេញអង្ករ ដោយបណ្ឌិតសឿន ប្រធាននាយកដ្ឋានផ្សព្វផ្សាយកសិកម្មនៃអគ្គនាយកដ្ឋានកសិកម្ម។ ទស្សនាវដ្តីកសិកម្ម លេខ៣៩ ត្រីមាសទី៣ ឆ្នាំ២០១១

[7] ករណីសិក្សាអំពីសហគមន៍កសិកម្ម និងការប្រើប្រាស់ពូជ នៅក្នុងភូមិដាសស្គរ ស្រុកកំពង់ត្រាច ខេត្តកំពត ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៦។

[8] អត្រានៃកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំនៅកម្ពុជា (ដោយធនាគារពិភពលោក)http://www.tradingeconomics.com/cambodia/gdp-growth-annual

ការចូលរួមពីវិស័យឯកជនក្នុងការផ្តល់សេវា និងចូលរួមក្នុងការអភិវឌ្ឍវិស័យនានា រាប់បញ្ចូលទាំងសេវាសាធារណ:[9]។ នៅក្នុងឆ្នាំ២០០៤ ប្រទេសកម្ពុជាបានចូលរួមជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ដោយត្រូវទទួលយកនូវកិច្ចព្រមព្រៀងពាណិជ្ជកម្មនានា រួមទាំងកិច្ចព្រមព្រៀងពាណិជ្ជកម្មស្តីពីកសិកម្មផងដែរ។ នៅក្នុងកិច្ចព្រមព្រៀងស្តីពីកសិកម្ម កម្ពុជាត្រូវធ្វើសេរីភាវូបនីយកម្មវិស័យកសិកម្ម ដោយបើកចំហរទីផ្សារកសិកម្មរបស់ខ្លួន និងអនុញ្ញាតិអោយមានការធ្វើពាណិជ្ជកម្មសេរីលើវិស័យកសិកម្ម ជាពិសេសរដ្ឋាភិបាលត្រូវធ្វើកំណែទម្រង់ និងបង្កើតគោលនយោបាយ និងច្បាប់នានាដើម្បីសម្រួលដល់ដំណើរការពាណិជ្ជកម្មសេរី និងការវិនិយោគក្នុងវិស័យកសិកម្ម។

រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំយុទ្ធសាស្រ្ត គោលនយោបាយជាតិ និងផែនការយុទ្ធសាស្រ្តអភិវឌ្ឍជាតិនានាសម្រាប់តម្រែតម្រង់ទិសដៅក្នុងការអភិវឌ្ឍជាបន្តបន្ទាប់។

នៅក្នុងផែនការយុទ្ធសាស្រ្តអភិវឌ្ឍជាតិ ចាប់តាំងពីឆ្នាំ២០០៦ មកដល់ពេលបច្ចុប្បន្នវិស័យកសិកម្មត្រូវបានដាក់ជាវិស័យអាទិភាពមួយដែលត្រូវលើកស្ទួយ ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ចធានាសមធម៌ សន្តិសុខស្បៀង និងជម្រុញសេដ្ឋកិច្ចជនបទ។ ការធ្វើទំនើបកម្មវិស័យកសិកម្ម គឺជាទិសដៅមួយដែលរាជរដ្ឋាភិបាលខិតខំប្រឹងប្រែងក្នុងអំឡុងពេល១០ឆ្នាំចុងក្រោយនេះ ជាពិសេសការកែប្រែកសិកម្មតាមបែបប្រពៃណីទៅជាទំនើបកម្មបែបប្រពលវប្បកម្ម (ស៊ីជម្រៅ) ក្នុងនោះមានដូចជា ការប្រើបច្ចេកទេស ការស្រាវជ្រាវពូជ ការអភិវឌ្ឍ និងការបញ្ជ្រាបការប្រើប្រាស់ពូជ១០មុខ ការជម្រុញការធ្វើយន្តូបនីយកម្ម (ការធ្វើកសិកម្មដោយគ្រឿងយន្ត) ជាដើម[10]។ ការកែលម្អប្រព័ន្ធធារាសាស្រ្ត និងការស្វែងរកទីផ្សារអន្តរជាតិ ក៏ជាវិធានការមួយដែលរាជរដ្ឋាភិបាលជឿជាក់ថាអាចនឹងជួយកាត់បន្ថយភាពក្រីក្រ និងបង្កើនប្រាក់ចំណូលរបស់ប្រជាពលរដ្ឋផងដែរ។

ការផ្តោតទៅលើទីផ្សារអន្តរជាតិ ក្លាយជាទិសដៅមួយរបស់រាជរដ្ឋាភិបាលផងដែរ ពិសេសគឺទីផ្សារអង្ករ។ រដ្ឋាភិបាលបានជម្រុញអោយមានការបង្កើនផលិតកម្មស្រូវ កែច្នៃអង្ករនិងជម្រុញការនាំចេញទៅទីផ្សារអន្តរជាតិ។ នៅក្នុងផែនការសកម្មភាពសម្រាប់អនុវត្តឯកសារគោល

[9] ក្របខណ្ឌឯកសារគោលនយោបាយស្តីពីសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសម្រាប់រយៈពេលមធ្យមនិងវែង ឆ្នាំ១៩៩៩-២០០២។ ឯកសារគោលនយោបាយសម្រាប់សម្របសម្រួលការកែទម្រង់រចនាសម្ពន្ធ័ រៀបចំដោយអាជ្ញាធរកម្ពុជា សហកាជាមួយនឹងបុគ្គលិករបស់មូលនិធិរូបិយវត្ថុអន្តរជាតិនិងធានាគាពិភពលោក ថ្ងៃទី៦ ខែតុលាឆ្នាំ១៩៩៩

[10] ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ២០០៩-២០១៣ និង ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨

នយោបាយស្តីពីការជម្រុញ ផលិតកម្មស្រូវនិងការនាំអង្ករចេញដែលរៀបចំដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខែមេសា ឆ្នាំ២០១១ បានបង្ហាញយ៉ាងច្បាស់អំពីចក្ខុវិស័យនេះ។

## ខ. ចក្ខុវិស័យ និង ទិសដៅយុទ្ធសាស្ត្រ

### ១. ចក្ខុវិស័យ

ឯកសារគោលនយោបាយស្តីពី «ការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ» បានបង្ហាញពីចក្ខុវិស័យ «គឺចង់ឲ្យប្រទេសកម្ពុជា ក្លាយជាជង្រុកស្រូវ និងជាប្រទេសនាំចេញអង្ករសំខាន់មួយលើទីផ្សារពិភពលោក »។ រាជរដ្ឋាភិបាលបានកំណត់យកឆ្នាំ ២០១៥ ជាឆ្នាំគោលដើម្បី: (១)ជំរុញការផលិតស្រូវលើសឱ្យបានច្រើនជាង ៤ លានតោន ក្នុងនោះ បរិមាណអង្ករសម្រាប់នាំចេញត្រូវសម្រេចឱ្យបានយ៉ាងតិច ១ លានតោន និង (២)ធ្វើឱ្យអង្ករកម្ពុជាត្រូវបានគេទទួលស្គាល់ជាអន្តរជាតិ។

### ២. ទិសដៅយុទ្ធសាស្ត្រ

ទិសដៅជាយុទ្ធសាស្ត្រ សម្រាប់ការបង្កើនផលិតកម្មដំណាំស្រូវ និងជំរុញការនាំចេញអង្កររបស់កម្ពុជាទៅទីផ្សារអន្តរជាតិគឺសំដៅ "ចូលរួមចំណែកជំរុញកំណើនសេដ្ឋកិច្ចជាតិ និងលើកកម្ពស់កំរិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ តាមរយៈ ការជំរុញផលិតកម្ម ពិសេសប្រពលវប្បកម្មដំណាំស្រូវ ការកែច្នៃ និង សម្រួលពាណិជ្ជកម្ម ដែលនឹងអាចបង្កើនការនាំចេញអង្ករ ពង្រីកទីផ្សារអន្តរជាតិ

នៅក្នុងផែនការសកម្មភាពនេះ ក៏បានគូសចេញនូវការជម្រុញការបង្កើនផលិតភាពដំណាំស្រូវ ការសម្រួលពាណិជ្ជកម្មតាមរយៈពង្រឹងសមត្ថភាពបច្ចេកទេស និងការគ្រប់គ្រងផលិតកម្មពិសេសការផ្ទេរបច្ចេកវិទ្យាកសិកម្ម ការប្រមូលផ្តុំផលិតកម្ម (សហគមន៍កសិកម្ម) និងផលិតកម្មតាមកិច្ចសន្យា ការគ្រប់គ្រងដីកសិកម្ម ការអនុវត្តច្បាប់ពូជដំណាំ ជាដើម។ វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កម្ពុជា ហៅកាត់ថាកាឌី មានតួនាទីសំខាន់ផងដែរនៅក្នុងផែនការសកម្មភាពនេះជុំវិញការងារអភិវឌ្ឍន៍ពូជស្រូវ ដែលសមស្របទៅនឹងក្សេត្របរិស្ថាននិងតម្រូវការទីផ្សារ។ ពូជស្រូវដែលបានកំណត់សម្រាប់ជម្រុញការធ្វើផលិតកម្មដំណាំស្រូវ អោយកាន់តែទទួលបាននូវទិន្នផលខ្ពស់រួមមានពូជស្រូវស្រាលមិនប្រកាន់រដូវមានចំនួន៣ពូជ គឺពូជសែនពិដោរ ពូជជលសា និងពូជអ៊ីអ៊ែរ៦៦ ពូជស្រូវកណ្តាលចំនួន៤មុខគឺពូជផ្ការំដួល ពូជផ្ការំដេង ពូជផ្ការមៀត និងពូជផ្កាច័ន្ទសែនស និងពូជស្រូវធ្ងន់ចំនួន៣ពូជគឺពូជរាំអជ័យ ពូជខា៤ និងពូជខា៦។

## ៤.១. ការស្រាវជ្រាវ អភិវឌ្ឍ និង គ្រប់គ្រងពូជដំណាំសម្រាប់បង្កើនផលិតកម្មកសិកម្ម

ជាមួយនឹងគោលដៅក្នុងការបង្កើននូវផលិតកម្មកសិកម្ម រួមមានទាំងស្រូវ រដ្ឋាភិបាលជម្រុញ អោយមានការអភិវឌ្ឍ និងស្រាវជ្រាវនូវពូជថ្មីនៃដំណាំ។ នៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០០៨ ច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និង សិទ្ធិអ្នកបង្កាត់ពូជដំណាំ ត្រូវបានអនុម័ត។ ច្បាប់នេះមានគោលដៅគ្រប់គ្រង និងត្រួតពិនិត្យលើកការបង្កាត់ ការបញ្ចេញអោយប្រើ ការផលិត ការកែច្នៃ ការចុះបញ្ជី ការចែកចាយ ការនាំចូល នាំចេញពូជដំណាំ និងការការពារពូជថ្មីនៃដំណាំក្នុងព្រះរាជាណាចក្រកម្ពុជា និង មានគោលបំណង ធានានៃការគ្រប់គ្រង ការលើកទឹកចិត្ត និងការអភិវឌ្ឍពូជដំណាំដោយនិរន្តរភាព ដើម្បីប្រយោជន៍សង្គម សេដ្ឋកិច្ច និងបរិស្ថាន[11]។ ក្នុងច្បាប់ក៏បានចែងអំពីសិទ្ធិរបស់អ្នកបង្កាត់ពូជឬម្ចាស់សិទ្ធិពូជថ្មីនៃដំណាំ ដែលអនុញ្ញាតអោយអ្នកដែលបានបង្កាត់ ឬរកឃើញ និងអភិវឌ្ឍពូជថ្មីនៃដំណាំ អាចដាក់ការការពារកម្មសិទ្ធិបញ្ញាលើពូជថ្មីនោះបាន នៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលនិង មានសិទ្ធិលក់ ឬ ផ្ទេរសិទ្ធិរបស់ខ្លួនបាន។ ហើយរាល់ការយកពូជឬបំណែកពូជដែលបានការពារទៅប្រើប្រាស់ក្នុងសកម្មភាព ការផលិត ឬការផលិតឡើងវិញដើម្បីសម្រាប់លក់ ឬចែកចាយនៅលើទីផ្សារ ការនាំចេញ ការនាំចូល ត្រូវសុំការអនុញ្ញាតិពីម្ចាស់

[11] ច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំនិងសិទ្ធិអ្នកបង្កាត់ពូជដំណាំ ជំពូកទី១៖ បទបញ្ញាតិទូទៅ មាត្រា ១ និង មាត្រា ២

សិទ្ធិ។ ម្ចាស់សិទ្ធិអាចផ្តល់ការអនុញ្ញាតអោយប្រើប្រាស់ពូជដំណាំរបស់ខ្លួនដោយភ្ជាប់នូវលក្ខខណ្ឌ ឬការកំណត់ផ្សេងៗ[12]។ លើសពីនេះទៅទៀត ម្ចាស់សិទ្ធិពូជថ្មីនៃដំណាំ អាចប្តឹងទៅតុលាការមានសមត្ថកិច្ចដើម្បីហាមឃាត់ការប្រព្រឹត្ត ឬការបន្តប្រព្រឹត្តអំពើរំលោភបំពានលើសិទ្ធិអ្នកបង្កាត់ពូជ និងផាកពិន័យ រឹបអូស ឬបំផ្លាញចោលពូជដំណាំដែលបានផលិតល្មើសលើសិទ្ធិអ្នកបង្កាត់ពូជដំណាំ និងសងការខូចខាតជាទឹកប្រាក់[13]។

## ៤.២. ការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្មសម្រាប់គាំទ្រដល់ផលិតកម្មកសិកម្ម

ដើម្បីគាំទ្រ និងជម្រុញដល់កំនើនផលិតកម្មកសិកម្ម និងជម្រុញប្រសិទ្ធិភាពនៃវិស័យកសិកម្ម រដ្ឋាភិបាលបានអនុញ្ញាត និងបើកអោយមានការនាំចូលនូវប្រភេទថ្នាំកសិកម្ម និងជីកសិកម្មគ្រប់ប្រភេទរួមមានទាំងជីសរីរាង្គ និង អសិរីរាង្គ។ ច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម ត្រូវបានបង្កើតឡើងនិងអនុម័តនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ក្នុងគោលដៅកំណត់អំពីការគ្រប់គ្រងថ្នាំកសិកម្ម និង ជីកសិកម្មគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ គោលបំណងចំនួនពីរក្នុងចំណោមគោលបំណងសំខាន់ៗចំនួន៤ដែលមានចែងនៅក្នុងច្បាប់នេះ គឺ ធានាការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្មប្រកបដោយប្រសិទ្ធិភាព និងសុវត្ថិភាព និងកាត់បន្ថយហានិភ័យដែលបង្កដោយការប្រើប្រាស់ថ្នាំកសិកម្ម និងជីកសិកម្ម ដើម្បីផលប្រយោជន៍របស់កសិករ និងប្រជាពលរដ្ឋទូទាំងប្រទេស ដោយធានាបាននូវសន្តិសុខស្បៀង សុវត្ថិភាពស្បៀង សុខភាពសាធារណៈ និងនិរន្តរភាពនៃបរិស្ថាន[14]។ នៅក្រោមវិសាលភាពនៃច្បាប់នេះ រូបវន្តបុគ្គល ឬនីតិបុគ្គលរួមមានក្រុមហ៊ុនឯកជន អាចធ្វើពាណិជ្ជកម្មឬធ្វើការលាយផ្សំថ្នាំកសិកម្មគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា ធ្វើការនាំចូល នាំចេញថ្នាំកសិកម្ម និងផ្គត់ផ្គង់ ចែកចាយ ដោយមានការយល់ព្រមអនុញ្ញាត និងការចុះបញ្ជីថ្នាំកសិកម្មនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់និង នេសាទ[15]។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទមានតួនាទីសំខាន់ក្នុងការគ្រប់គ្រង ការចុះបញ្ជី និង ត្រួត

---

[12] ច្បាប់ស្តីពីការគ្រប់គ្រងពូជនិង សិទ្ធិអ្នកបង្កាត់ពូជដំណាំ ជំពូកទី២ ការពារពូជថ្មីនៃដំណាំ ផ្នែកទី២៖ វិសាលភាព និងសុពលភាពនៃអ្នកបង្កាត់ពូជដំណាំ មាត្រា១១ មាត្រា១៤ និង មាត្រា ១៥

[13] ច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និង សិទ្ធិអ្នកបង្កាត់ពូជដំណាំ ជំពូកទី៧ ទោសបញ្ញាតិ ផ្នែកទី១៖ បទល្មើសលើការការពារពូជថ្មីនៃដំណាំ

[14] ច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និង ជីកសិកម្ម ជំពូកទី១ បទបញ្ញាតិទូទៅ មាត្រា១ និង មាត្រា២

[15] ច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និង ជីកសិកម្ម ជំពូកទី៣ ការគ្រប់គ្រងថ្នាំកសិកម្ម ផ្នែកទី១ ការចុះបញ្ជីថ្នាំកសិកម្ម និង ការតម្រូវបមាណីយ មាត្រា៧ មាត្រា៨ មាត្រា១២ និងផ្នែកទី៣ មាត្រា២៩ និងអនុផ្នែកទី៥ មាត្រា៣៧ មាត្រា៣៨ និង ជំពូកទី៤ ការគ្រប់គ្រងជីកសិកម្ម ផ្នែកទី១ ការចុះបញ្ជីជីកសិកម្មនិងការតម្រូវបមាណីយ មាត្រា៥២

ពិនិត្យរាល់ការអនុវត្តរបស់ក្រុមពាណិជ្ជករ និងក្រុមហ៊ុនក្នុងការផ្គត់ផ្គង់ ចែកចាយ ថ្នាំកសិកម្ម និងជីកសិកម្ម ព្រមទាំងត្រួតពិនិត្យ វាយតម្លៃអំពីផលប៉ះពាល់នៃថ្នាំកសិកម្មនិងជីកសិកម្មមុនពេលអនុញ្ញាតអោយចរាចរណ៍លើទីផ្សានិងនៅក្នុងពេលចាំបាច់[16]។

## ៥. គោលបំណង និងវិធីសាស្ត្រនៃការសិក្សា

### ៥.១. គោលបំណងនៃការសិក្សាស្រាវជ្រាវ

សកម្មភាពសង្គមដើម្បីសហគមន៍និងការអភិវឌ្ឍ កសិករនៃបណ្តាញពហុវិស័យ និងក្រុមស្រាវជ្រាវសកម្ម មានក្តីបារម្ភជុំវិញទិសដៅ និងការជម្រុញរបស់រាជរដ្ឋាភិបាលដែលកំពុងតែទទួលរងនូវឥទ្ធិពលប្រព័ន្ធទីផ្សារ និងពាណិជ្ជកម្មសេរី នៃសេរីភាវូបនីយកម្ម មកលើវិស័យកសិកម្មនៅប្រទេសកម្ពុជា រួមមានការជម្រុញធ្វើទំនើបកម្មកសិកម្មដំណាំស្រូវ ការផ្តោតទៅលើផលិតកម្មដើម្បីការនាំចេញ និងទីផ្សារអន្តរជាតិ ពិសេសការជម្រុញអោយមានការប្រើប្រាស់ពូជស្រូវបង្កាត់ថ្មី និងការធ្វើយន្តូបនីយកម្មជាជាងការផ្តោតទៅលើការបែងចែកដីសម្រាប់កសិករក្រីក្រ ព្រមទាំងការបំភ្លេចចោល ឬ បោះបង់ចោលកសិកម្មបែបប្រពៃណី។ យើងបារម្ភថាទិសដៅ និងការអនុវត្តទាំងនេះ មិនបានធានានូវសមធម៌ សន្តិសុខស្បៀង និងការអភិវឌ្ឍពិតប្រាកដនៅតំបន់ជនបទឡើយ។ ប៉ុន្តែវាអាចគម្រាមគំហែងដល់អធិបតេយ្យស្បៀង សន្តិសុខស្បៀង និងសុវត្ថិភាពស្បៀង សម្រាប់កសិករក្រីក្រ កសិករខ្នាតតូច និងកសិករខ្នាតមធ្យមនៅប្រទេសកម្ពុជា ហើយវានឹងអាចផ្តល់ផលប៉ះពាល់ដល់ការអភិវឌ្ឍសង្គម និងបង្កអោយមានភាពក្រីក្រកាន់តែខ្លាំងឡើងៗដល់ប្រជាជននៅប្រទេសកម្ពុជាផងដែរ។

ខាងក្រោមនេះគឺគោលបំណងសំខាន់ៗសម្រាប់ការសិក្សាស្រាវជ្រាវះ

១. ស្វែងយល់អំពីប្រព័ន្ធផលិតកម្មស្រូវ (បែបប្រពៃណី និងទំនើបថ្មី) និងផលប៉ះពាល់មកលើអធិបតេយ្យស្បៀង សន្តិសុខស្បៀង និងសេដ្ឋកិច្ចរបស់កសិករខ្នាតតូច និងមធ្យម ដោយផ្តោតសំខាន់ទៅលើការប្រែប្រួល នៃរបៀបធ្វើស្រែរបស់កសិករនិងសិក្សាពីមូលហេតុនៃនិន្នាការនៃការផ្លាស់ប្តូរទាំងនេះ ជាមួយនឹងការវិភាគទៅលើហានិភ័យដែលអាចកើតមាន។

២. ស្វែងយល់អំពីការប្រើប្រាស់ពូជផ្សេងៗ (ពូជប្រពៃណី និងពូជទំនើបថ្មី) និងផលប៉ះពាល់របស់វាដែលអាចកើតមានចំពោះអធិបតេយ្យស្បៀង សន្តិសុខស្បៀង និងសុវត្ថិភាពស្បៀងរបស់កសិករខ្នាតតូច និងមធ្យម។

---

[16] ច្បាប់ស្តីពីការគ្រប់ថ្នាំកសិកម្ម និងជីកសិកម្ម ជំពូកទី៨ សុពលភាពផ្គត់ផ្គង់ ចែកចាយ មាត្រា ៨៧ មាត្រា៨៩ មាត្រា៩០

៣. ស្វែងយល់អំពីបច្ចេកទេសនិងវិធីសាស្ត្រក្នុងការផលិតស្រូវ ឬការធ្វើកសិកម្មដែលធានាបាននូវអធិបតេយ្យស្បៀង សន្តិសុខស្បៀង និងសុវត្ថិភាពស្បៀង សេដ្ឋកិច្ច និងបរិស្ថាន ដោយផ្អែកទៅលើបទពិសោធន៍ជាក់ស្តែងរបស់កសិករ។

## ៥.២. វិធីសាស្ត្រ៖ ការជ្រើសរើសសំណាក និងការប្រមូលទិន្នន័យ

ការសិក្សាស្រាវជ្រាវនេះ ត្រូវបានធ្វើឡើងដោយប្រើនូវវិធីសាស្ត្រមួយចំនួន ដូចជាការសិក្សាស្រាវជ្រាវតាមរយៈឯកសារដែលមានស្រាប់ ការចុះសម្ភាសន៍គ្រួសារកសិករនៅតាមមូលដ្ឋាន ព្រមទាំងមានការពិភាក្សាជាក្រុមផងដែរ។ ការចុះប្រមូលព័ត៌មានត្រូវបានធ្វើឡើងដោយក្រុមកសិករដែលជាសមាជិកស្នូលរបស់បណ្តាញពហុវិស័យ ក្រុមស្រាវជ្រាវសកម្ម និងបុគ្គលិកអង្គការសកម្មភាពសង្គមដើម្បីសហគមន៍និងការអភិវឌ្ឍ នៅក្នុងខេត្តចំនួនប្រាំមួយនៅក្នុងប្រទេសកម្ពុជារួមមានខេត្តព្រៃវែង តាកែវ កំពត កំពង់ឆ្នាំង កំពង់ធំ និងបាត់ដំបង ដែលក្នុងនោះមាន ៩ស្រុក ១០ឃុំ និង១៥ភូមិ។ មានការសម្ភាសកសិករមកពី១០១គ្រួសារផ្សេងៗគ្នា ក្នុងនោះមានស្រីចំនួន៥៥នាក់ និងការពិភាក្សាក្រុមចំនួន៣ក្រុម (កសិករវ័យកណ្តាលអាយុចាប់ពី ២៥ ទៅ ៤៥ឆ្នាំ ចំនួន១ក្រុម ក្រុមកសិករវ័យចំណាស់អាយុចាប់ពី ៤៥ ទៅ ៩០ ឆ្នាំចំនួនពីរក្រុម) និង សម្ភាសន៍កសិករដែលជាអ្នកផលិតពូជទំនើបថ្មីសម្រាប់ចែកចាយ ចំនួន៤នាក់។

**មូលហេតុសំខាន់ៗដែលខេត្តទាំងនេះត្រូវបានជ្រើសរើសមាន៖**

- ជាតំបន់ដែលធ្វើកសិកម្មជាពិសេសដំណាំស្រូវ និងមានប្រភេទកសិករខ្នាតតូច ខ្នាតមធ្យម និងខ្នាតធំ។ ហើយកសិកររស់នៅក្នុងខេត្តទាំងនេះ នៅប្រើប្រាស់ពូជបុរាណ ឬប្រពៃណី ហើយក៏មានការប្រើប្រាស់ពូជថ្មី ឬពូជបង្កាត់ច្រើន ព្រមទាំងប្រើប្រាស់ជីគីមី និងថ្នាំពុលគីមីផងដែរ។
- កសិករជួបនឹងបញ្ហាច្រើនដូចជាជំពាក់បំណុល ចំណាកស្រុក កង្វះខាតស្បៀង។
- បង្ហាញពីស្ថានភាព និងបញ្ហាកសិករនៃខេត្តនីមួយៗដែលមានទីតាំងស្ថិតនៅភូមិភាគផ្សេងគ្នាដូចជា ពាយ័ព្យ ឧត្តរ និរតី និងកណ្តាល។ តាមដាន និងប្រៀបធៀប ស្ថានភាពបំណុលពាក់ព័ន្ធនឹងការធ្វើកសិកម្មនៅក្នុងខេត្តព្រៃវែង និងកំពង់ឆ្នាំង ដែលអង្គការសកម្មភាពសង្គមដើម្បីសហគមន៍និងការអភិវឌ្ឍ ធ្លាប់បានធ្វើការស្រាវជ្រាវកន្លងមក។
- មានការសហការ និងការគាំទ្រពីកសិករនៃបណ្តាញពហុវិស័យ និងសហគមន៍កសិករដែលជាដៃគូរក្នុងការជួយប្រមូលព័ត៌មាន។

**ចំពោះអ្នកផ្តល់ព័ត៌មានវិញ ពួកគាត់ត្រូវបានជ្រើសរើសឲ្យចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះ ពីព្រោះ៖**

- ជាកសិករដែលមានបទពិសោធន៍ប្រើពូជបុរាណ ឬប្រពៃណី ពូជថ្មី ប្រើជីគីមី និងថ្នាំពុលសម្លាប់សត្វល្អិត
- ជាកសិករដែលមានទំហំដីតូច មធ្យម និងធំ
- ជាអ្នកផលិតពូជស្រូវ អ្នកលក់ និងចែកចាយពូជថ្មី ឬ ពូជបង្កាត់

**ក្រុមអ្នកស្រាវជ្រាវមាន៖**

- ក្រុមកសិករដែលចូលរួមចុះប្រមូលព័ត៌មានចំនួន ១៥-២០នាក់៖ កសិករមកពីបណ្តាញពហុវិស័យ ក្រុមស្រាវជ្រាវនៃអង្គការផ្តោតទៅលើលោកខាងត្បូង
- បុគ្គលិកអង្គការសកម្មភាពសង្គមដើម្បីសហគមន៍និងការអភិវឌ្ឍ និង អ្នកប្រឹក្សាយោបល់ចំនួនមួយនាក់



ស្ត្រីកសិករនៅស្រុក ស្តុកកក្បាស ខេត្តកំពង់ឆ្នាំង។ ក្រៅពីធ្វើស្រែ មីង ដាំក្រូចឆ្មាសម្រាប់លក់ក្នុងស្រុកភូមិរបស់មីងផងដែរ។ រូបថតដោយ SACD។



ប្តី ប្រពន្ធកសិករ ចូលរួមផ្តល់កិច្ចសម្ភាសន៍ ស្រុក អង្គរបុរី ខេត្ត តាកែវ។ រូបថតដោយ ហ៊ីង សុខហ៊ុល។

# បទពិសោធជាក់ស្តែងនៃការធ្វើស្រែ និងស្ថានភាពរបស់កសិករពីមុននិងបច្ចុប្បន្ន



ស្ត្រីកសិករ ចែករំលែកអំពីការធ្វើស្រែនាសម័យពីមុន នៅស្រុកអង្គរបុរី ខេត្ត តាកែវ។

រូបថតដោយ ហ៊ីង សុខហ៊ុល។



លោកតា សៀ ចែករំលែកអំពីការធ្វើស្រែនាសម័យពីមុន នៅស្រុកអង្គរបុរី ខេត្ត តាកែវ។ រូបថតដោយ ហ៊ីង សុខហ៊ុល។





ក្រុមកសិករវ័យចំណាស់ ចែករំលែកអំពីការធ្វើស្រែនាសម័យពីមុន នៅខេត្ត កំពង់ធំ។

រូបថតដោយ សុភារិទ្ធ



# ៦. របកគំហើញសំខាន់ៗនៃការសិក្សាស្រាវជ្រាវ

## ៦.១. បទពិសោធជាក់ស្តែងនៃការធ្វើស្រែរបស់កសិករ

### ៦.១.១. បទពិសោធនិងស្ថានភាពរបស់កសិករមុនទសវត្សឆ្នាំ២០០០

#### ក.ការដាំដុះ និងបច្ចេកទេស

នៅកំឡុងទសវត្សឆ្នាំ១៩៨០មកមុនកំឡុងឆ្នាំ២០០០ កសិករភាគច្រើន (៦៩.៧% ក្នុងចំណោមកសិករដែលបានផ្តល់បទសម្ភាសន៍ ៦៨នាក់) មានដីសម្រាប់ធ្វើស្រែតូចជាង ២ ហិកតា ក្នុងនោះមាន៥០%នៃពួកគាត់មានដីតូចជាងមួយហិកតា។ កសិករ ២៨% ផ្សេងទៀតមានដីទំហំធំជាងពីរហិកតាទៅ៥ហិកតា ចំណែកអ្នកដែលមានដីធំជាង៥ហិកតាគឺមានចំនួនតិចតួចបំផុត (៧.៥%)។ ជាមួយនឹងដីស្រែដែលមាន កសិករភាគច្រើនបំផុត និយមធ្វើស្រែវស្សា និងកសិករតិចតួចបំផុតដែលធ្វើស្រែលាយគ្នា មានប្រាំងនិងវស្សា។ ជាទូទៅធ្វើការដាំដុះ១ដងក្នុង១ឆ្នាំ តែក៏មានកសិករមួយចំនួនតូច (១១%នៃ៦២នាក់នៃអ្នកផ្តល់សម្ភាសន៍) ធ្វើស្រែរហូតដល់ទៅ៣ដងក្នុងមួយឆ្នាំ ពិសេសគឺអ្នកដែលធ្វើស្រែប្រាំង។ កសិករបានលើកឡើងថា កាលដែលមិនសូវមានការធ្វើស្រែប្រាំង គឺដោយសារតែនៅមានកង្វះទឹក ប្រព័ន្ធស្រោចស្រព ហើយកត្តាចំបងនោះ គឺមិនទាន់មាន

ពូជស្រែប្រាំងច្រើន ដូចបច្ចុប្បន្នឡើយ។ ពេលដែលនិយាយអំពីពូជស្រែប្រាំង កសិករសំដៅទៅលើពូជថ្មីៗដែលមិនប្រកាន់រដូវ និងអាចប្រមូលផលបានក្នុងរយៈ៩៥ទៅ១០៥ថ្ងៃ ។ ភាគច្រើនពូជប្រាំងនិងស្រូវមិនប្រកាន់រដូវទាំងនោះ បាននាំចូលពីប្រទេសវៀតណាម ដោយឈ្មួញវៀតណាមនិងអាជីករដែលលក់ពូជស្រូវក្នុងស្រុក ពូជទាំងនោះមានដូចជាពូជ ណាំខុងបូង (៥០៤) ពូជអ៊ីអ៊ែផ្សេងៗទៀត ក្រៅពីនេះក៏មានពូជស្រូវរយៈពេលខ្លី (៩៥ទៅ១០៥ថ្ងៃរួមមានពូជស្រូវវស្សាផងដែរ) ជាពូជស្រូវក្រអូប ដូចជាសែនពិដោរ អ៊ីអ៊ែ៦៦ ដែលចែកចាយនិងផ្សព្វផ្សាយដោយរដ្ឋាភិបាលតាមរយៈមន្ទីរកសិកម្មនិងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលធ្វើរឿងកសិកម្មនិងពូជស្រូវមួយចំនួន។

ចំពោះរបៀបដាំដុះវិញ ឃើញថា កសិករស្ទើរតែទាំងអស់ (៩៤% នៃ ៦៩នាក់) ធ្វើស្រែដោយបែបប្រពៃណី គឺរក្សាតាមទម្លាប់ពីដូនតា មានដូចជា ភ្ជួរដីដោយប្រើប្រាស់កំលាំងសត្វ សាបព្រួសគ្រាប់ពូជ រួចដកយកទៅស្ទូងនិងថែទាំទៅតាមទម្លាប់ពីប្រពៃណី ខណៈដែលមានកសិករតិចតួចបំផុតដែលគាត់ព្រួសគ្រាប់ស្រូវយកតែម្តង ដោយសារតែខ្វះកំលាំងពលកម្ម។

*"...បច្ចេកទេសដាំដុះកាលពីសម័យមុនភ្ជួរដាស់ដីថ្នាលសំណាប ២ ដង។ បន្ទាប់មកធ្វើថ្នាលឲ្យរាបទើបសាបស្រូវ។ នៅពេលសំណាបមានអាយុបាន ១ខែដកវាយកទៅស្ទូង។ របៀប ស្ទូងគឺ មុននិងស្ទូងត្រូវភ្ជួរដាស់ដីចោលរយៈពេល ១៥-២០ថ្ងៃ ទើបទៅភ្ជួរ វាម្តងទៀតរាស់ដីឲ្យស្មើទើបស្ទូង។ ការភ្ជួរដោយប្រើនង្គ័ល នាស់ឈើនិង ប្រើកម្លាំងសត្វគោ។ សម្រាប់ការថែទាំគឺរក្សាទឹកឲ្យល្មមក្នុងស្រែត្រឹមក្រចកជើង និងបោចស្មៅក្នុងស្រែ។ ការច្រូតដោយដៃប្រើកណ្តៀវ។ របៀបធ្វើស្រែគឺធ្វើតាមទម្លាប់ពីដូនតា។..." គង់ ប៊ុនធឿន ភេទប្រុស អាយុ ៤៨ឆ្នាំជាកសិកររស់នៅខេត្តកំពត។*

## ខ. ការប្រើប្រាស់ពូជ

ចំពោះពូជស្រូវវិញ កសិករទាំងអស់ (១០០%នៃកសិករ៧០នាក់ដែលបានផ្តល់ព័ត៌មាន) ប្រើប្រាស់ពូជប្រពៃណីសុទ្ធ ក្នុងនោះមានប្រទភេទស្រូវស្រាល មានដូចជា អង្កុក កំពឹងពួយ ហាបាកូនក្រាញ់ សណ្តាយកន្លះ នាងនូ។ ពូជស្រូវកណ្តាលមានដូចជា ដំណើបក្រសាំង គង់សរ ដំណើបឈូក ដំណើបក្រចកសេះ ផ្កាខ្ញីជាដើម ។ ពូជស្រូវធ្ងន់មានដូចជា នាងមាស ផ្កាទៀន គង់កំបុតអង្គរជ័យ ផ្កាស្លាធ្ងន់ នាងដុំ ជាដើម[17]។ មានកសិករតិចតួចបំផុត (៨.៩% នៃ៧០នាក់) ដែលចាប់ផ្តើមនិងបានប្រើប្រាស់ពូជទំនើបថ្មី ពិសេសពូជស្រូវមានរយៈពេលខ្លី (៣ខែ) ដូចជាពូជអ៊ីអ៊ែរ៦៦ សែនពិដោរ ប្រភេទអ៊ីអ៊ែរផ្សេងៗទៀត និងពូជស្រូវរយៈពេលវែង មាន រាំងជ័យ ខា (៤ និង ៦ ជាដើម)។

[17] សូមមើលតារាង១៖ ពូជប្រពៃណីដែលបានប្រើប្រាស់កន្លងមក

## តារាង១៖ ពូជស្រូវប្រពៃណីដែលកសិករបានប្រើប្រាស់កន្លងមក ដកស្រង់ចេញពីកសិករដែលផ្តល់បទសម្ភាសន៍

| **ប្រភេទស្រូវ** | **តាកែវ** | **កំពង់ឆ្នាំង** | **កំពង់ធំ** | **បាត់ដំបង** | **ព្រៃវែង** |
|---|---|---|---|---|---|
| **ស្រូវស្រាល** | អង្កុក ហាបា កូនក្រាញ់ សណ្តាយកន្លះ នាងនូ ដំណើបស្នាល់ ខ្ពដូង ក្រចកជៀស ពងលលក សុម៉ាលី ខ្លឹមមៀន នាងកុក អញ្ចូលកន្លះ ស្រូវរំចូលកន្លះ | អង្គង់ខ្សាច់ ក្រសាំងទាប បន្ទុះភ្លុក ជាយស្បៃ ផ្ការំចង់ គ្លានមាន | នាងមាស ជីកែង នាងគង់ក្រអូប សរកាមួន នាងគួយ មាសសរ ខ្ញុំ ចន្ទុះប្លុក | ដំណើបទងសង្កែ ដំណើបល្វាវត់ គង់ខ្មៅ | ដំណើបក្រចកសេះ ដំណើបល្អិត ដំណើបគ្រប់បញ្ញក់ ទ្រនិចឃ្មុំ នាងគក់ប្រពៃ |
| **ស្រូវកណ្តាល** | ដំណើបក្រសាំង គង់សរ ដំណើបឈូក ដំណើបក្រចកសេះ ផ្កាខ្ចី ដំណើបខ្ទងដំរី ដំណើបមាន ១០០ ជ័យ ចំរើនផល កុកក្តឹក ស្រូវខ្លី នាងចិន ស្រូវពងលលក ក្រចកសេះ ពូជគង់ស នាងស្មើ ពូជកុកកន្តឹក ស្រូវរំចូល បីគួរ ដំណើមផ្កាល់ហ៊ីង ចុងប | ដំណើបខ្មៅ ឆ្អឹងដំរី ឈាមអន្ទង់ ក្រចកចាប នាងសរ ឆ្មាព្រំ ផ្កាស្លា ពងអង្រ្គង ចងៀកផ្កោ សំបុកអង្រ្គង នាងនយ កូនត្រី ចុងបន្លា បន្ទុះភ្លុក អូសទូក ខ្ទងរមាំង ណូយ រិទ្ធក្អិត ពូជពងហ៊ីង ចង្រៀកផ្កោ | ដំណើបនាងនួក ដំណើបត្នោត ព្រុំ ណូយ ដំណើបក្រចកចាប ដំណើបស្លាប ដំណើបនាងនុ មរម្យ នាងវែកសាមលាវ | ដំណើបជាយស្បៃ ដំណើបឈាមអន្ទង់ ដំណើបខ្មៅ ពូជនាងខ្សាច់ ពូជនាងពេជ្យ ពូជគ្រាប់ក្រូច នាងលួច ចង្វាយផ្កោ ដំណើបពងហ៊ីង ពូជស្មាព្រំ ដំណើបក្រចកចាប ចុងបន្លា | ដំណើបក្រឡាញ់ ដំណើបត្នោត ដំណើបស្អិតចេក ក្រសាំងទាប ដំណើបខ្សាច់ កន្តុំ៣ ពូជឆ្មា ពូជខ្ទងមាន់ ថ្មក្រឹម នាងពួន ស្រូវក្រហម សំបុក អង្រ្គង ចុងបន្លា ពូជម្រុំ |

| | | | | | |
|---|---|---|---|---|---|
| | ន្លា | | | | |
| **ស្រូវធ្ងន់** | នាងមាស ផ្កាទៀន គង់កំបុត អង្គរជ័យ ផ្កាស្លាធ្ងន់ នាងដុំ ដំណើមខ្មៅ គង់ទាប ស្រូវឡើងទឹក សណ្តាយធំ ស្រូវក្រហម ដំណើបឈ្មូក កូនត្រី ផ្កាដូង ចង្កោរំពាក់ លាក់សន្លឹក ១០០ កំពីងពួយ ជ័យ ផ្កាស្លា | សញ្ញឹក សអង្ជើល ចង្ហារ នាងមិញ ឆ្អឹងពស់ ផ្ការំចេក នាងឬស ធ កន្ទុយខ្មៅ ខ្ពរដូង នាងសរ ស្រូវពក ភ្នំរុន ភ្នាព្រំ ឆ្មើរ រិទ្ធសរ កន្ទុយខ្មៅ ពូជលាក់សន្លឹក រំអងសាឡី នាង គង់ខ្សាច់ ពូជនាងកុក ពង អង្រ្កង | លាក់សន្លឹក ចង្វាយផ្តៅ ព្រិច សេងប៊ូ ប្រពាយ ស្នាំង ចិញ្ចើមប្រវឹក ៦គួរ ស្រូវនាងស ពពាយឡើងទឹក ស្រូវណ្ហាយ នាង គង់ខ្សាច់ កន្ទុយដំរី គុល ដូង អង្គង់គ្រើល ៨គួរ ប្រពាយក្រហម ផ្តៅពេន នាងមាន់ កំពីងពួយ ស្រូវព្រិច សំបុកអង្រ្កង | ពូជកំពឹងពួយ នាងមាស នាងចៅ ផ្កាស្លា ឆ្មាព្រំ ពូជកូនឃ្មុំ ឬ កូនត្រី ពូជនាងស ពនាងល្វូច សក្រញ៉ាញ់ ចង្កោម រំពាក់ នាងគង់មៅ ពូជគង់កណ្តា ពូជនាងឡុង ពូជជង្គង់ខ្សាច់ ពូជជង្គង់ខ្មៅ ពូជឆ្អឹងក្របី ពូជកាឡា នាងខុន នាងមិញ | នាងខុន បន្លាផ្តៅ ទងឈ្មូក នាងមិញ នាងមាស នាងនូ នាងសរ បន្លាផ្តៅ កូនស្រូវ នាងឈ្មូក នាងអ៊្លូក |

តារាង ១.១៖ ពូជប្រពៃណី ស្រូវក្រអូប របស់កម្ពុជាដែលមានកន្លងមក (ប្រភព៖ www.cardi.org.kh, បណ្ឌិត ម៉ែន សារ៉ុម, "ដំណាំស្រូវនៅកម្ពុជា" វិទ្យាស្ថានស្រាវជ្រាវ និង អភិវឌ្ឍន៍កសិកម្មកម្ពុជា, ឆ្នាំ ២០០៧)

| ប្រភពដើម | ឈ្មោះពូជ | ប្រភពដើម | ឈ្មោះពូជ |
|---|---|---|---|
| កំពង់ធំ | អង្រ្កង ក្រឹមក្រអូប នាងហម | ស្ទឹងត្រែង | ត្នោតកន្លះ ស្រូវប្រាយ កាហុក បីគួរ ស្រូវគរគៀល |
| កោះកុង | អន្សថធំ ថ្មរមៀល កសិកម្ម ក្រចកចាប | ស្វាយរៀង | ផ្កាម្លិះ |
| កំពត | អញ្ចូល ស្រូវម្ទូល ស្រូវលឹម ស្រូវក្រហម ស្រូវរវក ស្រូវសស្អាត | ស្ទឹងត្រែង | ត្នោតកន្លះ កាហុក ស្រូវគរគៀល |
| សៀមរាប | អាស៊ាន គុយស ផ្កាចាន់ | មណ្ឌលគិរី | សរធ្ងន់ ផ្កាចារ ស្រូវក្រាញ់ ដកកែវ សាគុណ ដំណើបពងទា សំបុកអង្រ្កង ប៉ារដៀស្វាយ នាងនួនប៉ាគេន ប៉ាផាអៀ ម៉្រុំ ប៉ាយ៉ាំងទង |
| បាត់ដំបង | សុមាលីក្រអូប ស្រូវឆាង | រតនគិរី | ស្រូវជំជាន ស្រូវហេន ស្រូវអីម៉្ញូង ដកសួន កាទីវ ម៉ាក់ខា ដំណើបដង្កូវ ស្រូវរអឹកអៀ |
| ត្បូងឃ្មុំ | ដំណើបក្រហម ផ្កាខ្ញី ផ្កាស្លា ខ្នា ឡារ | កំពង់សោម | នាងកុក ស្រូវប្រាយ |
| កំពង់ចាម | ម្រេច ក្រមួនស ក្រយា កណ្តាលក្បាល មិញភ្លុក | ក្រចេះ | គ្រាប់ក្រូច ស្រូវថៃ ចម្រើនផល ដំណើបឃ្យូន ក្ងោកពុង ស្រូវគួយ ស្រូវស្មើ ស្រូវតេះ ចាំថៃ ថ្មរអិល ស្រូវនាងឡាយ ដំណើបក្រមួន បង្គួយខ្សាច់ គង់កំបុត គង់កក្អឹក មានជ័យ នាងអំ នាងឆ្មារ ផ្កៅប៉ែន ផល្លី ថ្វាង ស្រូវញៀង ស្រូវខ្មេម ស្រូវខេង ស្រូវខ្លែង ស្រូវខឹម ដំណើបកង្វែន ដំណើបកូនឃ្មុំ ប្រទាល រិច ដំណើបនាងអន ចង្វាយផ្កៅ ដំណើបខ្មៅ |

| | | | |
|---|---|---|---|
| | | | ដំណើបជើងមាន់ ដំណើបដំបូក<br>ផនថៃ ដំណើបសក់ |
| ព្រៃវែង | ដំណើបផ្ការល្វេស សូម៉ាលី | តាកែវ | ក្រញាំចាប |
| កំពង់ឆ្នាំ | នាងស | | |

### គ. ការប្រើប្រាស់ជី ការគ្រប់គ្រងសត្វល្អិត និងកត្តាចង្រៃ

លាមកគោ ក្របី ស្លឹកឈើរលួយ គឺជាប្រភពជីធម្មជាតិដ៏សំខាន់មួយរបស់កសិករនាសម័យនោះ។ ប៉ុន្តែក្រោយពីឆ្នាំ១៩៨០មក កសិករបានចាប់ផ្តើមប្រើជីគីមីជាបន្តបន្ទាប់។ តាមទិន្នន័យសម្ភាសន៍ មកត្រឹមមុនឆ្នាំ២០០០ច្រើនជាងពាក់កណ្តាលនៃចំនួនកសិករទាំងអស់ ប្រើប្រាស់ជីធម្មជាតិសុទ្ធ ខណៈកសិករចំនួនជាងពាក់កណ្តាលទៀតប្រើប្រាស់ជីធម្មជាតិលាយជាមួយនឹងជីគីមី និងមានកសិករតិចតួចបំផុតដែលប្រើប្រាស់ជីគីមីសុទ្ធ។ ជីគីមីដ៏ពេញនិយមមួយចំនួនដែលត្រូវបានប្រើប្រាស់នាកំឡុងពេលនោះ មានដូចជា ម៉ូហ្វូស ជីស (អ៊ុយរ៉េ) និង អិនប៉េកា (NPK) សែរាំងសីរ៉ូ (១៦.២០.0) អាមេរិចកាំងជាដើម។ ទោះបីជាមានការចាប់ផ្តើមប្រើជីគីមីក៏ដោយ ក៏កម្រិតនៃការប្រើប្រាស់គឺនៅតិចតួចនៅឡើយ ដោយសារកំឡុងពេលនោះមិនទាន់មានការចែកចាយជីគីមីបានដោយសេរីឬទូលំទូលាយនៅតាមទីផ្សារក្នុងស្រុកនៅឡើយទេ។ ជាពិសេស ក្នុងចន្លោះឆ្នាំ១៩៨០-១៩៨៥ ការចែកចាយជីគីមីគឺធ្វើឡើងដោយមានកម្រិត ដូចជា កសិករត្រូវ មានប័ណ្ណ មានឈ្មោះ និងចំនួនជីគីមីជាក់លាក់ (ជីម៉ូហ្វូស) និងត្រូវទៅបើកជីនៅមន្ទីរពាណិជ្ជកម្ម ការិយាល័យពាណិជ្ជកម្ម និង នៅតាមឃុំ (សាលាឃុំ) និងត្រូវបង់លុយមួយចំនួនផងដែរជូនរដ្ឋ ហើយរដ្ឋជាអ្នកចែកជីដល់កសិករ។

កសិករភាគច្រើន (៦៩.១% នៃអ្នកផ្តល់ព័ត៌មានចំនួន៦៨នាក់) បានប្រាប់ថា មិនបានប្រើប្រាស់ថ្នាំពុលគីមី ឬ ថ្នាំពុលធម្មជាតិនោះទេ ដោយសារតែស្រូវនាពេលនោះ គ្មានសត្វល្អិតឬរោគបំផ្លាញច្រើនដូចស្រូវបច្ចុប្បន្ន (ពូជស្រូវទំនើបថ្មី) នោះឡើយ។ មានករណីតិចតួចប៉ុណ្ណោះ ដែលស្រូវប្រពៃណីមានជំងឺ ដែលជម្ងឺទាំងនោះមិនបង្កបញ្ហាខ្លាំងក្លានោះទេ។ ជម្ងឺទាំងនោះមានដូចជា ក្រាស៊ីក្រាទឹក ក្រាភ្លើង ជាដើម។ ចំណែកឯសត្វចង្រៃបំផ្លាញស្រូវវិញក៏មិនសូវសម្បូរដែរ។ ជាទូទៅ មានតែសត្វកណ្តុរ ឬសត្វស្រឹង។ ដើម្បីកំចាត់ជម្ងឺទាំងនេះ ឬដេញសត្វកណ្តុរ កសិករបានប្រើប្រាស់វិធីសាស្ត្រធម្មជាតិដោយប្រើ ស្លឹកស្តៅ បណ្តូលពេជ្រ ថ្នាំជក់ ដើម្បីព្យាបាលជម្ងឺក្រាទឹក ក្រាភ្លើង និងដេញសត្វស្រឹងជាដើម។ មានកសិករតិចតួចប៉ុណ្ណោះ ប្រមាណជា១៧.២% នៃកសិករ៦៨នាក់ បានប្រើប្រាស់ថ្នាំពុលគីមីដូចជា អង់ទ្រីន និង ដេដេតេ (DDT)។ ប៉ុន្តែកម្រិតនៃការប្រើប្រាស់គឺនៅតិចតួច។ ការប្រើប្រាស់ថ្នាំពុលគីមីទាំងនេះ ចាប់ផ្តើមមានជាបណ្តើរៗនៅក្រោយឆ្នាំ១៩៨៥។

## ឃ. ប្រភពកម្លាំងពលកម្ម និងទឹក

ការប្រើប្រាស់កម្លាំងគោក្របី និង ការប្រវាស់ដៃគ្នា ការជួយគ្នាទៅវិញទៅមករបស់កសិករក្នុងភូមិ គឺជាប្រភពកម្លាំងពលកម្មដ៏សំខាន់មួយ សម្រាប់ការភ្ជួររាស់ ដកស្ទូង ថែទាំនិងប្រមូលផល។ កសិករចំណាយតិចតួចបំផុតទៅលើកំលាំងពលកម្មទាំងនេះ ដូចជាចំណាយទៅលើអាហារក្នុងកំឡុងពេលធ្វើការតែប៉ុណ្ណោះ។ កសិករភាគច្រើន (៦៦.៧% នៃអ្នកផ្តល់ព័ត៌មានចំនួន៤៥នាក់) មិនបានរាប់ការចំណាយទាំងនេះថាជាចំណាយទៀតផង ពីព្រោះពួកគាត់រាប់ការចំណាយទៅលើអាហារ ជាការចំណាយប្រចាំថ្ងៃរបស់គាត់ ហើយពួកគាត់ជួយគ្នាទៅវិញទៅមក ដូចនេះមានន័យថា ម្តងនេះគ្រួសារគាត់ជាអ្នកចំណាយ លើកក្រោយគឺគ្រួសារអ្នកភូមិផ្សេងទៀតជាអ្នកចំណាយវិញម្តង។ ចំណែកឯ ការប្រើប្រាស់កំលាំងគ្រឿងចក្រ ដូចជាគោយន្តវិញ គឺស្ទើរតែគ្មាននោះទេនៅក្នុងកំឡុងឆ្នាំ១៩៨០រហូតដល់ឆ្នាំ១៩៩០ជាង។ កសិករនៅពឹងផ្អែកទៅលើកម្លាំងគោក្របីនិងការប្រវាស់ដៃគ្នា ជួយគ្នាទៅវិញទៅមកច្រើន។ ពួកគាត់នៅរក្សាបាននូវទំនៀមទំលាប់ពីដូនតា និងស្មារតីជួយគ្នាពីបរមបុរាណ។ កត្តាមួយចំនួនដែលអាចអោយកសិករនាពេលនោះរក្សាបាននូវទំនៀមទំលាប់ទាំងនេះ គឺទី១៖ នៅពេលកំឡុងទសវត្សឆ្នាំ៨០និងឆ្នាំ៩០ ប្រជាកសិករធ្វើស្រែជាទូទៅគឺផ្តោតខ្លាំងសម្រាប់ចិញ្ចឹមគ្រួសារនិងមានលក្ខណៈទ្រង់ទ្រាយតូច និងធ្វើតាមទំលាប់។ ទី២៖ ប្រជាកសិករជាពិសេសយុវជននិងយុវនារីមិនទាន់ចំណាកស្រុក ឬចាកចេញពីស្រុកច្រើនដើម្បីទៅបម្រើការងារនៅក្នុងរោងចក្រ កម្មករសំណង់ ឬទៅប្រទេសក្រៅដូចបច្ចុប្បន្ននៅឡើយ។ នេះអាចអោយពួកគាត់មានកម្លាំងគ្រប់គ្រាន់នៅក្នុងភូមិសម្រាប់ជួយគ្នា។ ទី៣៖ កាលនោះគឺមិនទាន់មានការនាំចូល ហូរចូលឬការដាក់លក់នូវគ្រឿងចក្រ ដូចជាគោយន្ត ឬត្រាក់ទ័រច្រើនដូចបច្ចុប្បន្ននោះឡើយ។ កសិករក៏មិនទាន់មានទំលាប់ក្នុងការប្រើប្រាស់គ្រឿងចក្រទាំងនោះដែរ។

ប្រភពទឹកសម្រាប់ធ្វើស្រែគឺជាបញ្ហាសំខាន់សម្រាប់កសិករតាំងពីសម័យមុនៗមកដល់កំឡុងទសវត្សឆ្នាំ៨០និង៩០។ ទឹកភ្លៀងគឺជាប្រភពទឹកដ៏សំខាន់បំផុតសម្រាប់ការធ្វើស្រែរបស់កសិករ បន្ទាប់មកមានទឹកបឹងត្រពាំងស្ទឹង និងប្រឡាយចាស់ៗដែលសល់ពីសង្គម ដូចជាប្រឡាយពីជំនាន់ប៉ុលពត/ខ្មែរក្រហមជាដើម។ ការពឹងផ្អែកខ្លាំងទៅលើទឹកភ្លៀង ធ្វើអោយកសិករប្រឈមនិងហានិភ័យ ដោយសារតែភ្លៀងធ្លាក់មិនទៀងទាត់ និងកង្វះអាងឬប្រឡាយថ្មីៗសម្រាប់ស្តុកទឹកទុកសម្រាប់ធ្វើស្រែនៅពេលដែលភ្លៀងធ្លាក់មិនទៀងទាត់ឬរាំងស្ងួតជាដើម។

### ង ការចំណាយសម្រាប់ការធ្វើស្រែរបស់កសិករ

ការចំណាយក្នុងការធ្វើស្រែរបស់កសិករ គឺ អស់តិចតួចបើតាមកសិករលើកឡើង។ ជាមធ្យម កសិករចំណាយអស់២៥ម៉ឺនរៀល ចំនែកឯចំណាយទាបបំផុតគឺអស់២ម៉ឺនរៀល។ កសិករចំណាយទាបដោយសារពួកគាត់នៅប្រើប្រាស់កម្លាំងសត្វគោក្របីសម្រាប់អូសទាញ និង នៅបន្តស្មារតីជួយគ្នាជាកម្លាំង ការប្រវាស់ដៃគ្នារវាងសមាជិកក្នុងភូមិក្នុងការធ្វើស្រែ ការប្រើប្រាស់ជីធម្មជាតិដែលពួកគាត់មាន និង ប្រើប្រាស់ពូជប្រពៃណីដែលគាត់សន្សំពីដូនតារបស់គាត់មក។ ខណៈមានកសិករមួយចំនួនតូចប៉ុណ្ណោះ(៧.៤% នៃអ្នកបានផ្តល់ព័ត៌មានចំនួន៦៨នាក់) បានចំណាយខ្ពស់បំផុតអស់ដល់ទៅ១លានប្រាំសែនរៀលក្នុងស្រែ១ហិកតាក្នុង១រដូវ។ នេះដោយសារគាត់ចាប់ផ្តើមប្រើប្រាស់នូវគោយន្តមានជួលកំលាំងមនុស្សខ្លះៗ ទិញពូជថ្មី និងទិញជីគីមីលាយជាមួយជីធម្មជាតិ ឬប្រើជីគីមីសុទ្ធតែម្តង ពិសេសនៅក្នុងកំឡុងក្រោយឆ្នាំ ១៩៩៧មក នៅពេលដែលកសិករចាប់ផ្តើមប្រើពូជថ្មីនិងពង្រីកដីសម្រាប់ធ្វើស្រែប្រាំង។

### ច. ការប្រមូលទិន្នផលស្រូវ ការផ្គត់ផ្គង់ក្នុងគ្រួសារ

កសិករទាំងអស់ធ្វើស្រូវដើម្បីផ្គត់ផ្គង់ក្នុងគ្រួសារ (បរិភោគ) ហើយពាក់កណ្តាលនៃពួកគាត់ ធ្វើស្រូវសម្រាប់បរិភោគផង និងលក់ផង។ ពួកគាត់លក់ស្រូវដែលនៅសល់ពីហូប ប៉ុន្តែក៏មានអ្នកខ្លះទៀតយកស្រូវដែលសម្រាប់ផ្គត់ផ្គង់គ្រួសារទៅលក់ផងដែរ ដើម្បីបានចំណូលសម្រាប់ការចំណាយទៅលើតម្រូវការផ្សេងៗទៀត។ ចំពោះទិន្នផលស្រូវវិញ កសិករភាគច្រើន (៨៦.៨ %នៃអ្នកផ្តល់ព័ត៌មាន៥៣នាក់) អាចទទួលបានទិន្នផលស្រូវចាប់ពី១ទៅ៣តោនក្នុងមួយហិកតា។ មានកសិករតិចតួចប៉ុណ្ណោះបានទិន្នផលស្រូវក្រោមមួយតោនក្នុង១ហិកតា និងកសិករចំនួនតិចតួចបំផុតដែលមានបទពិសោធធ្វើស្រែបានទិន្នផលច្រើនជាង៣តោនក្នុងមួយហិកតា។ កត្តាចំបងដែលនាំអោយកសិករទទួលបានទិន្នផលតិចជាង៣តោនក្នុងមួយហិកតា គឺ កត្តាភ្លៀងធ្លាក់មិនទៀងទាត់ឬរាំងស្ងួត ប្រើប្រាស់ជីធម្មជាតិបានតិច ដីស្រែមិនសូវមានជីវជាតិនិង ការព្រួសគ្រាប់ស្រូវចោលនិងថែទាំស្រូវមិនបានល្អ។

ជាមួយនឹងទិន្នផលដែលទទួលបាន កសិករភាគច្រើន (៧៧.២% នៃ៥៧នាក់ដែលផ្តល់ព័ត៌មាន) ហូបនិងផ្គត់ផ្គង់គ្រួសារបានគ្រប់គ្រាន់។ ប៉ុន្តែនៅមានកសិករ មួយចំនួនតូច (២២% នៃចំនួនអ្នកផ្តល់ព័ត៌មានដដែល) ជួបការខ្វះខាត ខ្វះស្រូវ អង្ករសម្រាប់ហូបអោយគ្រប់មួយឆ្នាំ។ សម្រាប់អ្នកដែលខ្វះហូប មានអ្នកខ្លះខ្វះចាប់ពី១ទៅ៣ខែ និងគ្រួសារខ្លះខ្វះដល់ទៅ៦ខែ។ ដើម្បីដោះស្រាយកង្វះហូបនេះ

កសិករបានខ្ចីស្រូវអង្ករពីអ្នកភូមិជិតខាង ឯអ្នកខ្លះទៀតខ្ចីលុយគេដើម្បីទិញអង្ករហូប ទិញគេដោយជំពាក់សិន និងលក់មាន់ ទា សត្វចិញ្ចឹមផ្សេងៗទៀតដើម្បីដោះស្រាយ។

### ឆ. ទីផ្សារ (អំណាចក្នុងការគ្រប់គ្រងទីផ្សារ និងតម្លៃ)

នៅទសវត្សឆ្នាំ១៩៨០មកដល់មុនឆ្នាំ២០០០ ឃើញថា ទីផ្សារនិងអ្នកទិញស្រូវ អង្កររបស់កសិករមាន ៤ សំខាន់ៗ។ ទី១គឺ ឈ្មួញទាំងក្នុងខេត្តនិងមកពីក្រៅខេត្ត (៥៣.៧%)។ ទី២ គឺ រដ្ឋ (២៦.៨%) ជាពិសេសគឺកំឡុងឆ្នាំ១៩៨០មក១៩៨៥ ដែលនៅកំឡុងពេលនោះ រដ្ឋបានចុះទិញស្រូវពីកសិករនៅតាមស្រុក ឃុំនីមួយៗ។ ប៉ុន្តែក្រោយមក រដ្ឋបានផ្អាកឈប់ប្រមូលទិញស្រូវពីកសិករជាពិសេសក្រោយឆ្នាំ១៩៨៥មក ដោយសាររដ្ឋបាប់ផ្តើមបើកទីផ្សារអោយឈ្មួញឯកជនជាអ្នកប្រមូលទិញវិញម្តង។ ទី៣ រោងម៉ាស៊ីនកិនស្រូវ ផលិតអង្ករក្នុងស្រុក (១២.២%)។ ទី៤ គឺ អ្នកភូមិរស់នៅក្នុងភូមិជាមួយគ្នាដែលសុំចែកអង្ករឬស្រូវសម្រាប់ហូបបន្ត (៧.៣%)។ ជាទូទៅ ការទិញលក់ស្រូវ អង្ករគឺធ្វើឡើងនៅក្នុងស្រុក ឃុំ ភូមិនីមួយៗដែលកសិកររស់នៅ។ សម្រាប់ឈ្មួញ ជាទូទៅគេបានចុះទៅទិញដល់ផ្ទះនិង នៅស្រែរបស់កសិករ។ ចំណែកឯរោងម៉ាស៊ីនកិនស្រូវក្នុងស្រុកវិញ គឺកសិករត្រូវដឹកជញ្ជូនទៅដល់កន្លែងរ៉ោងម៉ាស៊ីនកិនស្រូវតែម្តង។ ចំពោះតម្លៃស្រូវ អង្ករវិញ សម្រាប់អ្នកដែលលក់ទៅអោយរដ្ឋបានចែករំលែកថា រដ្ឋគឺជាអ្នកកំណត់តម្លៃ ហើយតម្លៃវិញគឺសមរម្យអាចទទួលយកបាន និង អ្នកខ្លះប្រាប់ថា លក់បានថ្លៃ។ សម្រាប់ពួកគាត់ តម្លៃសមរម្យ មានន័យថា គាត់អាចសល់បានចំណេញខ្លះក្រោយពីទូទាត់លើការចំណាយផ្សេងៗសម្រាប់ធ្វើស្រែ ម្យ៉ាងទៀតដោយសារតែចំណាយថ្លៃដើមមិនសូវអស់ច្រើន ដូចនេះ គាត់ចំណេញបានសល់ខ្លះសម្រាប់សន្សំនិងចំណាយប្រើប្រាស់ផ្សេងៗ។ សម្រាប់អ្នកដែលលក់ស្រូវទៅអោយឈ្មួញ ក៏បានចែករំលែកផងដែរថា តម្លៃស្រូវគឺឈ្មួញជាអ្នកកំណត់ ហើយជាទូទៅ ស្រូវមានតម្លៃក៏គួសមប្រហាក់ប្រហែលទៅនឹងតម្លៃដែលរដ្ឋទិញផងដែរ។ ប៉ុន្តែក៏មានកសិករមួយចំនួនតូចត្អូញត្អែរថា ស្រូវថោកផងដែរ។ សម្រាប់កសិករដែលលក់ស្រូវ អង្ករអោយទៅអ្នកភូមិជិតខាង ពួកគាត់អាចកំណត់និងចរចារពីតម្លៃជាមួយនឹងអ្នកភូមិគ្នាគាត់បាន។

### ជ. ការគាំទ្រពីរដ្ឋ

ថ្វីត្បិតតែ កំឡុងឆ្នាំ១៩៨០ មកកំឡុងឆ្នាំ១៩៩០ ជាដំណាក់កាលក្នុងការស្តារនូវសេដ្ឋកិច្ច កសិកម្មជាតិក៏ពិតមែន ឃើញថារដ្ឋាភិបាលបានធ្វើការគាំទ្រលើកស្ទួយវិស័យកសិកម្មបានតិចតួចបំផុត។ តាមរយៈកសិករដែលចូលរួមផ្តល់សម្ភាសន៍ ពួកគាត់ភាគច្រើនបំផុត (៧៩.៦% នៃអ្នកផ្តល់ព័ត៌មាន

៥៨នាក់) មិនទទួលបានការគាំទ្រពីរដ្ឋក្នុងការធ្វើស្រែនោះទេ ក្រៅពីការទទួលបានការបែកចែកដីធ្លីសម្រាប់រស់នៅនិងធ្វើស្រែលក្ខណៈគ្រួសារក្នុងកំឡុងក្រោយឆ្នាំ១៩៨៥។ ពួកគាត់ខ្វះខាតទឹក ប្រព័ន្ធធារាសាស្ត្រ និង ទុនជាដើម។ មានកសិករតិចតួចប៉ុណ្ណោះដែលទទួលបានការគាំទ្រដូចជា ពូជ និង ទីផ្សារ (ការទិញស្រូវពីកសិករដោយរដ្ឋជាដើម)។

## ៦.១.២. បទពិសោធ និងស្ថានភាពរបស់កសិករពីឆ្នាំ២០០០ មកឆ្នាំ២០១៧

### ក. ការដាំដុះ និងបច្ចេកទេស

ជាង២ទសវត្សរ៍កន្លងមកនេះ ឃើញថាមានការប្រែប្រួលបន្តិចបន្តួចអំពីស្ថានភាពដីស្រែរបស់កសិករដែលបានចូលរួមក្នុងការសិក្សានេះ។ កសិករច្រើនជាងពាក់កណ្តាល (៥៧% នៃអ្នកផ្តល់សម្ភាសន៍១០០នាក់) មានដីស្រែតិចជាងឬស្មើរនឹងពីរហិកតា ក្នុងនោះពាក់កណ្តាលនៃពួកគាត់ មានដីក្រោម១ហិកតា។ ចំនួនកសិករដែលមានដីតូចជាងពីរហិកតានេះមានការថយចុះប្រមាណជា៧% បើធៀបទៅនឹងចំនួនអ្នកដែលមានដីស្មើរ/តិចជាង២ហិកតា នៅក្នុងកំឡុងឆ្នាំ១៩៨០មកឆ្នាំ២០០០។ នេះដោយសារតែកសិករមួយចំនួនបានពង្រីកដីរបស់ខ្លួនតាមរយៈការទិញដីឬជួលដីបន្ថែម និង ការកាប់រៀនដីព្រៃថ្មីជាដើមដូចនេះដីរបស់ពួកគាត់មានទំហំធំជាងមុន ចំណែកអ្នកខ្លះបានលក់ដីចោលអស់តែម្តងដោយសារការសងបំណុល ចំណាយលើការព្យាបាលសុខភាព ចែកដីអោយកូនដែលទើបនឹងរៀបការរួច និង ការចំណាកស្រុកទៅរកការងារនៅក្នុងទីក្រុងភ្នំពេញ ខេត្តផ្សេងៗទៀត និងទៅក្រៅប្រទេសដូចជាប្រទេសថៃជាដើម ។ កសិករ២៨%ទៀតមានដីច្រើនជាង២ហិកតាទៅ៥ហិកតា និងក្រៅពីនេះ កសិករចំនួនតិចតួចប៉ុណ្ណោះ មានដីធំជាង៥ហិកតា។ នេះក៏បង្ហាញអំពីគម្លាតខ្លាំងរវាងចំនួនអ្នកមានដីច្រើនជាង៥ហិកតា និង អ្នកមានដីតិចផងដែរ។

ការធ្វើស្រែរបស់កសិករគឺមានការប្រែប្រួលយ៉ាងខ្លាំង ដោយសារតែកសិករងាកមកធ្វើស្រែប្រាំងយ៉ាងគំហុក បន្ថែមទៅនឹងការធ្វើស្រែវស្សារបស់ពួកគាត់ដែលមានស្រាប់។ កសិករស្ទើរតែពាក់កណ្តាល (៤៧.៩ ភាគរយនៃអ្នកផ្តល់ព័ត៌មានចំនួន៩៦នាក់) បានធ្វើទាំងស្រែប្រាំងនិងស្រែវស្សា។ ការងាកមកធ្វើស្រែប្រាំងនេះ បណ្តាលមកពីហេតុផលចំបងៗមួយចំនួនដូចជា ការហូរចូល

ការចែកចាយយ៉ាងទូលំទូលាយ និងការផ្សព្វផ្សាយខ្លាំងអំពីពូជទំនើបថ្មីពិសេសគឺពូជស្រែប្រាំងនិងពូជស្រូវមិនប្រកាន់រដូវ និងតម្រូវការទីផ្សាររបស់ឈ្មួញទោះលើពូជទាំងនេះចាប់ផ្តើមមាន ពិសេសឈ្មួញទិញនាំចេញទៅប្រទេសវៀតណាម និង ប្រទេសថៃ (*សូមមើលតារាង៣៖ ពូជទំនើបថ្មីរួមមានពូជសម្រាប់ស្រែប្រាំង ដែលមាននៅក្នុងផ្នែកអំពីការប្រើប្រាស់ពូជ*)។

បច្ចេកទេសធ្វើស្រែ មានការប្រែប្រួលខ្លាំង ដោយសារតែកសិករភាគច្រើនបំផុត (៧៨.៤% នៃអ្នកផ្តល់ព័ត៌មានចំនួន៨៨នាក់) បានប្តូរពីការធ្វើស្រែបែបប្រពៃណីដូចជាកាស្ទូងសំណាប ភ្ជួររាស់ដី ការប្រើប្រាស់ជីធម្មជាតិ ពូជបុរាណជាដើម មកជាការព្រួសគ្រាប់ស្រូវនិងរងចាំទទួលផលតែម្តង។ ខណៈការធ្វើបែបប្រពៃណីបានធ្លាក់ចុះយ៉ាងខ្លាំង មកនៅត្រឹម២១.៦% ប៉ុណ្ណោះ ដែលកសិកររក្សាបាននូវការធ្វើស្រែដោយការភ្ជួរ ស្ទូងសំណាប ដូចពីមុន។ កត្តាមួយក្នុងចំណោមកត្តាផ្សេងៗទៀតដែលបង្ករអោយមានការប្រែប្រួលនេះ គឺ មកពីកង្វះកម្លាំងពលកម្មព្រោះយុវជននិងកសិករដែលជាបុរសបានចំណាកស្រុកច្រើនដែលធ្វើឲ្យខ្វះកម្លាំងពលកម្មនៅក្នុងស្រុក។

កសិករ បានបង្កើននូវចំនួននៃការធ្វើស្រែច្រើនជាងពីរដង ហើយចំនួនកសិករដែលធ្វើស្រែច្រើនជាង២ដងក្នុងមួយឆ្នាំបានកើនឡើង៤២% (ពី១១.៣% នៅមុនឆ្នាំ២០០០ មក៣.៨% នៅពេលបច្ចុប្បន្ន)។ កសិករអាចបង្កើនវដ្តនៃការដាំដុះនេះ ដោយសារ ទី១ គឺ ពួកគាត់ប្រើប្រាស់ពូជទំនើបថ្មីពិសេសប្រភេទស្រូវមិនប្រកាន់រដូវដែលផ្តល់ផលបានលឿន (៩៥ទៅ១០៥ថ្ងៃ) ហើយពូជទាំងនេះផ្តល់ទិន្នផលខ្ពស់ចាប់ពី៣តោនទៅ៥តោនកន្លះក្នុងមួយហិកតា។ ទី២ គឺ ពួកគាត់ធ្វើស្រែដោយផ្តោតខ្លាំងទៅលើការផលិតដើម្បីលក់ ដែលឆ្លើយតបទៅនឹងតម្រូវការទីផ្សារ ដែលនេះក៏ស្របទៅនឹងការជម្រុញនូវកំណើនផលិតកម្មស្រូវនៅក្នុងគោលនយោបាយផលិតកម្មស្រូវ និងនាំអង្ករចេញអោយបានមួយលានតោន (១,០០០,០០០តោន) របស់រាជរដ្ឋាភិបាល ពិសេសក្នុងកំឡុងឆ្នាំ ២០១៥ ហើយនិន្នាការនេះនូវបន្តរហូតមកដល់ឆ្នាំ២០១៧នេះតែម្តង។

## ខ. ការប្រើប្រាស់ពូជ

ជាង២ទសវត្សចុងក្រោយនេះ ជាពិសេសកំឡុងក្រោយឆ្នាំ២០០៣ និន្នាការនៃការប្រើប្រាស់ពូជទំនើបថ្មី (ទាំងប្រភេទស្រូវស្រាល និង ស្រូវធ្ងន់) មានការកើនឡើងខ្លាំងជាបន្តបន្ទាប់ និងកើនឡើងជាគំហុកនៅក្នុងចន្លោះឆ្នាំ២០០៨មកឆ្នាំ២០១៤។ តាមការសិក្សា កសិករស្ទើរតែទាំងអស់ (៩៥% នៃអ្នកផ្តល់ព័ត៌មានចំនួន ១០០នាក់) កំពុងតែប្រើប្រាស់ទាំងពូជទំនើបថ្មីនិង ពូជប្រពៃណីរបស់ខ្លួន នៅលើដីស្រែផ្សេងគ្នា និងពេលខ្លះនៅលើដីស្រែតែមួយ ប៉ុន្តែដាំឆ្លាស់ឆ្នាំគ្នាទៅតាមបទពិសោធរបស់ពួកគាត់រៀងខ្លួន។ ចំនួននេះកើនឡើង៨២%បើធៀបទៅនឹងភាគរយនៃអ្នកប្រើប្រាស់ពូជទំនើបថ្មីនៅមុនឆ្នាំ២០០០។ ទន្ទឹមនឹងនោះ ចំនួនកសិករដែលប្រើប្រាស់តែគ្រាប់ពូជស្រូវទំនើបថ្មីសុទ្ធ ក៏មានច្រើនដែរ គឺដល់ទៅ៣៣%ឯណោះ។ ខណៈកសិករដែលនៅប្រើប្រាស់ពូជប្រពៃណីសុទ្ធវិញ គឺនៅមានចំនួនតិចតួចបំផុត (៥%)។ ជាលទ្ធផល ការថយចុះនៃការប្រើប្រាស់ពូជប្រពៃណីនេះ ក៏បានបណ្តាលអោយមានបាត់បង់និងថយចុះនូវចំនួននៃប្រភេទពូជប្រពៃណីជាច្រើនផងដែរ។ តាមការសិក្សា ឃើញថាចំនួនពូជប្រពៃណី ដែលកសិករប្រើប្រាស់កន្លងមកមានច្រើនពី៣០ទៅ៥០មុខជាងនៅក្នុងខេត្តនីមួយៗ ប៉ុន្តែមកដល់ពេលបច្ចុប្បន្ន មានពូជប្រពៃណីនៅសល់ប្រហែលជា១០មុខជាងតែប៉ុណ្ណោះក្នុងខេត្តនីមួយៗដែលកសិករនៅប្រើប្រាស់*(សូមមើលតារាង២៖ ពូជប្រពៃណីដែលកសិករធ្លាប់ប្រើពីមុន និងកំពុងនៅប្រើប្រាស់)*។

**តារាង២៖ ពូជប្រពៃណីដែលកសិករធ្លាប់ប្រើពីមុន និងកំពុងនៅប្រើប្រាស់នាពេលបច្ចុប្បន្ន ដកស្រង់ពីកសិករដែលផ្តល់បទសម្ភាសន៍**

| ឈ្មោះខេត្ត | ពូជប្រពៃណីដែលកសិករបានប្រើប្រាស់និងមាននៅក្នុងស្រុកកន្លងមក | ពូជដែលកំពុងប្រើប្រាស់ពេលក្នុងបច្ចុប្បន្ន |
|---|---|---|
| តាកែវ | **ស្រូវស្រាល**<br>អង្កុក កំពីងពួយ ហាបា កូនក្រាញ់ សណ្តាយកន្លះ នាងនូ ដំណើបស្នាល់ ខ្ពដូង ក្រចកជៀស ពងលលក សុម៉ាលី ខ្លឹមមៀន នាងកុក អញ្ចូលកន្លះ ស្រូវរំចូលកន្លះ | ជលសា កំពីងពួយ អង្កុក ផ្កាម្លិះ កូនក្រាញ់ សុម៉ាលី |
| | **ស្រូវកណ្តាល**<br>ដំណើបក្រសាំង គង់សរ ដំណើបឈូក ដំណើបក្រចកសេះ ផ្កាខ្ញី ដំណើបខ្នងជំរី ដំណើបមាន ១០០ជ័យ ចំរើនផល កុកក្តឹក ស្រូវខ្លី នាងចិន ស្រូវពងលលក ក្រចកសេះ ពូជគង់សនាងស្មើ ពូជកុកកន្តឹក ស្រូវរំចូល បីគួរ ដំណើបផ្គាល់ហ៊ីង ចុងបន្លា | ពងលលក បីគួរ ផ្កាខ្ញី ដំណើបក្រចកសេះ |
| | **ស្រូវធ្ងន់**<br>នាងមាស ផ្កាទៀន គង់កំបុត អង្គរជ័យ ផ្កាស្លាធ្ងន់ នាងជុំ ដំណើបខ្មៅ គង់ទាប ស្រូវឡើងទឹក សណ្តាយធំ ស្រូវក្រហម ដំណើបឈូក កូនត្រី ផ្កាដូង ចង្កោរំពាក់ លាក់សន្លឹក ១០០ជ័យ ផ្កាស្លា | នាងជុំ ផ្កាស្លា |
| កំពង់ឆ្នាំង | **ស្រូវស្រាល**<br>អង្គជ់ខ្សាច់ ក្រសាំងទាប បន្ទុះភ្លុក ជាយស្បៃ ផ្ការំចង់ គ្លានមាន | ផ្កាម្លិះ |
| | **ស្រូវកណ្តាល**<br>ដំណើបខ្មៅ ឆ្អឹងជំរី ឈាបអន្ទង់ ដំណើបក្រចកចាប នាងសរ ឆ្មាព្រំ ផ្កាស្លា ពងអង្រ្កង ចង្កៀកផ្តៅ សំបុកអង្រ្កង នាងនយ កូនត្រី ចុងបន្លា បន្ទុះភ្លុក អូសទូក ខ្នងរមាំង ល្វាយ រិទ្ធ | សំបុកអង្រ្កង ចម្រៀកផ្តៅ,ថ្មរមាំង<br>ចុងបន្លា ផ្កាខ្ញី នាងហម សុម៉ាលី |

| | | |
|---|---|---|
| | ក្អិត ពូជពងហ៊ីង ចង្រៀកផ្កៅ នាងហម សុម៉ាលី | ដំណើបក្រចកចាប |
| | **ស្រូវធ្ងន់**<br>សញ្ចឹក សអង្វើល ចង្វារ នាងមិញ ដំណើបឆ្អឹងពស់ ផ្ការំចេក នាងឫស ធកន្ទុយខ្មៅ ខ្ពរដូង នាងសរ ស្រូវពក ភ្នំរុន ភ្នាព្រំ ឆ្មើរ រិទ្ធសរ កន្ទុយខ្មៅ ពូជលាក់សន្លឹក រំអែងសាឡី នាងគង់ខ្សាច់ ពូជនាងកុក ពងអង្រ្កង ផ្កាស្លា | ខ្ពរដូង អន្សរ កន្ទុយទូក នាងមិញ ដំណើបឆ្អឹងពស់ ផ្កាស្លា |
| កំពង់ធំ | **ស្រូវស្រាល**<br>នាងមាស ជីកែង នាងគង់ក្រអូប សរកាមួន នាងគួយ មាសសរ ខ្ញុំ ចន្ទុះប្លុក | ដំណើបនាងនុ ដំ.ក្រចកចាប ផ្កាម្លិះ |
| | **ស្រូវកណ្តាល**<br>ដំណើបនាងនួក ដំណើបត្នោត ព្រុំ ណូយ ដំណើបក្រចកចាប ដំណើបស្លាប ដំណើបនាងនុ មរម្យ នាងវែក សាមលាវ | |
| | **ស្រូវធ្ងន់**<br>លាក់សន្លឹក ចង្វាយផ្កៅ ព្រិច សេងប៊ូ ប្រពាយ ស្ទាំង ចិញ្ចើមប្រវឹក ៦គួរ ស្រូវនាងស ពពាយឡឿងទឹក ស្រូវណូយ នាងគង់ខ្សាច់ កន្ទុយដំរី គុលដូង អង្គង់គ្រើល ៨គួរ ប្រពាយក្រហម ផ្កៅពេន នាងមាន់ កំពីងពួយ ស្រូវព្រិច សំបុកអង្រ្កង | នាងគង់ខ្សាច់<br>ម្លិ ព្រុំ ខ្ញុំ |
| បាត់ដំបង | **ស្រូវស្រាល**<br>ដំណើបទងសង្កែ ដំណើបល្វាវត់ គង់ខ្មៅ | ផ្កាម្លិះ |
| | **ស្រូវកណ្តាល**<br>ដំណើបជាយស្បៃ ដំណើបឈាមអន្ទង់ ដំណើបខ្មៅ ពូជនាងខ្សាច់ ពូជនាងពេជ្យ ពូជគ្រាប់ក្រូច នាងលួច ចង្វាយផ្កៅ ដំណើបពងហ៊ីង ពូជស្មាព្រំ ដំណើបក្រចកចាប ចុងបន្លា | ផ្កាខ្ញី<br>សុម៉ាលី |

| | | |
|---|---|---|
| | សុម៉ាលី ផ្កាខ្ញី | |
| | **ស្រូវធ្ងន់**<br>ពូជកំពឹងពួយ នាងមាស នាងចៅ ផ្កាស្លា ឆ្មាព្រំ ពូជកូនឃ្មុំ ឬ កូនត្រី ពូជនាងស ពនាងលួច សក្រញ៉ាញ់ ចង្កោមរំពាក់ នាងគង់មៅ ពូជគង់កណ្ដា ពូជនាងឡុង ពូជជង្គង់ខ្សាច់ ពូជជង្គង់ខ្មៅ ពូជឆ្អឹងក្របី ពូជកាឡា នាងខុន នាងមិញ | នាងខុន នាងមិញ |
| ព្រៃវែង | **ស្រូវស្រាល**<br>ដំណើបក្រចកសេះ ដំណើបល្អិត ដំណើបគ្រាប់បញ្លក់ ទ្រនិចឃ្មុំ នាងគក់ ប្រពៃ | ដំណើបក្រចកសេះ ដំណើបល្អិត ដំណើបល្អិត |
| | **ស្រូវកណ្ដាល**<br>ដំណើបក្រឡាញ់ ដំណើបត្នោត ដំណើបស្និតចេក ក្រសាំងទាប ដំណើបខ្សាច់ កន្ទុំ៣ ពូជឆ្មា ពូជខ្ទងមាន់ ថ្មក្រឹម នាងពួន ស្រូវក្រហម សំបុកអង្រ្កង ចុងបន្លា ពូជម្រុំ | ក្រសាំងទាប, កូនស្រូវ ស្រូវប្រពៃ, នាងពួនចុងបន្លា កន្ទុំ៣ កូនស្រូវ |
| | **ស្រូវធ្ងន់**<br>នាងខុន បន្លាផ្ដៅ ទងឈូក នាងមិញ នាងមាស នាងនូ នាងសរ បន្លាផ្ដៅ កូនស្រូវ នាងឈូក នាងអ៊ួក | នាងមិញ នាងសរ នាងនូ |

កត្តាចំបងៗដែលជម្រុញអោយមានការកើនឡើងនៃការប្រើប្រាស់ពូជទំនើបថ្មី គឺបណ្ដាលមកពីមានការជម្រុញទៅតាមតម្រូវការទីផ្សារជាពិសេសតម្រូវការសម្រាប់ទីផ្សារនាំចេញ។ ពូជទំនើបថ្មី ជាប្រភេទពូជដែលទីផ្សារត្រូវការ ពិសេសពូជទាំង១០មុខដែលរដ្ឋាភិបាលបានផ្សព្វផ្សាយ និងលើកកំពស់ មានដូចជា សម្រាប់ពូជស្រូវស្រាលមានរយៈពេលខ្លី៖ សែនពិដោរ ជលសារ និង អ៊ីអែ៦៦ រយៈពេលល្មម៖ ផ្ការំដួល ផ្ការមៀត ផ្កា

ចាន់សែនសរ ផ្ការំដេង និង រយៈពេលវែង៖ រាំងជ័យ ខា៤ និង ខា៦ ជាដើម។ ក្រៅពីនេះ ក៏មានពូជទំនើបថ្មីផ្សេងៗទៀតដែលបានចែកចាយនិងផ្សព្វផ្សាយនៅលើទៅផ្សារផងដែរ *(សូមមើលតារាង៣៖ ពូជស្រូវទំនើបថ្មីដែលកសិករកំពុងធ្លាប់ប្រើប្រាស់និងកំពុងប្រើប្រាស់ពេលបច្ចុប្បន្ន)* ។ ពូជទំនើបថ្មី ជាពិសេសពូជស្រូវប្រាំង/ស្រូវមិនប្រកាន់រដូវ អាចអោយកសិករទទួលបានផលរហ័ស (៩០ទៅ១០៥ថ្ងៃ) ឆាប់បានប្រមូលផលលក់

និងផ្តល់ទិន្នផលខ្ពស់ជាងពូជប្រពៃណីធម្មតា ដែលក្នុងមួយហិកតាអាចទទួលបានផលដល់ទៅ៥តោនសម្រាប់ឆ្នាំដំបូង។ ក្រៅពីកត្តាខាងលើ កសិករក៏ទទួលរងឥទ្ធិពលពីអ្នកភូមិជិតខាងគ្នា គឺប្រើប្រាស់ពូជតាមគ្នា។

*"...ពូជទំនើបថ្មីដូចជាពូជផ្ការំដួល និង សែនក្រអូប។ ពិសេសគឺសែន ក្រអូប គឺអាចអោយកសិករធ្វើបាន២ដងក្នុង១ឆ្នាំ ហើយស្រូវ នេះមានតម្រូវការទីផ្សារ គេចូលចិត្តទិញ។ ពូជនេះបានផលច្រើន ក្នុង១ហិកតា បានដល់ទៅ៣ទៅ៤តោនឯណោះ។ ពូជនេះមានតម្លៃជាងពូជនាងមិញ នាងខុន ផ្កាខ្ញី (ពូជបុរាណ) ហើយរហ័សបានប្រមូលផលនិងលក់ ហើយវាជាប្រភេទស្រូវស្រាល មានរយៈពេល៣ខែ..." អ្នកផលិតនិងចែកចាយពូជ ភូមិបាយដំរាំ ឃុំបាយដំរាំ ស្រុកបាណន់ ខេត្តបាត់ដំបង។*




កសិករទទួលបានពូជទំនើបថ្មី ពីប្រភពសំខាន់ៗដូចជា៖ ទី១ កសិករទិញពីអ្នកលក់ឯកជន (៤២.៩% នៃអ្នកផ្តល់ព័ត៌មាន៧៧នាក់) រួមមានទាំងពូជថ្មីផ្សេងៗទៀតដែលនាំចូលពីវៀតណាម និង/ឬលក់ចែកចាយដោយឈ្មួញវៀតណាមនិងឈ្មួញក្នុងស្រុកតែម្តងដូចជាពូជណាំខុងបូង (៥០៤) ដែលសុទ្ធសឹងតែជាពូជស្រែប្រាំង។ ទី២ បានពីទិញឬដោះដូរតគ្នាពីអ្នកភូមិជិតខាង (៣៧.៧%) និងទី៣ បានពីអង្គការមិនមែនរដ្ឋាភិបាលនិងមន្ទីរកសិកម្ម ១៩.៥% ។

*"...ខ្ញុំប្រើពូជថ្មី សម្រាប់ធ្វើស្រែវស្សា មានប្រើពូជផ្ការំដួល (ស្រូវកណ្តាល) ។ ចាប់ប្រើពូជនេះពីឆ្នាំ ២០០៣មក។ ពូជនេះបានពីអង្គការចែកអោយ សម្រាប់ធ្វើជាសហគមន៍។ ចំណែកស្រែប្រាំង ប្រើពូជ ៨៥ (ស្រូវស្រាល)និង ចាប់ផ្តើមប្រើនៅឆ្នាំ ២០០៨។ ពូជនេះទិញពីស្វាយរៀង ព្រៃវែង។ តម្លៃ ១១០០៛ លុយដល់*

*ដៃ។ ពូជនេះទិញគេខ្លះ ទុកខ្លួនឯងខ្លះ។ ប្រើពូជអស់២៥០គីឡូក្នុង១ហិកតា...” កសិករ អ៊ាង ម៉ក់ ស្រី អាយុ ៥៦ឆ្នាំ នៅភូមិ ស្ពានគ្រង ឃុំចំណារក្រោម ស្រុកស្ទោង ខេត្តកំពង់ធំ។*

*“...ពូជថ្មីមានដូចជាពូជផ្ការំដួល (ស្រូវកណ្តាល)។ ពូជនេះបានមកពីដូរគេក្នុងភូមិ។ ពូជថ្មីនេះចាប់ប្រើពីឆ្នាំ ២០១០។ មូលហេតុប្រើពូជថ្មី ព្រោះពេលប្រើទៅឃើញថាវាផ្លែបានល្អ ក្រអូប លក់បានថ្លៃ។ ដំបូង ពូជនេះ បានមកពីគេចែកអោយដោយខាងកសិកម្មស្រុក។ ប្រើពូជអស់៤០០គីឡូ និងចំណាយអស់៤០០០០ រៀល ក្នុងមួយឆ្នាំ...” រ៉ែន អុល ស្រី អាយុ៣៦ឆ្នាំ ឃុំចំណាក្រោម ស្រុកស្ទោង ខេត្តកំពង់ធំ។*

**តារាង៣៖ ពូជទំនើបថ្មីដែលកសិករបានប្រើប្រាស់កន្លងមកនៅក្នុងខេត្តនីមួយៗ ដកស្រង់ចេញពីកសិករដែលផ្តល់បទសម្ភាសន៍**

| ឈ្មោះខេត្ត | ពូជទំនើបថ្មីដែលប្រើប្រាស់កន្លងមក | ពូជទំនើបថ្មីដែលកំពុងពេញនិយម និងប្រើប្រាស់ក្នុងពេលបច្ចុប្បន្ន |
|---|---|---|
| តាកែវ | **ស្រូវស្រាល**<br>អ៊ីអ៊ែ (៦៦) ណាំខុងបូង អ៊ីអ៊ែ(៧៥) (៦០) (៥៥) (៨៥) (៤២) (៣០) និង (៣៦) ក្រមុំឃ្យូន ផ្កាម្លិថៃ/ស្រងែ ពូជរីចយ | អ៊ីអ៊ែ (៦៦) ណាំខុងបូង អ៊ីអ៊ែ (៧៥) (៦០) (៥៥) (៤៦) និង (៤២) |
| | **ស្រូវកណ្តាល**<br>ផ្ការំដួល | ផ្ការំដួល |
| | **ស្រូវធ្ងន់**<br>រាំងជ័យ | រាំងជ័យ |
| កំពង់ឆ្នាំង | **ស្រូវស្រាល**<br>សែនពិដោ ស្រអែមជាប់ចាន ស្រូវរ៉ូយាល់ ផ្កាម្លិ (ថៃ) | សែនក្រអូប<br>ណាំខុងបូង(៥០៤) |
| | **ស្រូវកណ្តាល**<br>មានពូជផ្ការំដួល ផ្ការំដេង ផ្កាចាន់សែនសរ | ផ្កាចាន់សែនស ផ្ការរំដួល ផ្ការំចេក ផ្ការំចង់ |
| | **ស្រូវធ្ងន់**<br>រាំងជ័យ ពូជខា៦ | ខា៩ ខា៥ ខា៦ ខា២ រាំងជ័យ |

| | | |
|---|---|---|
| កំពង់ធំ | **ស្រូវស្រាល**<br>អ៊ីអ៊ែរ (៨៥) (៦៦) និង (៥៣) | ណាំខុងបូង<br>អ៊ីអ៊ែរ (៦៦) និង (៥៥) |
| | **ស្រូវកណ្ដាល**<br>ផ្ការំដួល ផ្កាម្លិ | ផ្ការំដួល |
| | **ស្រូវធ្ងន់**<br>រាំងជ័យ | រាំងជ័យ |
| បាត់ដំបង | **ស្រូវស្រាល**<br>ពូជសែនពិដោ ពូជខ្ញីតឿ ម្លិស្រាល ម៉ាក្រិក ពូជផ្កាម្លិះស្រង៉ែ ពូជថងខារ ខ្ញីទីម្លិះ សែនក្រអូប ណាំខុងបូង | សែនក្រអូប ថងខារ ម្លិ<br>សែនពិដោរ |
| | **ស្រូវកណ្ដាល**<br>ផ្ការំដួល ម្លិះ | ផ្ការំដួល សែនក្រអូប |
| | **ស្រូវធ្ងន់** | រាំងជ័យ |
| ព្រៃវែង | **ស្រូវស្រាល**<br>ណាំខុងបូង | ណាំខុងបូង, អ៊ីអ៊ែរ (៥៤) និង (៦៦) |
| | **ស្រូវកណ្ដាល**<br>ផ្ការំដួល | ផ្ការំដួល |
| | **ស្រូវធ្ងន់** | |

តារាង ៣.១៖ ប្រភេទពូជថ្មីដែលអភិវឌ្ឍដោយកាឌី ដកស្រង់ចេញពី (ប្រភពឯកសារ៖ http://www.cardi.org.kh)

| ល.រ | ទម្រង់គ្រាប់ពូជ និង ឈ្មោះពូជ |
|---|---|
| ១ |  ផ្ការមៀត (Phka Romeat) |

| | |
|---|---|
| ២ |  ផ្ការំដេង (Phka Rumdeng) |
| ៣ |  ទេវតា (Tewada) |
| ៤ |  ខៅតាពេជ្រ (Khao Tah Petch) |
| ៥ |  ដូន  (Don) |
| ៦ |  ផ្ការំចេក (Phka Rumchek) |
| ៧ |  ផ្ការំចង់ (Phka Rumchang) |
| ៨ |  ផ្ការំដួល (Phka Rumduol) |
| ៩ |  សន្តិភាព៣ (Santepheap3) |
| ១០ |  សន្តិភាព២ (Santepheap2) |
| ១១ |  សន្តិភាព១ (Santepheap1) |
| ១២ |  រាំងជ័យ (Raing Chey) |

| | |
|---|---|
| ១៣ |  សារីកា (Sarika) |
| ១៤ |  ពពូល (Popoul) |
| ១៥ |  ខា១៣ (Car 13) |
| ១៦ |  ខា១២ (Car 12) |
| ១៧ |  ខា៩ (Car 9) |
| ១៨ |  ខា៨ (Car 8) |
| ១៩ |  ខា៧ (Car 7) |
| ២០ |  ខា៦ (Car 6) |
| ២១ |  ខា៥(Car 5) |
| ២២ |  ខា៤ (Car 4) |
| ២៣ |  ខា៣ (Car 3) |

| | |
|---|---|
| ២៤ |  ខា២ (Car 2) |
| ២៥ |  ខា១ (Car 1) |
| ២៦ |  រំពេរ (Rumpe) |
| ២៧ |  រហាត់ (Rohat) |
| ២៨ |  ជលសា(Chulsa) |
| ២៩ |  បារ៉ាយ(Baray) |
| ៣០ |  អ៊ីអ៊ែរ កេសរ (IR kesar) |
| ៣១ |  គ្រូ (Kru) |
| ៣២ |  អ៊ីអ៊ែរ៧២ (IR 72) |
| ៣៣ |  អ៊ីអ៊ែរ៦៦ (IR 66) |
| ៣៤ |  សីតា (Sida) |

| | |
|---|---|
| ៣៥ |  សីតា (Sida) |

សម្រាប់កសិករឬសហគមន៍កសិកម្មដែលផលិតពូជលក់វិញ ជាដំបូងពួកគាត់ទទួលបានពូជពីអង្គការមិនមែនរដ្ឋាភិបាល និងបច្ចេកទេសសម្រាប់ផលិតពូជ រួចបន្ទាប់មកពួកគាត់ទិញនិងប្តូរពូជថ្មីបន្ថែមពីវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CARDI) ដែលជាវិទ្យាស្ថានមួយសម្រាប់ធ្វើការស្រាវជ្រាវនិងអភិវឌ្ឍពូជស្រូវនិងដំណាំ ចែកចាយពូជអភិវឌ្ឍថ្មី និង បណ្តុះបណ្តាលបច្ចេកទេសផលិតពូជ និងបច្ចេកទេសនៃការដាំដុះ ការប្រើប្រាស់ជីគីមីជាដើម។ វិទ្យាស្ថាននេះស្ថិតនៅក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងមានការគាំទ្រផ្តួចផ្តើមអោយបង្កើតឡើងដំបូងដោយអង្គការ វិទ្យាសាស្ត្រពូជស្រូវដើម្បីពិភពលោកដ៏ប្រសើរ ហៅកាត់ថា អ៊ីរី (Rice Science for Better World or IRRI) តាំងពីឆ្នាំ១៩៨៧[18]។

*"...សហគមន៍នេះបង្កើតនៅឆ្នាំ២០០៧ ដោយកាលនោះកសិករបានចាប់ផ្តើមជាមួយនឹងការដាក់លុយសន្សំ។ នៅឆ្នាំ២០១៤ អង្គការ ហាវេស ធ្វើឃ្លាំងដាក់ពូជស្រូវនិងអោយពូជស្រូវមកអោយសហគមន៍ មានដូចជាពូជផ្ការំដួល ផ្កាម្លិះ សែនក្រអូប សែនពិដោ។ អង្គការនេះ សហការជាមួយនឹងមន្ទីរកសិកម្មខេត្តបាត់ដំបង។ អង្គការនិងមន្ទីរបានបង្រៀនបច្ចេកទេសផលិតពូជ។ ប៉ុន្តែបច្ចុប្បន្ននេះ ចាប់ពីឆ្នាំ២០១៥មកសហគមន៍ផលិតតែពូជផ្ការំដួលតែមួយប៉ុណ្ណោះ ដោយសារតែវាងាយស្រួលជាងធ្វើពូជច្រើនប្រភេទ។ ពូជផ្ការំដួលនេះបានពី អង្គការហាវេស ហើយទុកផលិតពូជបាន៣ឆ្នាំ (គិតដល់ឆ្នាំ២០១៧នេះឯង) ។ ឆ្នាំបន្ទាប់ត្រូវតែដូរទិញពូជថ្មី គឺទិញពីមន្ទីរកសិកម្មខេត្តបាត់ដំបង ក្នុងតម្លៃ១គីឡូ ២០០០រៀល (គឺពូជធម្មតា មិនមែនពូជសុទ្ធនោះទេ) សម្រាប់ពូជសុទ្ធគឺតម្លៃ ១ដុល្លារ (យកពីការឌី)។ ករណីពូជសុទ្ធគ្រឹះ ត្រូវទិញពី CARDI តម្លៃ ៣.៥ ដុល្លារ។ អង្គការហាវេស យកពូជពីអង្គការ កាឌី។ ពូជនេះ បើស្ងួត ទុកបាន៣ឆ្នាំ តែបើព្រួសវិញ ទុកបានតែ១ទៅ២ឆ្នាំប៉ុណ្ណោះដោយសារតែពូជនេះវាឆាប់ក្លាយ ដូចជា ប្រែទៅជាព៌ណ៌ក្រហម បាត់ក្លិនក្រអូប រសជាតិខ្សោះ ហើយរឹងខុសពីដំបូង ហើយពូជនេះមិនដុះទេ (ដុះបានតែមួយឆ្នាំដំបូងទេ)*

[18] គេហទំព័រនៃវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កម្ពុជា អពីប្រវត្តិនៃការបង្កើត CARDI

*ភាគច្រើន បើទុកមួយឆ្នាំ គឺដុះល្អ តែបើលើសពីមួយឆ្នាំ គឺដុះមិនសូវល្អ ឬមិនដុះតែម្តង។ លុះត្រាតែថែទាំខ្លាំងណាស់។...” កិច្ចសម្ភាសន៍ជាមួយនឹងអ្នកផលិតនិងលក់ពូជ ភូមិខ្វិត ឃុំពង្រ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង។*

ការប្រើប្រាស់ពូជថ្មី ចូលរួមចំណែកធ្វើអោយកើនឡើងនូវចំណាយរបស់កសិករ។ សម្រាប់ពូជស្រូវដែលកសិករធម្មតាទិញសម្រាប់យកមកផលិតស្រូវចំណីឬស្រូវសម្រាប់បរិភោគ គឺមានតម្លៃចន្លោះពី៨០០-២៥០០ រៀលក្នុង១គីឡូក្រាម ហើយកសិករត្រូវទិញពូជថ្មីជារៀងរាល់ឆ្នាំ ឬ២ ទៅ៣ ឆ្នាំម្តងដោយសារតែពូជថ្មីមិនអាចទុកពូជបានយូរ ផ្តល់ផលថយចុះបន្ទាប់ពីឆ្នាំដំបូងឬមិនដុះទាល់តែសោះ និងឆាប់ក្លាយដូចជា ប្តូរពណ៌ទៅជាពណ៌ក្រហម បាយរឹង បាត់ក្លិននិងរសជាតិជាដើម។ ជាងពាក់កណ្តាល (៥៦.១១%) នៃកសិករ បានប្រាប់ថា ពួកគាត់ទិញពូជថ្មីមកប្រើរួចទុកពូជខ្លួនឯងតែប្តូរក្រោយពី១ឆ្នាំទៅ៣ឆ្នាំ (១ជំនាន់ទៅ៣ជំនាន់) ចំណែកកសិករផ្សេងទៀតទិញពូជថ្មីមកប្រើនិងទុកបន្តតែមិនបានបញ្ជាក់ថាពួកគាត់ប្តូរវាទៀតឬបន្តទុករហូតច្រើនជំនាន់នោះទេ ហើយកសិករខ្លះ គឺទើបតែចាប់ផ្តើមប្រើពូជទាំងនេះបាន១ទៅ២ឆ្នាំប៉ុណ្ណោះ។

*“...មានប្រើពូជ អ៊ីអ៊ែ និង ១ឆ្នាំធ្វើ៣ដង។ ពូជនេះមានអាយុកាល៨៥ទៅ៩០ថ្ងៃ។ ...ពូជនេះទិញពីគេរាល់ឆ្នាំ និង ទុកពូជខ្លួនឯងខ្លះ។ ១ បេ (៥០គីឡូ) តម្លៃ៩-១០ម៉ឺនរៀល។ ក្នុង១ឆ្នាំទិញពូជ៤បេ។ ពូជនេះត្រូវទិញពីគេដោយសារតែពូជនេះវាក្លាយ (ដុះខ្ពស់ទាប ប្តូរពណ៌ទៅជាព័ណ៌ក្រហម គ្រាប់វែងខ្លី)។ ស្រូវនេះធ្វើតែសម្រាប់លក់ប៉ុណ្ណោះ។ បើយើងទុកពូជខ្លួនឯង គឺបានតែ១ទៅ២ជំនាន់តែប៉ុណ្ណោះ។ ពូជ អ៊ីអ៊ែរនេះ សំបូរជំងឺ ដូចជា ងាប់ដើម ងាប់ផ្លែ ក្រហមស្លឹក ក្រាស៊ី រលាកករត្ត ជាដើម។...” លោកអ៊ុំសែន ស៊ា អាយុ ៧៤ឆ្នាំ ភូមិ ព្រៃបាសិដ្ឋ ឃុំបាស្រែ ស្រុកអង្គរបុរី តាកែវ*

តាមការសម្ភាសន៍ ជាទូទៅកសិករប្រើប្រាស់ពូជស្រូវអស់ជាមធ្យម ២០៨គីឡូក្រាមក្នុងមួយហិកតាសម្រាប់ការធ្វើស្រែមួយដង។ ចំណែកកសិករខ្លះប្រើប្រាស់ពូជស្រូវអស់ដល់ទៅ៤៨០គីឡូក្រាម។ ការប្រើប្រាស់ពូជច្រើនបែបនេះ គឺដោយសារតែពួកគាត់ព្រួសគ្រាប់ស្រូវញឹក និងដើម្បីចង់បង្កើនទិន្នផលស្រូវ ជាពិសេសចំពោះកសិករដែលប្រើពូជស្រូវប្រាំងឬមិនប្រកាន់រដូវ (ពូជស្រូវខ្លី)។ ប៉ុន្តែក៏មាន

កសិករដែលប្រើប្រាស់ពូជអស់តិចជាងគេបំផុតគឺត្រឹមតែ១៥គីឡូក្រាមប៉ុណ្ណោះ ដោយសារតែគាត់នៅប្រើបច្ចេកទេសបែបស្ទូងស្រូវ១ដើម។

## គ. ការប្រើប្រាស់ជី ការគ្រប់គ្រងសត្វល្អិត និងកត្តាចង្រៃ

ខុសប្លែកពី២០ឆ្នាំមុន កសិករឥឡូវ ភាគច្រើន (៦៣.៨% នៃអ្នកផ្តល់ព័ត៌មាន៩៥នាក់) បានងាកមកប្រើប្រាស់ជីគីមី និង ភាគច្រើនបំផុត (៧៨%នៃអ្នកផ្តល់ព័ត៌មាន១០០នាក់) ប្រើប្រាស់ថ្នាំពុលគីមីនិងសម្លាប់សត្វល្អិតនិងស្មៅចង្រៃ ជំនួសអោយការប្រើប្រាស់នូវថ្នាំធម្មជាតិដូចជា ស្លឹកស្តៅជាដើម។ ចំនួននៃការប្រើប្រាស់ជីគីមីនិងថ្នាំពុលគីមី[19]នេះមានការកើនឡើងខ្ពស់ បើធៀបទៅនឹងតួលេខនៃអ្នកប្រើប្រាស់ជីគីមី (៥៥%) និងថ្នាំពុល (១៧.២%) ក្នុងកំឡុងឆ្នាំ១៩៨០-២០០០។ ការផ្លាស់ប្តូរនេះបណ្តាលមកពីកត្តាទី១៖ ស្រូវ ពិសេសស្រូវពូជទំនើបថ្មីតម្រូវអោយមានការប្រើប្រាស់ជីគីមី ហើយមានរោគច្រើន[20] និងទាក់ទាញសត្វល្អិតច្រើន ដោយសារវាមានក្លិនក្រអូប។ ទី២៖ដោយសារតែការចែកចាយ និងផ្សព្វផ្សាយអំពីជីគីមីនិងថ្នាំពុលមានភាពទូលំទូលាយ និង ងាយស្រួលរកទិញនៅលើទីផ្សារ ហើយម្យ៉ាងទៀតនោះ ថ្នាំពុលគីមីទាំងនេះ វាផ្តល់ផលលឿននិងមានជាតិពុលខ្លាំងអាចសម្លាប់ស្មៅនិងសត្វល្អិតបានរហ័ស។

[19] សូមមើលតារាង៨៖ ឈ្មោះជីគីមីដំពេញនិយមដែលកំពុងប្រើប្រាស់ដោយកសិករដកស្រង់ចេញពីការសម្ភាសន៍

[20] សូមមើលតារាង៨៖ អំពីប្រភេទជំងឺ សត្វល្អិត និងស្មៅដែលស្រង់បានពីការសម្ភាសន៍ដកស្រង់ចេញពីការសម្ភាសន៍

ការប្រើប្រាស់ថ្នាំពុលគីមី បានចាប់ផ្តើមមានតាំងពីឆ្នាំ ១៩៩០ មកម្ល៉េះ ប៉ុន្តែចំនួននៃអ្នកប្រើប្រាស់នៅមានតិចតួចនៅឡើយ។ ចាប់ពីឆ្នាំ ២០១១មក ឃើញថាទំនោរ នៃការប្រើប្រាស់ថ្នាំពុលគីមីរបស់កសិករមានការកើនឡើងជាលំដាប់ ហើយកសិករចាប់ផ្តើមងាកមកប្រើប្រាស់ថ្នាំពុលគីមីខ្លាំងបំផុត គឺនៅកំឡុងឆ្នាំ ២០១២ និងបន្តមកដល់ពេលបច្ចុប្បន្ន។ ការប្រើប្រាស់ថ្នាំបំពុលទាំងនេះ បានផ្តល់បញ្ហាជាច្រើនសម្រាប់កសិករ ដូចជាប៉ះពាល់សុខភាពធ្ងន់ធ្ងរ ធ្វើឲ្យខូចគុណភាពដី ចំណាយច្រើន ប៉ះពាល់ដល់ជីវិតជីវៈចម្រុះ ជាពិសេសសត្វនិងរុក្ខជាតិដែលមានប្រយោជន៍ក្នុងស្រែនិងបរិស្ថានជុំវិញនិងបង្កើតនូវស្មៅចង្រៃនិងសត្វចង្រៃដូចជាដង្កូវប្លែកៗ[21]កាន់តែច្រើនជាដើម។




រូបអំពីថ្នាំពុលកសិកម្មសម្រាប់សម្លាប់ស្មៅនិងសត្វល្អិតដែលកសិករប្រើប្រាស់កន្លងមក នៅស្រុកអង្គរបុរី ខេត្តតាកែវ។ រូបថតដោយ ហ៊ីង សុខហ៊ុល។

ក្នុងចំណោមកសិករដែលផ្តល់បទសម្ភាសន៍១៦នាក់ មានកសិករ១៤នាក់បានប្រាប់ថា ចំនួននៃការប្រើប្រាស់ថ្នាំពុលគីមីមានការកើនឡើងជាលំដាប់ជារៀងរាល់ឆ្នាំ។ មូលហេតុនៃការកើនឡើងនេះដោយសារតែស្រូវមានការកើនឡើងខ្លាំងនូវជម្ងឺ និង ទាក់ទាញសត្វល្អិតច្រើន ពិសេសសម្រាប់កសិករដែលប្រើពូជទំនើបថ្មី (ពិសេសប្រភេទពូជស្រូវក្រអូប ព្រោះវាទាក់ទាញសត្វល្អិត)។

ការកើនឡើងនៃការប្រើប្រាស់ថ្នាំពុលគីមីសម្រាប់សម្លាប់សត្វល្អិតនិងស្មៅចង្រៃ រួមចំណែកសំខាន់ក្នុងការបង្កើនចំណាយរបស់កសិករ។ ជាមធ្យមកសិករចំណាយលើការទិញថ្នាំសម្លាប់សត្វល្អិតអស់ ១៥០០០០រៀលក្នុងដីស្រែមួយហិកតាសម្រាប់ការធ្វើស្រែមួយដង និងចំណាយច្រើនបំផុតអស់ ៦១០០០០រៀល ខណៈតិចបំផុតចំណាយអស់ត្រឹមតែ ១៨០០០រៀលប៉ុណ្ណោះ។

[21] សូមមើលតារាង៩៖ ប្រភេទជំងឺ សត្វល្អិត និងស្មៅដែលស្រង់ចេញពីការសម្ភាស

**តារាង៩៖ ឈ្មោះជីគីមីដ៏ពេញនិយមដែលកំពុងប្រើប្រាស់ដោយកសិករ និងប្រភេទជំងឺ សត្វល្អិត និង ស្មៅ ដែលដកស្រង់ចេញពីការសម្ភាស**

| ជីគីមី | ថ្នាំបំពុល | ប្រភេទរោគ ជម្ងឺស្រូវ | សត្វចង្រៃ | ស្មៅចង្រៃ |
|---|---|---|---|---|
| អាម្ញប៉ុល អ៊ុយរ៉េ ជីផ្លែឈើ ក្បាលក្របី ជីកាលី ជីសេរីរាង្គ ជីសេវ៉ាំងសីរ៉ូ DAP ហ្វីលីពីន ជីជប៉ុន ជីថៃ NPK អាមេរិចកាំង ជីក្បាលគោ ជីសញ្ញាផែនដី(ហ្វូឡង់) វីស្វូណា កាជីប តាអើក ស្វរ៉ាមី | ថ្នាំកាព៉ត់តេ កាំភ្លើងធំ ថ្នាំកាតា ថ្នាំក្បាលខ្លា ថ្នាំខ្យង ថ្នាំស្មៅ សមុទ្រ៣ ណាតូប៉េរ៉ង់ ស្វនាមិ បេហាពី ថ្នាំក្ដាម ថ្នាំ(៩៩) ថ្នាំបាយ៉ន សេកក្រហម វីស្វូណា | គ្រាប់ពង ក្រាភ្លើង ជំងឺអុចស្លឹក ជំងឺផ្សិត ដង្កូវមូលស្លឹក ស្រូវងាប់ដើម ពុកគល់ ដង្កូវមូលករ រលាកស្លឹក រលាកក្ងរ សឹង្ឃដង្កូវ រោគសឹង រោគក្រាលស៊ី ដង្កូវស៊ីឬស | កណ្ដុរស៊ីស្រូវ មមាចត្នោត ដង្កូវតូច ដង្កូវបាក់ខ្នង ដង្កូវកាត់ស្លឹក ដង្កូវចាក់គុល ខ្យងស៊ីស្រូវ កណ្ដូប កណ្ដៀរស៊ីស្រូវ ដង្កូវយោលទង មេអំបៅចង្រៃ ដង្កូវមូស្លឹក ខ្យងក្រហម | ស្មៅគុម្ព ស្មៅកន្ទុយឆ្កែ ស្មៅបំបែកក្បាលស្មៅ ភ្នែកក្ដាម ស្មៅកក់កណ្ដៀរ កាជីប កំផ្លូងរមីស រំពាក់ទឹក ប្ដីស្រូវ ស្មៅឆ្លូញ អំបោស កន្ទុយសេះ កំពេទឹក |

ជាមធ្យមកសិករប្រើប្រាស់ជីអស់៤បារក្នុងស្រែមួយហិកតា តែមានកសិករមួយចំនួនប្រើប្រាស់ជីអស់ច្រើន ទៅដល់ចំនួន ១២បារដោយសារតែកសិករនិយមប្រើប្រាស់ពូជទំនើបថ្មីដែលចាំបាច់ត្រូវប្រើជីគីមីនិងដើម្បីបង្កើនទិន្នផលអោយបានច្រើនសម្រាប់លក់ ពិសេសអ្នកដែលធ្វើស្រែប្រាំង។ តាមបទពិសោធរបស់កសិករភាគច្រើនបំផុត (៨៨.៣%នៃអ្នកផ្ដល់ព័ត៌មានចំនួន៦០នាក់) បានអោយដឹងថា ចំនួននៃការប្រើប្រាស់ជីគីមីគឺមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ដោយសារដីស្រែកាន់តែរិចរិល រឹង គ្មានជីវជាតិ ហើយប្រសិនបើមិនបង្កើនបរិមាណជីទេនោះ ស្រូវនឹងមិនផ្ដល់ផលនោះឡើយ។ ដោយសារតែតម្រូវការជីគីមីកើនឡើង ការចំណាយរបស់កសិករក៏កើនឡើងរច្រើនផងដែរ។

ជាមធ្យមកសិករចំណាយអស់ប្រហែល ៤៩០០០០ រៀលទៅលើដីគឺមីសម្រាប់ដីស្រែមួយហិកតាក្នុងការធ្វើស្រែ១ដង និង ចំណាយច្រើនបំផុតអស់ ដល់ទៅ១,៤០០,០០០ រៀលឯណោះ។

### ឃ. ប្រភពកំលាំងពលកម្ម

ចាប់ពីឆ្នាំ២០០០ជាងរហូតមកបច្ចុប្បន្ន ប្រភពកំលាំងពលកម្មសម្រាប់ការអូសទាញនិងធ្វើស្រែរបស់កសិករមានការប្រែប្រួលយ៉ាងខ្លាំង។ កសិករស្ទើរតែទាំងអស់ (៩៧.៩%) ងាកមកប្រើប្រាស់គ្រឿងម៉ាស៊ីនដូចជាគោយន្តនិងត្រាក់ទ័រជំនួសអោយការប្រើកំលាំងសត្វ។ ហើយអ្វីដែលផ្លាស់ប្តូរខ្លាំងគួរអោយកត់សំគាល់នោះទៀតសោត គឺកសិករលក់កំលាំងឬជួលកំលាំងពលកម្មជាជាងការប្រវាស់ដៃគ្នាដូចកាលពីសម័យមុនៗ។ នេះដោយសារ ទី១៖ ខ្វះកម្លាំងពលកម្មក្នុងស្រុកដោយសារការចំណាកស្រុកទៅធ្វើការនៅខេត្តផ្សេង ជាពិសេសទៅធ្វើការជាកម្មកររោងចក្រ សំណង់ និងតាមផ្ទះនៅទីក្រុង និង នៅប្រទេសថៃជាដើម។ ទី២៖ ការនាំចូលនិងចែកចាយបានទំលំទូលាយនូវគ្រឿងចក្រនៅលើទីផ្សារ។ ទី៣៖ ការប្រើប្រាស់គ្រឿងចក្រគឺលឿននិងរហ័ស ជាពិសេសជួយសម្រួលការងារច្រើនដល់អ្នកដែលមានដីច្រើន។ ប៉ុន្តែ ការកើនឡើងនៃការប្រើប្រាស់គ្រឿងចក្រទាំងនេះ បានបង្កើនចំណាយកាន់តែខ្ពស់ដល់កសិករផងដែរ។ ការចំណាយទៅលើកម្លាំងពលកម្មរួមមានទាំងគ្រឿងចក្រនិងជួលមនុស្ស គឺចាប់ពី ២៥ម៉ឺនទៅ១លានរៀលសម្រាប់ការធ្វើស្រែក្នុងដី១ហិកតា។

### ង. ប្រភពទឹកសម្រាប់ធ្វើស្រែ

ប្រហាក់ប្រហែលទៅនឹងសម័យឆ្នាំទសវត្សរ៍៨០និង៩០ដែរ កសិករនៅតែពឹងផ្អែកខ្លាំងទៅលើទឹកភ្លៀង (៤១.៤%)។ ប្រភពទឹកសំខាន់បន្ទាប់ពីទឹកភ្លៀង គឺមានដូចជាប្រឡាយទឹកចាស់ៗនិងបឹងធំដែលមានស្រាប់ (២៥.៧%) បឹងសហគមន៍ (១៧.១%) បឹងត្រពាំង (១១.៤%) និងប្រលាយថ្មីមានចំនួនតិចតួចបំផុត (៤.៣%)។ នេះហាក់ចង្អុលបង្ហាញអោយឃើញថាប្រព័ន្ធធារាសាស្រ្តសម្រាប់ការធ្វើកសិកម្មជាពិសេសការធ្វើស្រូវរបស់កសិករនូវមានកម្រិតខ្សោយនៅឡើយ ទោះបីជាប្រទេសកម្ពុជាបានចាត់ទុកវិស័យកសិកម្មជាពិសេសដំណាំស្រូវជាផ្នែកមួយដ៏សំខាន់ក្នុងការស្តារ និងលើកស្ទួយវិស័យសេដ្ឋកិច្ចជាតិក្នុងកំឡុងជាង២ទសវត្សនេះមកហើយក៏ដោយ។ ការអភិវឌ្ឍប្រពន្ធ័ធារាសាស្ត្រ

របស់រដ្ឋាភិបាលនៅមានកម្រិតនិងមិនទាន់ឆ្លើយតបទៅនឹងតម្រូវការរបស់កសិករ ជាពិសេសកសិករខ្នាតតូចនិងមធ្យម។ ការបន្តពឹងផ្អែកខ្លាំងទៅលើទឹកភ្លៀងនិងប្រឡាយចាស់បែបនេះនឹងបង្កហានិភ័យច្រើនសម្រាប់ការផលិតស្រូវនិងជីវភាពរបស់កសិករ។ គ្មានភ្លៀងគឺគ្មានទឹកប្រើប្រាស់។

ទន្ទឹមនឹងកង្វះប្រពន្ធ័ធារាសាស្រ្តដែលផ្តល់ដោយរដ្ឋ កសិករត្រូវចំណាយថវិកាដើម្បីទិញទឹកសម្រាប់ធ្វើស្រែ។ តាមការចែករំលែកពីកសិករចំនួន២៤នាក់ បានអោយដឹងថាប្រភពទឹកដើម្បីធ្វើស្រែកន្លងមកនេះទី១ ភាគច្រើនគឺផ្គត់ផ្គង់ដោយឯកជន (៦២.៥%) មានដូចជាករណីនៅក្នុងខេត្តតាកែវ ស្រុកអង្គរបុរីនិងស្រុកបាណន់ ខេត្តបាត់ដំបង ដែលកសិករត្រូវទិញទឹកពីស្ថានីយឯកជនក្នុងតម្លៃ៣០ម៉ឺនរៀលក្នុងដីស្រែមួយហិកតាក្នុងការធ្វើស្រែ១រដូវ។ ទី២ គឺកសិករ ជីកអណ្តូងនិងស្រះដោយខ្លួនឯង (១២.៥%) និងរដ្ឋមានការផ្គត់ផ្គង់តិចតួចប៉ុណ្ណោះប្រមាណជា១៦.៧% តាមរយៈប្រឡាយថ្មីនិងប្រឡាយចាស់ៗដែលបានស្តារ។

*"...ទិញទឹកពីគេតម្លៃ៣០ម៉ឺនរៀលសម្រាប់ដី១ហិកតា។ ធ្វើ១ដងអស់ប្រហែលជា៧០ម៉ឺនរៀល តែបើធ្វើ៣ដងក្នុង១ឆ្នាំគឺអស់២លាន១សែនរៀល។ ទិញទឹកពីស្ថានីយឯកជន។ ឯកជនគេគ្រប់គ្រងស្ថានីយទឹកដោយគេធ្វើព្រែក រួចយើងបូមទឹកពីព្រែកដាក់ចូលក្នុងស្រែដោយខ្លួនឯង..." អ៊ីន អ៊ី ភេទប្រុស អាយុ៦០ឆ្នាំ ស្រុកអង្គរបុរី ខេត្តតាកែវ។*

## ច. ការចំណាយសម្រាប់ការធ្វើស្រែ

កសិករទាំងអស់ បានចំណាយក្នុងការធ្វើស្រែចាប់តាំងពីការចាប់ផ្តើមធ្វើរហូតដល់ពេលប្រមូលផល។ កសិករចំណាយចាប់ពី២០ម៉ឺនទៅដល់៣,៩ លានរៀលក្នុងស្រែមួយហិកតាក្នុងការធ្វើស្រែ១ដង និងជាមធ្យមកសិករ ចំណាយអស់១,២លានរៀលក្នុងដីមួយហិកតា។ ការចំណាយនេះគឺខ្ពស់ខ្លាំងបើធៀបទៅនឹងការចំណាយរបស់កសិករនៅមុននិងក្នុងកំឡុងទសវត្សរ៍៨០និង៩០។ កសិករចំណាយអស់ច្រើន ដោយសារតែពួកគាត់ត្រូវទិញពូជថ្មីជាប្រចាំ ទិញនិងប្រើប្រាស់ជីគីមីនិងថ្នាំពុលច្រើន ចំណាយទៅលើគ្រឿងចក្រ និង ទឹកជាដើម។ ចំពោះអ្នកចំណាយអស់តិច គឺគាត់នៅប្រើជីធម្មជាតិ ប្រើកម្លាំងផ្ទាល់ខ្លួនសម្រាប់ការថែទាំ និងប្រើពូជបុរាណជាដើម។

ដោយសារតែការចំណាយធ្វើស្រែខ្ពស់ កសិករមិនមានប្រាក់ផ្ទាល់ខ្លួនសម្រាប់ចំណាយភ្លាមៗនោះទេ។ តាមរយៈកសិករដែលបានផ្តល់ព័ត៌មានចំនួន៥២នាក់ ក្នុងនោះពាក់កណ្តាលនៃពួកគាត់បានខ្ចីលុយគេសម្រាប់ចំណាយមានដូចជាការខ្ចីពីមីក្រូហិរញ្ញវត្ថុឬធានាគា (៥៧.១%) និងអ្នកផ្សេងទៀត ខ្ចីកម្ចីពីក្រុមសន្សំសហគមន៍ និងអ្នកភូមិ (២៣% និង ១៩%រៀងគ្នា) ។ កម្ចីទាំងនោះ គឺមានអត្រាការប្រាក់ចាប់ពី១.២% ទៅ៤%។ ក្រៅពីខ្ចីកម្ចីពីប្រភពខាងលើ កសិករមួយចំនួនបានទិញជីគីមីថ្នាំពុលគីមី និងពូជបណ្តាក់គេជាមុន រួចបង់សងរំលោះនិងសងត្រលប់វិញនៅពេលដែលគាត់ប្រមូលផលស្រូវបាន។

## ឆ. ការប្រមូលទិន្នផលនិងការផ្គត់ផ្គង់ក្នុងគ្រួសារ

ទិន្នផលស្រូវភាគច្រើន គឺបានក្រោម៣តោនក្នុង១ហិកតា ពិសេសគឺស្រូវវស្សាប្រភេទស្រូវធ្ងន់ដែលភាគច្រើនត្រូវបានដាំដុះឡើងជាចំបងសម្រាប់ហូប និងសល់ខ្លះសម្រាប់លក់ និងមានប្រហែលជា១ភាគ៣នៃកសិករ៨១នាក់ ទទួលបានផលស្រូវច្រើនជាង៣តោនក្នុងមួយហិកតា ពិសេសគឺអ្នកដែលធ្វើស្រែប្រាំង។ នេះដោយសារតែពួកគាត់ប្រើប្រាស់ជីគីមីច្រើននិងប្រើពូជទំនើបថ្មីពិសេសនៅឆ្នាំដំបូងនៃការប្រើពូជថ្មីតែម្តង។ ម្យ៉ាងទៀតនោះ គឺស្រែរបស់ពួកគាត់នៅក្បែរប្រភពទឹកដូចជាស្ទឹងបឹងនិងទន្លេជាដើម ដែលអាចអោយពួកគាត់ស្រោចស្រពទឹកស្រូវបានគ្រប់គ្រាន់។ ជាទូទៅកសិករដែលផលិតស្រូវប្រាំង គឺគាត់ផ្តោតខ្លាំងទៅលើការផលិតដើម្បីលក់ ជាជាងការផលិតដើម្បីបរិភោគក្នុងគ្រួសារ។

ដោយសារការធ្វើស្រែបានផលច្រើនគួរសមនោះ កសិករភាគច្រើន(៧៤.៦%នៃ៦៧នាក់) មានស្បៀងហូបគ្រប់គ្រាន់ ខណៈនៅមានកសិករមួយចំនួនតូច ប្រមាណជា១៦% ហូបមិនគ្រប់គ្រាន់ដោយសារគាត់មានដីតិច សមាជិកច្រើន និងយកទិន្នផលខ្លះទៅលក់ដើម្បីសងបំណុលនិងបំពេញតម្រូវការចាំបាច់ផ្សេងៗទៀតដូចជា មើលជម្ងឺ បុណ្យទាន សម្រាប់កូនរៀនជាដើម។ គ្រួសារខ្លះខ្វះស្បៀងចាប់ពី១ខែទៅ៣ខែ និងខ្លះទៀតខ្វះដល់ទៅ៦ខែ។ ស្ថានភាពនេះ គឺប្រហាក់ប្រហែលទៅ នឹងកំឡុងឆ្នាំ១៩៨០-២០០០ដែរ ដែលមានកសិករមួយចំនួន (២២.៨%) មានការខ្វះអង្ករ/ស្រូវសម្រាប់

បរិភោគ និង បានធ្វើដំណោះស្រាយដូចគ្នា ដោយទិញស្រូវពីគេតាមរយៈលក់មាន់ ទារ ជ្រូក និង លុយកូនផ្ញើរមកឲ្យ និង ខ្ចីគេសម្រាប់ហូប ។

**ជ. ទីផ្សារ (អំណាចក្នុងការគ្រប់គ្រងទីផ្សារ និងតម្លៃ)**

ឈ្មួញឯកជនទាំងក្នុងស្រុក និងអ្នកមកក្រៅស្រុកនៅតែជាតួអង្គចំបងក្នុងការប្រមូលទិញស្រូវពីកសិករ។ កសិករជាទូទៅមិនបានផ្តោតសំខាន់ទៅលើទិសដៅចុងក្រោយនៃការលក់ស្រូវរបស់គាត់បន្ទាប់ពីឈ្មួញទិញនោះទេ។ កសិករស្ទើរតែទាំងអស់លក់ស្រូវអោយឈ្មួញកណ្តាល។ កសិករខ្លះបានអោយដឹងថា ស្រូវគឺដឹកបន្តទៅលក់អោយវៀតណាម ពិសេសកសិករដែលនៅជិតព្រំដែនវៀតណាម ដូចជាកសិករនៅស្រុកអង្គរបុរី ខេត្តតាកែវជាដើម។ ខណៈកសិករមួយចំនួនផ្សេងទៀត ចែករំលែកថាឈ្មួញដែលទិញស្រូវពីពួកគាត់ គឺដឹកបន្តទៅលក់អោយខាងរោងម៉ាស៊ីនស្រូវធំៗនៅខេត្តផ្សេងនិងនៅក្នុងក្រុងភ្នំពេញ ប៉ុន្តែគាត់មិនច្បាស់ថា គេយកស្រូវទៅកែច្នៃឬបន្តយកទៅលក់នៅឯណានោះទេ។ កសិករខ្លះទៀតបានប្រាប់ថា គេដឹកស្រូវដែលទិញពីពួកគាត់នោះ យកទៅផលិតជាអង្ករនិងនាំចេញទៅក្រៅ។ សម្រាប់ការទិញលក់វិញ ស្ទើរតែទាំងអស់គឺធ្វើឡើងនៅក្នុងភូមិ ហើយពេលខ្លះឈ្មួញបានចុះទៅទិញដល់ស្រែរបស់កសិករទៀតផង។ មានកសិករតិចតួចបំផុតដែលបានដឹកយកទៅលក់នៅផ្សារនិងរោងម៉ាស៊ីនកិនស្រូវក្នុងស្រុក និង ដឹកយកមកលក់នៅលើផ្លូវធំ។



កសិកររៀបចំស្រូវសម្រាប់លក់អោយឈ្មួញ នៅស្រុកស្ទោង ខេត្តកំពង់ធំ។ រូបថតដោយ សកម្មភាពសង្គមដើម្បីសហគមន៍ និងការអភិវឌ្ឍ ឆ្នាំ២០១៦។




តម្លៃអង្ករនៅទីផ្សារក្នុងស្រុកមួយនៅរាជធានីភ្នំពេញ។ រូបថតដោយ សកម្មភាពសង្គមដើម្បីសហគមន៍និងការអភិវឌ្ឍ ឆ្នាំ ២០១៦។

តម្លៃស្រូវ និង ស្តង់ដាទាំងអស់ត្រូវបានកំណត់ដោយឈ្មួញ។ កសិករមានលទ្ធភាពតិចតួចបំផុតក្នុងការចរចានិងកំណត់តម្លៃ។ ចំពោះតម្លៃស្រូវទៀតសោត ក្នុងកសិករ៨១នាក់ដែលផ្តល់ព័ត៌មានមានស្ទើរតែទាំងអស់ (៩៧.៦%) នៃពួកគាត់ហើយដែលបានប្រាប់ថា តម្លៃស្រូវដែលឈ្មួញកំណត់នោះ មានតម្លៃថោក។ នៅពេលដែលកសិករប្រើពាក្យថា "ស្រូវមានតម្លៃថោក" មានន័យថា តម្លៃដែលគេកំណត់គឺពិបាកអោយកសិករទូទាត់រួចទៅលើការចំណាយក្នុងពេលផលិតស្រូវឬការធ្វើស្រែ ដែលពេលខ្លះគាត់ត្រូវខាតបង់ច្រើន និង ធ្លាក់ខ្លួនជំពាក់បំណុលគេ និង ចំណាកស្រុកដើម្បីរកលុយសម្រាប់សងគេវិញ។ នៅក្នុងកំឡុង ២ឬ៣ឆ្នាំចុងក្រោយនេះ កសិករគាត់អាចលក់ស្រូវបានក្នុងតម្លៃចាប់ពី ៧០០ ទៅ ១២០០រៀល ក្នុងមួយគីឡូក្រាមទៅតាមប្រភេទស្រូវ។ តម្លៃស្រូវនេះមានតម្លៃទាបបើធៀបទៅនឹងតម្លៃអង្ករដែលមានដាក់លក់នៅក្នុងទីផ្សារក្នុងស្រុកដែលមានតម្លៃចាប់ពី ១៨០០ ទៅ ៤០០០ រៀលក្នុង១គីឡូក្រាម[22]។ ក្នុងចំណោមកសិករ៥៤នាក់ដែលមានបទពិសោធក្នុងការលក់ស្រូវច្រើន ២០%នៃពួកគាត់ជួបការខាតបង់ច្រើននៅពេលលក់ស្រូវ ចំណែកឯ កសិករជាងពាក់កណ្តាលទៀត (៥២%) ទទួលបានចំណេញ តែចំណេញតិចតួចប៉ុណ្ណោះ ក្រៅពីនេះ កសិករ១៨%ទៀត អាចបានត្រឹមទូទាត់រួចនូវចំណាយថ្លៃដើម ប៉ុន្តែគាត់ត្រូវខាតបង់តម្លៃពេលវេលា និងកំលាំងពលកម្មរបស់ខ្លួនដែលធ្វើការហត់នឿយខ្លាំងតែមិនបានចំណេញ។

### ឈ. ការគាំទ្រពីរដ្ឋ

មិនសូវជាខុសពីបទពិសោធកន្លងមកនោះទេ ការគាំទ្រពីរដ្ឋ គឺហាក់ដូចជាពុំសូវមានភាពប្រសើររីកចំរើនឡើយ។ ក្នុងចំណោមកសិករ៧៦នាក់ដែលបានផ្តល់សំភាសន៍ មានកសិករតិចតួចប៉ុណ្ណោះប្រមាណជា២៤% ទទួលបានការគាំទ្រ ការឧបត្ថម្ភពីរដ្ឋ ដូចជាពូជនិងជី ជាដើម។ កសិករភាគច្រើន (៧២%) នៅតែមិនទាន់ទទួលបានការគាំទ្រពីអាជ្ញាធរឬមន្ត្រីកសិកម្មនោះទេ។ កសិករលើកឡើងថារដ្ឋមិនបានជួយក្នុងការផ្តល់ទុនកម្ចីដល់កសិករដែលមានអាត្រាការប្រាក់ទាប ហើយមិនបានជួយស្តារនិងកសាងប្រព័ន្ធធារាសាស្ត្រអោយបានគ្រប់គ្រាន់ដល់កសិករឡើយ ចំណែកតម្លៃស្រូវសមរម្យសម្រាប់កសិករក៏មិនមានការធានានោះដែរ។ ចំពោះកសិករ អ្វីដែលពួកគាត់ត្រូវការមានដូចជា៖

[22] តារាងទំនិញសម្រាប់ខែសីហា ឆ្នាំ២០១៦ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

១. ស្ពាននិងកសាងប្រព័ន្ធធារាសាស្ត្រអោយបានគ្រប់គ្រាន់សំរាប់ពួកគាត់ធ្វើស្រែ។ ២. ជួយរកទីផ្សារនិងផ្តល់តម្លៃស្រូវអោយបានសមរម្យ។ ៣. អោយរដ្ឋជួយផ្តល់ទុនកម្ចីដែលមានការប្រាក់ទាបសំរាប់ធ្វើស្រែ ដែលអាចជួយកាត់បន្ថយពីការចងការឬកម្ចីប្រាក់ពីធនាគារឬមីក្រូហិរញ្ញវត្ថុឯកជនដែលមានអត្រាការប្រាក់ខ្ពស់។ ៤. រដ្ឋជួយគាំទ្រធាតុចូលកសិកម្មដូចជាពូជ ជី ជាដើម។ ៥. រដ្ឋបែងចែកដីដល់កសិករក្រីក្រសម្រាប់ធ្វើស្រែ ដើម្បីបានផលសម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសារបានគ្រប់គ្រាន់។

***"...ខ្ញុំប្រើពូជផ្ការំដួល ចាប់ពីឆ្នាំ ១៩៩៣ ដោយសារឃើញគេប្រើបានផលច្រើនហើយគេថាពូជនេះមានទីផ្សារអន្តរជាតិ ដូចនេះខ្ញុំក៏យកស្រូវពីដើមរបស់ខ្លួនឯងយកទៅដូរយកពូជថ្មីធ្វើរហូត។ គេធ្វើពេញស្រុកសុទ្ធតែពូជថ្មី ។ ហើយពូជនេះគឺ៣ឆ្នាំទិញពីគេម្តង"***

*ផូង ផាន អាយុ៦២ ឆ្នាំ ស្រុកបាណន់ ខេត្តបាត់ដំបង*



**ពូជទំនើបថ្មីនិងហានិភ័យមកលើអធិបតេយ្យស្បៀង សន្តិសុខស្បៀងរបស់កសិករ**

### ៦.២. ហានិភ័យមកលើសន្តិសុខស្បៀង សុវត្ថិភាពស្បៀង និង អធិបតេយ្យស្បៀងរបស់កសិករ

#### ៦.២.១. ការប្រើប្រាស់ពូជទំនើបថ្មី និងហានិភ័យមកលើអធិបតេយ្យស្បៀង និងសន្តិសុខស្បៀង

ការប្តូរ ឬចាប់យកពូជទំនើបថ្មី បង្ករអោយមានក្តីបារម្មណ៍ និងហានិភ័យយ៉ាងខ្លាំងមកលើភាពជាម្ចាស់ ការគ្រប់គ្រងមកលើគ្រាប់ពូជដោយកសិករ និងបញ្ហាស្បៀងរបស់កសិករ និងប្រជាជនសម្រាប់នាពេលបច្ចុប្បន្ន និងនៅពេលអនាគត ។

**នេះ ទី១** ដោយសារតែកសិករមិនអាចរក្សាគ្រប់គ្រង និងសន្សំទុកដាក់ពូជអោយបានយូរអង្វែងដោយខ្លួនឯង តជំនាន់បានឡើយ។ ពូជទាំងនេះ គឺពិបាកទុក មានន័យថា កសិករត្រូវវេចខ្ចប់ដាក់ក្នុងថង់ប្លាស្ទីក រួចក្លាសេទុកដាច់ដោយឡែក ហើយពូជក្លាសេ (ទុកដាក់នៅកន្លែងដែលមានសីតុណ្ហភាពត្រជាក់ល្មម) នេះអាចទុកបានរយៈពេលពី៣ទៅ៦ខែ។ ប៉ុន្តែបើករណីកសិករមិនបានក្លាសេពូជនេះទេនោះ កសិករត្រូវចិញ្ចឹមពូជនេះទុកដោយ ការយកពូជដែលបន្តពីពូជដំបូង យកមកធ្វើតែម្តង (អាចមួយខែក្រោយរើសពូជ)ដោយមិនទុកយូរនោះទេ បើមិនដូច្នោះទេ ពូជនោះគឺមិនដុះឡើយ។ នេះគឺខុសខ្លាំងពីពូជប្រពៃណី។

**ទី២** បើទោះបីជាពូជទំនើបថ្មីអាចផ្តល់ផលបានខ្ពស់ ប៉ុន្តែទិន្នផលនេះបានច្រើនសម្រាប់តែឆ្នាំដំបូងប៉ុណ្ណោះ ហើយពូជទំនើបថ្មីទាំងនេះនិងបន្តថយចុះទិន្នផលនៅឆ្នាំបន្ទាប់ ឬមិនផ្តល់ផលទាល់តែសោះ ឬមិនដុះទាល់តែសោះ និងឆាប់ក្លាយ (ប្តូរពណ៌ ក្លិន រសជាតិរឹង) ទោះបីជាកសិករបន្សុទ្ធពូជទៅតាមបច្ចេកទេសក៏ដោយ ដែលនេះតម្រូវអោយកសិករត្រូវទិញនិងប្តូរពូជជាទៀងទាត់រាល់មួយឆ្នាំម្តង ឬពីរទៅបីឆ្នាំម្តង។

**ទី៣** ពូជទំនើបថ្មីត្រូវបានចែកចាយនិងគ្រប់គ្រងដោយឈ្មួញ និង ក្រុមហ៊ុនឯកជន ឬអ្នកផលិតនិងចែកចាយជាក់លាក់ដូចជាសហគមន៍កសិករជាដើម ជាមួយនឹងតម្លៃថ្លៃដែលកំណត់ដោយអ្នកចែកចាយទាំងនោះ។ នៅពេលខាងមុខ ឈ្មួញអាចទទួលបានសិទ្ធិផ្តាច់មុខក្នុងការគ្រប់គ្រងលើ

គ្រាប់ពូជ ហើយកសិករនឹងប្រឈមទៅនឹងការបាត់បង់ភាពជាម្ចាស់លើគ្រាប់ពូជស្រូវរបស់ខ្លួន និង ពឹងផ្អែកកាន់តែខ្លាំងទៅលើពូជទំនើបដែលគ្រប់គ្រងដោយឈ្មួញ និង អ្នកចែកចាយផលិតគ្រាប់ពូជទាំងនោះ។

**ទី៤** ជាមួយនឹងហេតុផលនៃកត្តាតម្រូវការទីផ្សារចំពោះពូជថ្មី និង សម្រាប់តម្រូវការនាំចេញទៅទីផ្សារអន្តរជាតិ កសិករនឹងបន្តពឹងផ្អែកកាន់តែខ្លាំងទៅលើពូជថ្មី និង ទីផ្សារទាំងនោះ ដែលកសិករខ្លួនឯង មិនអាចធ្វើការគ្រប់គ្រងបាន។ កសិករត្រូវពឹងផ្អែកខ្លាំងទៅលើឈ្មួញ។

*"...មាននៅប្រើពូជ ណាំខុងបូង និង ផ្ការំដួល។ ពូជថ្មីផលល្អរបស់វាគឺធ្វើបានផលច្រើន ទីផ្សារត្រូវការវាដោយសារបាយទន់ បាយក្រអូប ។ ផលមិនល្អនោះគឺពូជថ្មីមានជំងឺច្រើន ប្រើជីគីមីច្រើន ថ្នាំពុលច្រើន ទុកពូជមិនបានយូរ និង ដុះមិនស្វល្អ ។ ការប្រើប្រាស់ពូជថ្មីទៅថ្ងៃអនាគតវានឹងធ្វើអោយខូចដី ចំណាយច្រើន ធ្លាក់ខ្លួនជំពាក់បំណុលគេ..." ហៀង ហាក់ ភេទប្រុស អាយុ ៧៨ឆ្នាំ ខេត្តតាកែវ។*




## សម្រង់សំដីរបស់កសិករអ្នកប្រើប្រាស់និងអ្នកផលិតពូជទៅលើគុណវិបត្តិនៃពូជទំនើបថ្មី៖

*"...ផលពិបាករបស់ពូជថ្មីគឺពូជទុកបានតែមួយឆ្នាំ ងាយក្លាយ (កំពស់ស្រូវខ្ពស់ខ្លី គ្រាប់ខ្លី ប្តូរពណ៌ទៅជាពណ៌ក្រហម ដែលពីមុន គ្រាប់អង្ករពណ៌ស) បើធៀបទៅនឹងពូជបុរាណខាងលើ ពូជថ្មីឆាប់ក្លាយជាង ត្រូវទិញពូជថ្មីប្តូរដើម្បីសុទ្ធ (តែបើយើងទុក នោះទុកបាន២ជំនាន់) ត្រូវប្រើថ្នាំពុលគីមី ដោយសារមានសត្វល្អិតបំផ្លាញ (ដូចជាខ្យងស៊ីស្រូវ ដង្កូវស៊ី ចៃស្រូវ ដែលវាស៊ីស្រូវឡើងក្រហម ក្រាលស៊ីដែលមានសស្លឹក មមាតត្នោត/ភ្លើង ច្រើង*

*ស៊ីផ្លែ) ត្រូវដាក់ជីគីមី បើមិនដាក់គឺមិនបានផលច្រើនទេ (គឺបានផលដូចពីដើម) ...” សម្ភាសន៍ជាក្រុម ជាមួយនឹងកសិករវ៉ៃយកណ្តាល នៅស្រុកអង្គបុរី ខេត្តតាកែវ។*

*"...មានពូជដូចជា អ៊ីអ៊ែរ៦៦ ។ ពូជនេះយកមកពីវៀតណាម ទៅទិញនៅស្រុកអង្គរបុរី។ ១គីឡូតម្លៃ១៥០០រៀល។ ស្រូវនេះត្រូវចិញ្ចឹមពូជ ហើយវាឆាប់ក្លាយពូជ។ ពេលក្លាយ វាមានលក្ខណៈដូចជា ស្រូវដុះវែងខ្លីអត់ត្រឹមគ្រាប់ស្រូវមានដុះកន្ទុយ។ ពូជស្រូវនេះ ក៏មានជំងឺច្រើន ជាងពូជពីដើម។ សម្រាប់រោគនិងជំងឺវា មានដូចជា៖ ក្រាស៊ី ស្លឹកឆេះខ្លោច។ ហើយក៏មានសត្វល្អិតច្រើនដែរ ដូចជា ដង្កូវស៊ីបណ្តូលជាដើម។ សម្រាប់ពូជនេះ បើទុកពូជខ្លួនឯង គឺបានតែ៣ឆ្នាំទេ (៣ជំនាន់) ដូចនេះ ត្រូវដូរឬទិញគេ... ” លោកអ៊ុំសែន ស៊ា អាយុ ៧៩ឆ្នាំ ស្រុកអង្គរបុរី ខេត្តតាកែវ ។*

*"...ផលមិនល្អនៃពូជទាំងនេះគឺមានជំងឺច្រើន បើសំអាតមិនបានល្អមុនដាំដុះ ពិបាកថែទាំ (វាតែងតែមានភាពលាយឡំជាមួយនឹងពូជផ្សេងៗទោះបីជាមានការសំអិតសំអាងយ៉ាងណាក៏ដោយ) ឆាប់ក្លាយ (គ្រាប់ខ្លីជាងមុន បាត់រស់ជាតិដើម បាត់ក្លិនដើម) បច្ចេកទេសតម្រូវអោយប្រើជីគីមី ទុកពូជមិនបានយូរ ត្រូវទិញរាល់ឆ្នាំ ឬ ជាវៀងរាល់២ឆ្នាំម្តង (ករណីបន្សុទ្ធខ្លួនឯងបន្ត) ពូជនេះមានសំដីច្រើន (ស្កុក)” កែ ខាន់ អាយុ ៥៩ឆ្នាំ មានមុខរបរជាកសិករ សមាជិកសហគមន៍ភ្នំតូចសាមគ្គី ជាអ្នកផលិតពូជស្រូវសម្រាប់លក់ដល់កសិករ។*

*"...ផលពិបាកនៃពូជថ្មីគឺឆាប់ក្លាយ និង ទុកពូជមិនបានយូរ។ ពូជនេះ បើស្ទូង ទុកបាន៣ឆ្នាំ តែបើព្រួសវិញ ទុកបានតែ១ទៅ២ឆ្នាំប៉ុណ្ណោះដោយសារតែពូជនេះវាឆាប់ក្លាយ ដូចជា ប្រែទៅជាពណ៌ក្រហម បាត់ក្លិនក្រអូប រសជាតិខ្សោះ ហើយរឹងខុសពីដំបូង ហើយពូជនេះមិនដុះទេ (ដុះបានតែមួយឆ្នាំដំបូងទេ) ភាគច្រើន បើទុកមួយឆ្នាំគឺដុះល្អ បើលើសមួយឆ្នាំ គឺដុះមិនសូវល្អ ឬមិនដុះតែម្តង។ លុះត្រាតែថែទាំខ្លាំងណាស់។ មានជំងឺច្រើន ដូចជា រលាកកគួរ (ខ្មៅៗ) ជំងឺផ្លាស (ខុសពីពូជពីដើម មិនមានរោគច្រើនទេ)។ ពូជមានក្លិនក្រអូប ទាក់ទាញសត្វល្អិតច្រើនជាងពូជធម្មតានិងពូជពីដើមដូចជា នាងមិញ ផ្កាខ្ញី)” កសិករ សមាជិកនៃសហគមន៍ពន្លឺក្តីសង្ឃឹមនៃកសិករ ស្រុកបាណន់ ខេត្តបាត់ដំបង។*

### ក្តីបារម្មណ៍ទៅលើការបាត់បង់ពូជប្រពៃណី

កសិករប្រឈមនិងការបាត់បង់ពូជប្រពៃណីរបស់ខ្លួនពីមួយជំនាន់ទៅមួយជំនាន់ ដោយសារការជម្រុញអោយប្រើប្រាស់និងការចាប់យកពូជទំនើបថ្មី។ នេះបង្ករក្តីបារម្ភណ៍ជាខ្លាំងសម្រាប់នាពេលអនាគតទៅលើការបាត់បង់ពូជស្រូវប្រពៃណីកាន់តែខ្លាំង។ តាមការដកស្រង់ពីកិច្ចសម្ភាសន៍ជាមួយនឹងកសិករទាំងប្រាំខេត្ត ឃើញថាពូជប្រពៃណីដែលកសិករធ្លាប់ប្រើគឺមានចំនួនច្រើនជាង៣០ទៅ៥០មុខជាង (ទាំងស្រូវស្រាល កណ្តាល និងស្រូវធ្ងន់) នៅតាមខេត្តនីមួយៗ ប៉ុន្តែបច្ចុប្បន្ន ចំនួនពូជប្រពៃណីដែលនៅប្រើ គឺនៅមានតិចជាងឬប្រហែល១០មុខជាងតែប៉ុណ្ណោះដោយសារតែការងាកមកពឹងផ្អែកទៅលើពូជទំនើបថ្មីដើម្បីតម្រូវតាមទីផ្សារ។





កសិករកំពុងបាញ់ថ្នាំពុលកសិកម្មនៅលើស្រែរបស់គាត់ នៅស្រុកអង្គរបុរី ខេត្ត តាកែវ។ រូបថតដោយហ៊ីង សុខហ៊ុល




ថ្នាំពុលកសិកម្ម ដែលកសិករប្រើប្រាស់កន្លងមក នៅស្រុកអង្គរបុរី ខេត្ត តាកែវ។ រូបថតដោយហ៊ីង សុខហ៊ុល



ការ៉ុង ជីគីមី ដែលកសិករប្រើប្រាស់ នៅស្រុកអង្គរបុរី ខេត្ត តាកែវ។ រូបថតដោយ ហ៊ីង សុខហ៊ុល

*"...ប្រើជីគីមីធ្វើអោយសត្វចង្រៃកើតច្រើន ដីរឹង ដីក្តាំង បាយរឹង បាត់បង់រសជាតិ ប៉ះពាល់ពាល់សុខ ភាព(ឈឺក្រពះ)។ ទៅអនាគតបាត់បង់សត្វមានប្រយោជន៍ ប៉ះពាល់ក្រពះពោះវៀន ដីក្តាំងរឹង  ឈឺសន្ទាក់..." សាត់ អ៊ុជ ភេទស្រី អាយុ ៦៨ ស្រុកស្ទោង ខេត្តកំពង់ធំ*

*...ប្រើប្រាស់ថ្នាំពុល ធ្វើអោយប៉ះពាល់សុខភាពមនុស្សនិង ប៉ះពាល់សុខភាពសត្វគោក្របី និងធ្វើអោយដី រឹង ហើយធ្វើអោយមនុស្សឈឺច្រើន។ម្យ៉ាងវិញទៀត ធ្វើអោយបាត់បង់ជីវះចំរុះ* **ឧ.** *សត្វក្តាម ខ្យង ត្រី កង្កែប។ មីងគិតថាប្រសិនបើ ប្រើប្រាស់ជីធម្មជាតិធ្វើអោយដីជ្រាយ សំបូរជន្លេន ដីល្អ និងសំបូរក្តាម ខ្យង ត្រី កង្កែប។..." ឆេង លី ភេទស្រី អាយុ ៥៦ឆ្នាំ ស្រុករលាប្អៀរ កំពង់ឆ្នាំង*

**ការប្រើប្រាស់ជីគីមី ថ្នាំពុលគីមី និងបញ្ហាមកលើសុវត្ថិភាពស្បៀង សន្តិសុខស្បៀងរបស់កសិករ**

### ៦.២.២. ការប្រើប្រាស់ជីគីមី ថ្នាំពុលគីមី និងបញ្ហាមកលើសុវត្ថិភាពស្បៀង និងសន្តិសុខស្បៀង

ដីគឺមានសារៈសំខាន់បំផុតសម្រាប់ការដាំដុះផលិតស្បៀងសម្រាប់កសិករនិងប្រជាជនទូទៅ។ ប្រសិនបើដីបាត់បង់និងខ្សោះនូវជីជាតិលឿន នោះកសិករនឹងទទួលរងនូវហានិភ័យយ៉ាងខ្លាំងក្នុងការបាត់បង់ដីដែលមានសមត្ថភាពផលិតស្បៀងអាហារ ដូចជាស្រូវជាដើម ហើយនេះនឹងប៉ះពាល់ខ្លាំងដល់ការផ្គត់ផ្គង់ស្បៀងអាហារសម្រាប់គ្រួសាររបស់កសិករ សហគមន៍ និងប្រជាជាតិទាំងអស់។

តាមបទពិសោធជាក់ស្តែងរបស់កសិករ ដែលចូលរួមផ្តល់ព័ត៌មានក្នុងការសិក្សាស្រាវជ្រាវនេះ ពិសេសកសិករដែលមានបទពិសោធច្រើនក្នុងការប្រើប្រាស់ជីគីមី ភាគច្រើនពួកគាត់បានបង្ហាញពីក្តីបារម្ភណ៍យ៉ាងខ្លាំងទៅលើផលប៉ះពាល់ដែលបណ្តាលមកពីជីគីមីមកលើដីស្រែ ស្រូវនិងបរិស្ថានជុំវិញរួមមានទាំងទឹក និង ជីវិតជីវៈចំរុះដែលមាននៅក្នុងស្រែនិងនៅជុំវិញស្រែរបស់ពួកគាត់។ ជីគីមីបង្ករអោយដីរឹង បាត់បង់ជីវជាតិពីមួយឆ្នាំទៅមួយឆ្នាំទៅតាមពេលវេលានិងចំនួនជីគីមីដែលពួកគាត់បានប្រើ។ ក្រៅពីធ្វើអោយដីស្រែរឹង ខ្សោះជីជាតិ ជីគីមីបង្ករបញ្ហាសុខភាពដល់កសិករដែលជាអ្នកធ្វើស្រែដោយផ្ទាល់និងអ្នកបរិភោគ។ តាមការចែករំលែកពីបទពិសោធជាក់ស្តែង កសិករសង្កេតនិងជួបប្រទះដោយខ្លួនផ្ទាល់តែម្តងអំពីបញ្ហាសុខភាពដែលមានក្រោយការប្រើប្រាស់ជីគីមី គឺ មានជម្ងឺប្រចាំកាយកើតឡើងច្រើនជាងមុនពេលដែលពួកគាត់ប្រើជីគីមី ហើយវាកើតឡើងដោយផ្ទាល់ចំពោះពួកគាត់និងសមាជិកក្នុងភូមិ។ ជម្ងឺទាំងនោះមានដូចជាជម្ងឺឈឺក្រពះ គ្រុនពោះវៀន ឈឺក្បាល រាគរូស និងហើមខ្លួន (ឈឺចុករោយ) ជាដើម។ ជីគីមីក៏បង្ករផលប៉ះពាល់ដល់ដល់សុខភាពរបស់សត្វនិងជីវិតជីវៈចំរុះដែលមាននៅក្នុងស្រែនិងទឹកផងដែរ។ កសិករសង្កេតឃើញថា មានការថយចុះនិងបាត់បង់ពពួកជីវិតចំរុះដែលនៅក្នុងស្រែដែលមានប្រយោជដូចជាជន្លេន កូនត្រី ក្តាមខ្យងសម្រាប់ហូបជាដើមបន្តិចម្តងៗបន្ទាប់ការប្រើប្រាស់ជីគីមី។

*"...ការប្រើប្រាស់ជីគីមីធ្វើអោយ ស្រូវខ្លោច (ពេលបាចជីអ៊ុយរ៉េសុទ្ធ ហើយពេលប្រើច្រើន) មានជំងឺ (រលាកស្លឹក មូលករ/ខ្មៅកន្លែងកស្រូវ...) ជីរឹងខ្សោះ (ធ្វើអោយស្រូវអត់លូតលាស់ ងាប់...) ជំនួននៃការប្រើជីមានការកើនឡើងទៅតាមស្រូវ បើស្រូវល្អ យើងប្រើជីតិច ប្រើស្រូវមិនល្អ ត្រូវប្រើជីច្រើន និង ទៅតាមអាកាសធាតុ (ក្តៅឬភ្លៀង)។ បើមានភ្លៀង ស្រូវល្អ។ ការប្រើថ្នាំពុលគីមី៖ ប៉ះពាល់ សុខភាព (ប៉ះពាល់ និង មានជំងឺក្រពះ ស្ទិត រលាកច្រមុះ បំពង់ក ទឹកស៊ីជើង ឈឺក្បាល វិលមុខ ពុលខ្លួនឯងពេលបាញ់ហើយ) ធ្វើអោយស្រូវខូច (ពេលប្រើថ្នាំខុស ដូចជាពេលទិញថ្នាំបាញ់ស្មៅ គេអោយថ្នាំសំលាប់ដង្កូវ) ងាប់កូនត្រី ក្តាម ខ្យង ដែលយើងហូបបាន ងាប់កង្កែប ពុលទឹក។ តាមបទពិសោធនិងតាមការអង្កេត៖ ការប្រើពូជថ្មី ការប្រើពីជីគីមី និង ថ្នាំពុល ធ្វើអោយមានកើតឡើងនូវសត្វល្អិត និង ស្មៅប្លែកៗកាន់តែដុះច្រើនឡើង។ ឧទាហរណ៍៖ ដូចជា ខ្យងស៊ីស្រូវ កាលពីមុនមិនមាននោះទេ..." ការសម្ភាន៍ជាក្រុមជាមួយនឹងក្រុមកសិករវ៉ែយកណ្តាល ស្រុកអង្គរបុរី ខេត្តតាកែវ។*

ការប្រើប្រាស់ថ្នាំពុលគីមីសម្រាប់សម្លាប់ស្មៅចង្រៃនិងសត្វចង្រៃ ក៏បង្ករនៅបញ្ហាយ៉ាងខ្លាំងសម្រាប់កសិករផងដែរ។ កសិករដែលចូលរួមផ្តល់ព័ត៌មាន ទទួលស្គាល់ថា ការប្រើប្រាស់ថ្នាំពុលគីមីធ្វើអោយប៉ះពាល់យ៉ាងខ្លាំងមកលើគុណភាព សុវត្ថិភាពចំណីអាហារ ពិសេសស្រូវដែលពួកគាត់ផលិត។

ដ្យាក្រាមខាងក្រោមបង្ហាញអំពីបញ្ហាបង្ករដោយជីគីមី និង ថ្នាំបំពុលគីមីៈ








កសិករត្រូវការជម្រើសថ្មីក្នុងការផលិតស្រូវឬធ្វើកសិកម្មដែលធានាបាននូវអធិបតេយ្យស្បៀង សន្តិ
សុខស្បៀង និងសុវត្ថិភាពស្បៀង សេដ្ឋកិច្ច និង បរិស្ថាន

## ៦.៣. ជម្រើសថ្មីសម្រាប់កសិករ និង ឧបសគ្គ

តាមរយៈការស្ទង់មតិជាមួយនឹងកសិករ៨២នាក់ ពួកគាត់ស្ទើរតែទាំងអស់ចង់វិលត្រឡប់ទៅធ្វើស្រែដូចសម័យពីមុន គឺលក្ខណៈបែបប្រពៃណី និងបែបធម្មជាតិ។ កសិកម្មបែបប្រពៃណី និងលក្ខណៈគ្រួសារ ធ្វើអោយកសិករមិនចំណាយថ្លៃដើមច្រើន ធានាបាននូវជីវភាព សុខភាព និងបរិស្ថាន។ ប៉ុន្តែ ការងាកទៅរកកសិកម្មបែបប្រពៃណីវិញ ហាក់នៅមិនទាន់ធ្វើបានភ្លាមៗនោះឡើយសម្រាប់ពួកគាត់ ហើយកសិករត្រូវប្រឈមនឹងឧបសគ្គមួយចំនួនដូចខាងក្រោមៈ

**ទី១** ប្រភេទពូជប្រពៃណីមួយចំនួន ត្រូវបានបាត់បង់ទៅហើយ ដូចនេះ វាផ្តល់ភាពលំបាកសម្រាប់កសិករក្នុងការស្វែងរកនូវពូជទាំងនោះត្រឡប់មកវិញ។ កសិករ បានអោយដឹងថា គ្រាប់ពូជប្រពៃណីគឺអាចអោយគាត់រក្សាទុក និងសន្សំដោយខ្លួនឯងបានយូរពីមួយជំនាន់ទៅមួយជំនាន់ ហើយពូជទាំងនោះធានាបាននូវភាពជាម្ចាស់របស់កសិករ បន្ថយនូវការចំណាយ និងធានាបាននូវនិរន្តភាពនៃស្បៀងអាហារ។ កសិករមិនចាំបាច់ពឹងផ្អែកទៅលើពូជអភិវឌ្ឍថ្មីដែលត្រូវទិញពីឈ្មួញជាប្រចាំនោះឡើយ។ ខណៈដែលពូជមួយចំនួនបានបាត់បង់នោះ កសិករដែលនៅប្រើប្រាស់ពូជប្រពៃណីមួយចំនួន ពួកគាត់បានចែករំលែកថា គាត់នឹងបន្តប្រើប្រាស់ពូជប្រពៃណីដែលគាត់មាន និងបន្តរក្សាទុកពូជទាំងនោះ ចំណែកឯ កសិករដែលកំពុងតែប្រើប្រាស់ពូជទំនើបថ្មីវិញ ពួកគាត់នឹងត្រឡប់ទៅរកពូជប្រពៃណីមួយចំនួននិងប្រើប្រាស់វាឡើងវិញ។

**ទី២** ការប្រើប្រាស់ជីធម្មជាតិ ក៏ជាផ្នែកមួយសំខាន់សម្រាប់កសិកម្មបែបប្រពៃណីផងដែរ។ កសិករអាចប្រើប្រាស់ជីធម្មជាតិដែលរកបាននិងបង្កើតឡើងបានដោយខ្លួនឯងដូចជា លាមកគោក្របី និង ស្លឹករុក្ខជាតិជាដើម។ ការប្រើប្រាស់ជីធម្មជាតិទាំងនេះ មិនត្រឹមតែជួយកសិករក្នុងការកាត់បន្ថយចំណាយប៉ុណ្ណោះទេ វាថែមទាំងជួយរក្សាបាននូវជីវជាតិដី ធ្វើអោយដីធូរ និងបង្កអោយស្រូវលូតលាស់ល្អ។ លើសពីនេះទៀតនោះ វាមិនបង្កហានិភ័យ ឬធ្វើអោយប៉ះពាល់ដល់ជីវិតជីវៈចម្រុះ និង ប្រពន្ធ័អេកូឡូស៊ីដែលមាននៅក្នុងស្រែ និងបរិស្ថានឡើយ។ ប៉ុន្តែ សម្រាប់កសិករ បច្ចុប្បន្នគឺមានការលំបាកក្នុងការទទួលបាន ឬបង្កើតជីធម្មជាតិទាំងនេះ។ កង្វះនូវលាមកសត្វ និងស្លឹករុក្ខជាតិជាកត្តាចំបងមួយសម្រាប់កសិករ ដោយសារតែកសិករបច្ចុប្បន្ន ងាកមកប្រើគ្រឿងចក្រច្រើន បន្ថយចំនួនគោ ក្របីដែលចិញ្ចឹមនៅតាមផ្ទះ ហើយនេះធ្វើអោយមានកង្វះលាមកសត្វ។

**ទី៣** កាប្រើប្រាស់កំលាំងសត្វពាហនៈជាកំលាំងអូសទាញ និងស្មារតីនៃការជួយគ្នាទៅវិញទៅមករបស់កសិករ បានជួយបន្ថយការចំណាយរបស់កសិករ ពិសេសបន្ថយការពឹងផ្អែកទៅលើប្រេង

ឥន្ធនៈ និងថាមពលដែលមិនមានភាពចិតថេរយូរអង្វែង និងមានតម្លៃខ្ពស់។ នេះ ក៏ជួយធានាបានជីវភាពមួយសម្រាប់កសិករ ដោយសារតែថ្លៃដើមចំណាយសម្រាប់ធ្វើស្រែមានតម្លៃទាប។ ទន្ទឹមនិងនោះ ការប្រើប្រាស់កំលាំងពលកម្មក្នុងស្រុក ភូមិ គឺធានាបាននូវការងារក្នុងស្រុកសម្រាប់កសិករ និងយុវជន ដែលនេះអាចជួយកាត់បន្ថយការចំណាកស្រុក។ ប៉ុន្តែ បច្ចុប្បន្ននេះ ការអនុវត្តបែបនេះគឺមានការបាត់បង់ច្រើន។ បញ្ហាចំបងមួយដែលកសិករលើកឡើងចំពោះករណីដែលធ្វើអោយពួកគាត់ពិបាកក្នុងការបន្តប្រើប្រាស់កំលាំងសត្វ គឺដោយសារ ទីផ្សារពិសេសឈ្មួញត្រូវការការប្រមូលផលនិងទិញស្រូវលឿន ដូចកសិករត្រូវប្រើប្រាស់គ្រឿងចក្រដើម្បីពន្លឿនការធ្វើស្រែនិងប្រមូលផលជាដើម។

## ៧. សេចក្តីសរុប

ទស្សនៈវិស័យ និង គោលដៅក្នុងការធ្វើទំនើបកម្មវិស័យកសិកម្មរបស់រាជរដ្ឋាភិបាលកម្ពុជា រួមមានទំនើបកម្មក្នុងវិស័យដំណាំស្រូវជាដើម បានក្លាយទៅជាចលករដ៏ខ្លាំងក្លាមួយ ក្នុងការជម្រុញ និងចូលរួមចំណែកធ្វើអោយមានការផ្លាស់ប្តូរយ៉ាងខ្លាំងនៅក្នុងប្រព័ន្ធផលិតកម្មកសិកម្ម ការផ្លាស់ប្តូរឥរិយាបទ និង ការអនុវត្តរបស់កសិករ។

ក្នុងកំឡុងពេលជាងពីរទសវត្សចុងក្រោយនេះ របៀបនៃការធ្វើកសិកម្មដំណាំស្រូវរបស់កសិករមានការប្រែប្រួលយ៉ាងខ្លាំង ដោយផ្លាស់ប្តូរពីបច្ចេកទេសក្នុងការដាំស្រូវបែបប្រពៃណីមកបែបទំនើបនិងមានលក្ខខណៈពាណិជ្ជកម្ម។ កសិករស្ទើរតែទាំងអស់ (៩៥%) នៃអ្នកផ្តល់បទសម្ភាសន៍កំពុងផ្លាស់ប្តូរ និងងាកមកប្រើប្រាស់នូវពូជស្រូវទំនើបឬពូជស្រូវអភិវឌ្ឍថ្មី ។ កសិករបន្ថែមរដូវ ឬវដ្តដាំដុះពី១ដងទៅដល់៣ដងក្នុងមួយឆ្នាំ និង ពឹងផ្អែកកាន់តែខ្លាំងទៅលើគ្រឿងចក្រជាដើម។ ការប្រែប្រួលនៃការអនុវត្តរបៀបធ្វើកសិកម្មនេះ ធ្វើអោយកសិករបង្កើនចំណាយកាន់តែខ្លាំង និង ឈានដល់ការជំពាក់បំណុលសម្រាប់ធ្វើកសិកម្ម តាមរយៈការប្រើប្រាស់កម្ចីពីស្ថាប័នមីក្រូហិរញ្ញវត្ថុ និងក្រុមសន្សំសហគមន៍ជាមួយនឹងអត្រាការប្រាក់ខ្ពស់ចាប់ពី១.២ ទៅ ៤%ក្នុងខែ។

ការដាក់ចេញនូវគោលនយោបាយ ដែលមានលក្ខណៈផ្តោតសំខាន់ទៅលើការជម្រុញ ការអភិវឌ្ឍ និង ពឹងផ្អែកកាន់តែខ្លាំងទៅលើកសិ-ឧស្សាហាកម្ម និង ការធ្វើកសិកម្មសម្រាប់ពាណិជ្ជកម្មដូចជាការកែច្នៃស្រូវនិងការនាំចេញអង្ករទៅកាន់ទីផ្សារអន្តរជាតិរបស់រដ្ឋាភិបាល បានធ្វើអោយកសិករ ទាំងខ្នាតតូច និង មធ្យម ខំប្រឹងប្រែងផលិតទៅតាមតម្រូវការទីផ្សារ ពិសេសគឺការប្រើប្រាស់ពូជអភិវឌ្ឍថ្មី ឬពូជទំនើបថ្មី ការប្រើប្រាស់ធាតុចូលយ៉ាងច្រើន ដូចជាជីគីមីនិងថ្នាំពុលកសិកម្មដើម្បីជម្រុញល្បឿននៃផលិតកម្ម និងបង្កើនទិន្នផល ហើយកសិករ បន្តពឹងផ្អែកកាន់តែខ្លាំងទៅលើទីផ្សារដែលមិនមានភាពច្បាស់លាស់ ទាំងតម្លៃ និង បរិមាណ។ តាមសិក្សានេះ ទីផ្សារ តម្លៃ គុណភាព និងបរិមាណ គឺត្រូវបានគ្រប់គ្រងដោយឈ្មួញ។ នេះ បានបង្កហានិភ័យខ្ពស់សម្រាប់កសិករ។ កសិករត្រូវប្រឈមនិងការខាតបង់ខ្លាំង ដោយសារការចំណាយថ្លៃដើមក្នុងការផលិតខ្ពស់ ហើយតម្លៃលក់ស្ថិតក្នុងកម្រិតដែលកសិករមិនអាចគ្រប់គ្រងបាន ដែលតាមបទពិសោធក្នុងរយៈពេលប៉ុន្មានឆ្នាំចុង

ក្រោយនេះ តាមបទសម្ភាសន៍ ឃើញថា តម្លៃស្រូវគឺមានតម្លៃថោកដែលកសិករពិបាកនឹងទទួលយក។

ទន្ទឹមនឹងបញ្ហាខាងលើ ការប្រើប្រាស់ពូជទំនើបថ្មី ឬពូជអភិវឌ្ឍថ្មី ផ្តល់ផលពិបាកដល់កសិករ និងធ្វើអោយប៉ះពាល់ដល់អធិបតេយ្យរបស់កសិករទៅលើស្បៀងអាហារ ពិសេសគឺអធិបតេយ្យទៅលើគ្រាប់ពូជ ហើយនៅក្នុងរយៈពេលវែងទៅថ្ងៃមុខ និងមានផលប៉ះពាល់ខ្លាំងមកលើសន្តិសុខស្បៀងរបស់កសិករ។ កសិករបាត់បង់នូវភាពជាម្ចាស់និងអំណាចក្នុងការគ្រប់គ្រងពូជស្រូវរបស់ពួកគាត់ ហើយពឹងផ្អែកកាន់តែខ្លាំងឡើងទៅលើពូជថ្មីដែលគ្រប់គ្រងដោយអ្នកអភិវឌ្ឍពូជ ឬ អ្នកផលិតពូជស្រូវសម្រាប់លក់។

ការអនុវត្តច្បាប់ស្តីពី ការគ្រប់គ្រងជីនិងថ្នាំកសិកម្ម និង ការបើកអោយមានការនាំចូល ឬផលិតនិងចែកចាយនូវរាល់ប្រភេទជីនិងថ្នាំកសិកម្ម បានចូលរួមចំណែកក្នុងការធ្វើអោយមានការប្រែប្រួលទម្លាប់និងការអនុវត្តរបស់កសិករ ចំពោះការប្រើប្រាស់ជីសម្រាប់ធ្វើស្រែផងដែរ។ នេះដោយសារតែ កសិករអាចងាយនឹងត្រូវបានទាក់ទាញ លើកទឹកចិត្តអោយប្រើប្រាស់ដោយអ្នកផ្សព្វផ្សាយជីគីមី និង ថ្នាំពុលកសិកម្ម ហើយទំនិញទាំងនេះ គឺងាយស្រួលក្នុងការរកទិញបានទៅលើទីផ្សារក្នុងស្រុក។

ទិសដៅ និងការជម្រុញរបស់រាជរដ្ឋាភិបាលដែលកំពុងតែទទួលរងនូវឥទ្ធិពលប្រព័ន្ធទីផ្សារ និងពាណិជ្ជកម្មសេរី នៃសេរីភាវូបនីយកម្មមកលើវិស័យកសិកម្មនៅប្រទេសកម្ពុជា រួមមានការជម្រុញធ្វើទំនើបកម្មកសិកម្មដំណាំស្រូវ ការផ្តោតទៅលើផលិតកម្មដើម្បីការនាំចេញ និងទីផ្សារអន្តរជាតិ ពិសេសការជម្រុញអោយមានការប្រើប្រាស់ពូជស្រូវបង្កាត់ថ្មី និងការធ្វើយន្តូបនីយកម្មនេះ ហាក់បីដូចជា មិនបានធានានូវសមធម៌ សន្តិសុខស្បៀង និងការអភិវឌ្ឍពិតប្រាកដនៅតំបន់ជនបទឡើយ។ ហើយនេះ អាចគម្រាមគំហែងដល់ សន្តិសុខស្បៀង សុវត្ថិភាពស្បៀង និងអធិបតេយ្យស្បៀង របស់កសិករក្រីក្រ កសិករខ្នាតតូច និងកសិករខ្នាតមធ្យមនៅប្រទេសកម្ពុជា។ ដែលជាលទ្ធផលរយៈពេល

វែង វានឹងអាចផ្តល់ផលប៉ះពាល់ដល់ការអភិវឌ្ឍសង្គម និងបង្កអោយមានភាពក្រីក្រកាន់តែខ្លាំងឡើងៗដល់ប្រជាជននៅប្រទេសកម្ពុជាផងដែរ។

ស្ទើរតែទាំងអស់នៃកសិករដែលចូលរួមក្នុងការសិក្សាស្រាវជ្រាវ ចង់ត្រឡប់ទៅអនុវត្តការធ្វើកសិកម្មបែបប្រពៃណីវិញ ហើយភាគច្រើនបំផុតនៃពួកគាត់ជឿជាក់ថា ការអនុវត្តកសិកម្មបែបធម្មជាតិ អាចធានាបាននូវសុខភាព បរិស្ថាន និង ជីវភាពរបស់ពួកគាត់បានយូរអង្វែង ។ ប៉ុន្តែ វាហាក់បីដូចជានូវមានឧបសគ្គច្រើនសម្រាប់ពួកគាត់ ក្នុងការត្រឡប់ទៅអនុវត្ត ឬកែប្រែទៅរកកសិកម្មបែបធម្មជាតិ ឬប្រពៃណីនេះ។ ដូចនេះ ការត្រឡប់ ឬកែប្រែការអនុវត្ត និង ការជម្រុញការធ្វើកសិកម្មបែបធម្មជាតិ គឺត្រូវការពេលវេលា ឆន្ទៈរបស់កសិករ និង ឆន្ទៈនយោបាយនិងការចូលរួមចំណែកពីរាជរដ្ឋាភិបាលកម្ពុជា និង ស្ថាប័នពាក់ពន្ធ័ទាំងអស់។

## ៨. អនុសាសន៍របស់កសិករនិងក្រុមស្រាវជ្រាវទៅកាន់រដ្ឋាភិបាល និង ស្ថាប័នពាក់ព័ន្ធ៖

- ផ្សព្វផ្សាយ ជម្រុញលើកទឹកចិត្ត អោយអនុវត្ត កសិកម្មបែបធម្មជាតិឬប្រពៃណី (រួមមានដូចជាការប្រើប្រាស់ពូជប្រពៃណី ជីធម្មជាតិ ការដាំដំណាំចំរុះ និង ការទុកពេលអោយដីសម្រាកគ្រប់គ្រាន់...) ដើម្បីកាត់បន្ថយចំណាយ ការប៉ះពាល់ដល់សុខភាព និងបរិស្ថាន។
- រដ្ឋត្រូវប្រមូល និង រក្សាទុកអោយបាននូវពូជប្រពៃណីដែលមាន និង លើកកំពស់ការយល់ដឹងការផ្សព្វផ្សាយពីគុណប្រយោជនៃពូជប្រពៃណី និង បង្កើនការប្រើប្រាស់ពូជប្រពៃណីឡើងវិញ។
- ការគិតគូរអំពីផលិតកម្មបែបគ្រួសារ និងជាលក្ខណៈសហគមន៍ ដើម្បីផ្គត់ផ្គង់ក្នុងគ្រួសារ សហគមន៍ និង ប្រជាជនក្នុងស្រុកជាមុន មុនគិតគូរដល់ការនាំចេញទៅទីផ្សារអន្តរជាតិ ឬពង្រីកទីផ្សារអន្តរជាតិ គឺជាផ្នែកមួយសំខាន់ក្នុងការលើកស្ទួយគាំទ្រដល់ទីផ្សារក្នុងស្រុកសម្រាប់ការផលិតកសិផលក្នុងស្រុករួមមានទាំងស្រូវនិងអង្ករ។ ហើយកសិករត្រូវចូលរួមចំណែកក្នុងការកំណត់ពីតម្លៃទីផ្សារសម្រាប់កសិកផល ដែលពួកគាត់ផលិតបានរួមមានទាំងស្រូវនិងអង្ករ។ រដ្ឋាភិបាលផ្តោតលើការពង្រឹង និងពង្រីកទីផ្សារក្នុងស្រុក និងគាំទ្រដល់កសិផលក្នុងស្រុក មុនការនាំចេញ និងទីផ្សារអន្តរជាតិ ពិសេសអោយមានការចូលរួមពីកសិករក្នុងការគ្រប់គ្រង និងកំណត់តម្លៃទីផ្សារ។ ទន្ទឹមនឹងនោះ រដ្ឋាភិបាលគួកំណត់ឬដាក់កម្រិតទៅលើការនាំចូលប្រភេទកសិផលដែលកសិករក្នុងស្រុកអាចផលិតបាន និងផ្គត់ផ្គង់ក្នុងស្រុកបាន ដើម្បីធានាបាននូវទីផ្សារសម្រាប់កសិកផលក្នុងស្រុក។
- រាជរដ្ឋាភិបាលពង្រឹងប្រព័ន្ធធារាសាស្ត្រ ដើម្បីអោយឆ្លើយតបទៅនឹងតម្រូវការកសិករដើម្បីធ្វើអោយប្រសើរឡើងនូវវិស័យកសិកម្ម ដូចមានចែងនៅក្នុងគោលនយោបាយ
- រដ្ឋធ្វើការបែងចែកដីសម្រាប់កសិករក្រីក្រនិងកសិករដែលគ្មានដីសម្រាប់ធ្វើស្រែ ឬមានដីតិចតួច ដើម្បីអោយគាត់មានលទ្ធភាពក្នុងការប្រកបរបរកសិកម្មដើម្បីចិញ្ចឹមជីវិត គ្រួសារ សហគមន៍ និង ប្រទេសជាតិ
- រដ្ឋផ្តល់ការឧបត្ថម្ភធន រួមមានទុនដែលគ្មានការប្រាក់ឬការប្រាក់ទាបបំផុត សម្ភារៈកសិកម្ម និងធាតុចូលកសិកម្មដូចជាជីធម្មជាតិ គ្រាប់ពូជប្រពៃណី និងជួយចេញថ្លៃខាតបង់ពីការផលិតជាដើម។

- ជម្រុញ និងលើកទឹកចិត្តអោយកសិករចិញ្ចឹមគោ ក្របី នៅតាមគ្រួសារ ឬក្នុងភូមិ សម្រាប់ជាកំលាំងអូសទាញ និងទាញយកលាមកមកប្រើប្រាស់ជាជីធម្មជាតិ និងដាំរុក្ខជាតិដំណាំមានប្រយោជន៍នៅក្បែរស្រែសម្រាប់ធ្វើជាជីធម្មជាតិ
- ធ្វើការស្តាដីដែលខូចគុណភាព អោយមានគុណភាពឡើងវិញ ដោយមានការចូលរួមពីកសិករនៅគ្រប់ដំណើរការ
- ផ្សព្វផ្សាយពីផលប៉ះពាល់ពីការប្រើប្រាស់ជីគីមី និងថ្នាំពុលអោយបានទូលាយដល់កសិករ
- គ្រប់គ្រងការនាំចូលនិងចែកចាយជីគីមី និងថ្នាំពុល
- ផ្សព្វផ្សាយពីគុណវិបត្តិនៃការប្រើប្រាស់គ្រឿងចក្រ
- រដ្ឋត្រួតពិនិត្យ និងវិសោធនកម្មលើគោលនយោបាយ និងច្បាប់ដែលពាក់ពន្ធ័ទាំងឡាយដែលមានផលប៉ះពាល់មកលើសិទ្ធិនិងប្រយោជន៍របស់កសិករ
- ស្ថាប័នម្ចាស់ជំនួយ ដៃគូរអភិវឌ្ឍ បញ្ឈប់ការដាក់លក្ខខ័ណ្ឌ ឬសម្ពាធមកលើរដ្ឋាភិបាលកម្ពុជាក្នុងការធ្វើសេរីភាវូបនីយកម្មមកលើវិស័យកសិកម្មដែលប៉ះពាល់ដល់សិទ្ធិនិងប្រយោជន៍របស់កសិករ៕

